សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# វិធានការនិរន្តរាយ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ លោក **ប្រុស សុវណ្ណតារា**
លោក **ហួ ច័ន្ទពិសិដ្ឋ**

សាស្ត្រាចារ្យណែនាំ
លោក **ទ្រី សុធារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# វិធានការនិរន្តរាយ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ លោក **ប្រុស សុវណ្ណតារា**

លោក **ឃួ ច័ន្ទពិសិដ្ឋ**

សាស្ត្រាចារ្យណែនាំ

លោក **ជ្រ សុតារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរឈ្មោះ **ប្រុស សុវណ្ណតារា** និង **ហួ ច័ន្ទពិសិដ្ឋ** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមអនុញ្ញាតលំឱនកាយវាចាចិត្តសម្តែងនូវគារវកិច្ចគោរពដឹងគុណដោយស្មោះអស់ពីដួងចិត្ត និងមហាកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅពុំអាចកាត់ថ្លៃបានជូនចំពោះ ៖

**លោកឪពុក** និង **អ្នកម្តាយ** របស់យើងខ្ញុំទាំងពីរដែលលោកទាំងទ្វេបានផ្តល់កំណើតដល់រូបយើងខ្ញុំ និងប្រឹងប្រែងយ៉ាងខ្លាំងពេញមួយជីវិតដើម្បីចិញ្ចឹមបីបាច់ថែរក្សាការពារយើងខ្ញុំតាំងតែពីតូចរហូតដល់ធំ ព្រមទាំងបានផ្តល់ការអប់រំទូន្មានប្រៀនប្រដៅណែនាំផ្តល់ជាកម្លាំងចិត្តដល់រូបយើងខ្ញុំទាំងពីរប្រកបដោយព្រហ្មវិហារធម៌ជារៀងរហូតមក រួមទាំងបានផ្តល់យើងខ្ញុំនូវការសិក្សារៀនសូត្រក្រេបយកចំណេះវិជ្ជាតាំងពីថ្នាក់មតេយ្យរហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ។ សេចក្តីដឹងគុណចំពោះ **លោកឪពុក** និង **អ្នកម្តាយ** ទាំងអស់នេះពិតជាធំធេងដែលពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតពួកយើងខ្ញុំទាំងពីរ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលរូបសម្តេចបានខិតខំតស៊ូព្យាយាមគ្រប់កាលៈទេសៈនៅក្នុងសង្គមជាតិទាំងអស់ក្នុងការប្រឹងប្រែងខិតខំបង្រួបបង្រួមជាតិ ដោយបានបង្កើតនូវនយោបាយឈ្នះៗក្នុងការត្រួសត្រាយផ្លូវដ៏ល្អប្រពៃមួយក្នុងដំណើរឆ្ពោះទៅរកការឯកភាពជាតិ សន្តិភាព និងស្ថេរភាពនយោបាយជានិច្ចនិរន្តន៍ដែលជាកត្តាមួយដ៏ចាំបាច់ក្នុងការជម្រុញឱ្យមានការអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានភាពរីកចម្រើនលូតលាស់លើគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសកម្ពុជាប្រកបដោយនិរន្តរ៍ភាព។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ និង សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំគណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលលោកទាំងអស់បានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តចូលរួមលើកស្ទួយបណ្តុះបណ្តាលធនធានមនុស្សឱ្យទទួលបាននូវចំណេះដឹងយ៉ាងទូលំទូលាយនិងការអប់រំដ៏ល្អយ៉ាងច្បាស់លាស់ ជាពិសេសនោះគឺការបង្ហាត់បង្រៀន និងផ្តល់ជាដំបូន្មានដល់យើងខ្ញុំទាំងពីរតាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតបានបញ្ចប់នូវថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ។

ពិសេសជាងនេះទៅទៀតនោះ យើងខ្ញុំទាំងពីរសូមលំឱនកាយគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអស់ពីចិត្តជូនចំពោះ **លោកមេធាវី ជ្រ សុតារ៉ា** ដែលលោកជាសាស្ត្រាចារ្យណែនាំ និងដឹកនាំដល់ការសរសេរសារណារបស់យើងខ្ញុំ ដោយរូបលោកបានខិតខំអស់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត រួមទាំងចំណាយពេលវេលាដ៏មានតម្លៃមកធ្វើការពន្យល់ណែនាំបង្ហាញនូវគន្លឹះសំខាន់ៗ ហើយបានផ្ដល់នូវដំបូន្មាន រួមទាំងគំនិត និងចំណេះដឹងសំខាន់ផ្សេងៗទៀត ព្រមទាំងលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរចាប់តាំងពីថ្ងៃដែលចាប់ផ្ដើមសរសេរសារណារហូតដល់ទទួលបាននូវស្នាដៃមួយនេះជាស្ថាពរដែលគុណទាំងអស់ខាងលើនេះគឺពិតជាមានតម្លៃយ៉ាងវិសេសវិសាលធំធេងពុំអាចកាត់ថ្លៃបានឡើយមកលើយើងខ្ញុំទាំងពីរ។

# អារម្ភកថា

យើងខ្ញុំទាំងពីរជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២១ ដោយយើងខ្ញុំបានឆ្លងកាត់ការសិក្សាអប់រំបណ្តុះបណ្តាលក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំមកនេះ បានបង្ហាញឱ្យឃើញថាការសិក្សានៅក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះពិតជាបានផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងណាស់សម្រាប់យើងខ្ញុំទាំងពីរដែលជាសរសរទ្រូងនៃប្រទេសជាតិនាជំនាន់ក្រោយនេះ។ ជាក់ស្តែង បន្ទាប់ពីយើងខ្ញុំបានសិក្សាអំពីមុខវិជ្ជាជាច្រើននៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្ររួចមក យើងខ្ញុំបានក្រេបនូវចំណេះដឹងជាច្រើន ក៏ដូចជាទទួលបាននូវបទពិសោធន៍មួយចំនួនធំផងដែរ ទោះបីជាកាលៈទេសៈខ្លះយើងខ្ញុំទាំងពីរបានជួបប្រទះនូវផលវិបាក និងភាពស្មុគស្មាញយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែជំនះព្យាយាមតស៊ូសិក្សាស្វែងយល់ទទួលនូវចំណេះវិជ្ជាដោយមិនព្រមរុញរាឬបោះបង់ចោលនូវការខិតខំប្រឹងសង្វាតនូវការសិក្សាដ៏ល្អប្រពៃនេះឡើយ ដោយយើងខ្ញុំប្តេជ្ញាថានឹងបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះឱ្យទទួលបានជោគជ័យជាស្ថាពរ និងទទួលបានលទ្ធផលល្អគួរជាទីគាប់ចិត្ត។ ទន្ទឹមនឹងនេះដែរ ដើម្បីទទួលការបញ្ចប់ថ្នាក់បរិញ្ញាបត្រឱ្យបានជោគជ័យត្រចះត្រចង់នោះយើងខ្ញុំទាំងពីរនាក់មានគោលបំណងដោយបានសម្រេចចិត្តជាមួយគ្នាថានឹងបញ្ចប់ការសិក្សានេះដោយការសរសេរសារណាមួយដ៏សមប្រកបដែលជាស្នាដៃដ៏សំខាន់មួយសម្រាប់យើងខ្ញុំទាំងពីរ បន្ទាប់ពីបានសិក្សាក្រេបជញ្ជក់យកចំណេះដឹងអស់រយៈពេល ៤ឆ្នាំ កន្លងមកនេះ។

ម្យ៉ាងទៀតនោះ ដោយសារតែយើងខ្ញុំបានឆ្លងកាត់ការសិក្សានូវមុខវិជ្ជាដ៏សំខាន់ៗជាច្រើនក្នុងថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក៏ដូចជាផ្នែកច្បាប់នេះ យើងខ្ញុំទាំងពីរនាក់មានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ដោយហេតុថាមុខវិជ្ជានេះគឺជាមុខវិជ្ជាមួយដែលបានសិក្សារៀនសូត្រអំពីនីតិវិធីព្រហ្មទណ្ឌដែលជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀតសម្រាប់ការគ្រប់គ្រងសណ្តាប់ធ្នាប់សង្គម ដោយយើងខ្ញុំបានសិក្សាទាក់ទងទៅនឹងនីតិវិធីដែលត្រូវអនុវត្ត ជាពិសេសនោះគឺបញ្ញត្តិដែលបានចែងអំពីនីតិវិធីនៃដំណាក់កាលទាំងបួនក្នុងរឿងក្តីព្រហ្មទណ្ឌ។ ជាងនេះទៅទៀតនោះ គឺយើងខ្ញុំបានសិក្សាអំពីដំណាក់ស៊ើបសួរដែលដឹងនាំនីតិវិធីដោយចៅក្រមស៊ើបសួរដែលជាដំណាក់ទី៣ នៃនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងទៀត នៅក្នុងដំណាក់កាលស៊ើបសួរដែលដឹកនាំដោយចៅក្រមស៊ើបសួរនេះ ក៏មានវិធានមួយដែលចៅក្រមស៊ើបសួរតែងតែប្រើប្រាស់ជាប្រចាំសម្រាប់ឱ្យដំណើរការនីតិវិធីនៃការស៊ើបសួរប្រព្រឹត្តទៅដោយរលូនដែលវិធាននេះគឺ«**វិធានការនិរន្តរាយ**»។

អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំទាំងពីរសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយគឺ « **វិធានការនិរន្តរាយ**» មកធ្វើការសិក្សាស្រាវជ្រាវ។

ចំពោះមូលហេតុដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ និង ចងក្រងឡើងជាសៀវភៅនេះគឺដោយសារតែយើងខ្ញុំទាំងពីរមានគោលបំណងក្នុងការទទួលបាននូវបទពិសោធន៍ ក៏ដូចជាចំណេះដឹងបន្ថែមឱ្យកាន់តែស៊ីជម្រៅអំពីវិធានការនិរន្តរាយនេះ ទោះបីជាប្រធានបទនេះធ្លាប់ត្រូវបានសិស្ស ច្បងជំនាន់មុនមួយចំនួនបានយកមកធ្វើការសរសេររួចហើយក៏ដោយនោះ។ ទោះបីជាយ៉ាងណា ក៏យើងខ្ញុំសង្ឃឹម យ៉ាងមុតមាំថាការសិក្សាស្រាវជ្រាវថ្មីនេះអាចនឹងទទួលបានអ្វីដែលថ្មីជាងមុនខុសពីការស្រាវជ្រាវមុនៗផងដែរ។ ដោយយើងខ្ញុំមានការបូកបញ្ចូលនូវការអនុវត្តជាក់ស្ដែងនៃវិធានការនេះខ្លះៗផងដែរ និងការអនុវត្តរបស់ចៅក្រម ស៊ើបសួរមួយចំនួនមកធ្វើការបកស្រាយ។

ជាងនេះទៅទៀតនោះ ដោយមូលហេតុថាប្រធានបទ «**វិធានការនិរន្តរាយ**» មានភាពទូលំទូលាយ ដូច្នេះ យើងខ្ញុំទាំងពីរសូមធ្វើការអភ័យទោសជាមុន ប្រសិនបើការស្រាវជ្រាវរបស់យើងខ្ញុំមានចំណុចខ្វះខាតត្រង់ប្រការ ណាមួយនោះ ជាពិសេសនោះទាក់ទងទៅនឹងការអនុវត្តជាក់ស្ដែងនៃវិធានការនេះពីព្រោះថាយើងខ្ញុំទាំងពីរនាក់ គឺជានិស្សិតនៅឡើយដែលពុំទាន់បានឆ្លងកាត់ការអនុវត្តជាក់ស្ដែងទេ ដែលជាហេតុនាំឱ្យការស្រាវជ្រាវរបស់យើង ខ្ញុំនៅមានកម្រិតនៅឡើយ។ ក៏ប៉ុន្ដែទោះបីជាកាលៈទេសៈណាក៏ដោយក៏យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវមួយនេះ អាចផ្ដល់នូវចំណេះដឹងបន្ថែមដល់អ្នកសិក្សាដែរ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមទទួលការរិះគន់ដើម្បីស្ថាបនាកែលម្អពីសំណាក់ លោក លោកស្រី ជាសាស្ត្រាចារ្យ បងប្អូន ក៏ដូចជាមិត្តភក្ដិជានិស្សិតទាំងអស់ដែលបានអានស្នាដៃមួយនេះ ហើយយើងខ្ញុំនឹង រីករាយទទួលនូវកំហុសណាមួយដែលកើតមានឡើងដោយអចេតនារបស់យើងខ្ញុំទាំងពីរនាក់។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** .......... ១

**ជំពូកទី១**

**ចៅក្រមស៊ើបសួរ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ** .......... ៦

១.១ សញ្ញាណគតិយុត្ត .......... ៦

១.២. គោលបំណង .......... ៦

**ផ្នែកទី២៖ សមត្ថកិច្ច** .......... ៧

២.១. សមត្ថកិច្ចដែនដី .......... ៧

២.២. សមត្ថកិច្ចចងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ .......... ៨

**ផ្នែកទី៣៖ ប្រភពនាំឱ្យមានការស៊ើបសួរ** .......... ៨

៣.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ .......... ៨

៣.២. ពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ .......... ៨

**ជំពូកទី២**

**វិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃវិធានការនិរន្តរាយ** .......... ១០

១.១. សញ្ញាណទូទៅនៃវិធានការនិរន្តរាយ .......... ១០

១.២. អានុភាពនៃវិធានការនិរន្តរាយ .......... ១១

**ផ្នែកទី២៖ ការចេញដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ** .......... ១១

២.១. ដីកាបង្គាប់ឱ្យចូលខ្លួន .......... ១១

២.១.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យចូលខ្លួន .......... ១១

២.១.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យចូលខ្លួន .......... ១២

២.១.៣. ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន .......... ១៣

២.១.៤. អានុភាពនៃដីកាបង្គាប់ឱ្យចូលខ្លួន .......... ១៤

២.២. ដីកាបង្គាប់ឱ្យនាំខ្លួន .......... ១៥

២.២.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យនាំខ្លួន .......... ១៥

២.២.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យនាំខ្លួន .......... ១៥

២.២.៣. ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន .......... ១៧

២.២.៤. អានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួន .......... ១៨

២.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................................................................ ១៩
២.៣.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យចាប់ខ្លួន ....................................................................... ១៩
២.៣.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យចាប់ខ្លួន ....................................................................................២០
២.៣.៣. ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................................................២១
២.៣.៤. អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួន.......................................................................................២៣
២.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន ..........................................................................................................២៤
២.៤.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យឃុំខ្លួន ........................................................................២៥
២.៤.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យឃុំខ្លួន .....................................................................................២៥
២.៤.២. ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន .........................................................................................២៥
២.៤.៤. អានុភាពនៃដីកាបង្គាប់ឱ្យឃុំខ្លួន........................................................................................២៦
**ផ្នែកទី៣៖ ការឃុំខ្លួនបណ្តោះអាសន្ន**............................................................................................២៦
៣.១ គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ...........................................................................២៦
៣.២.លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ..................................................................................២៧
៣.២.១. បទល្មើស ..........................................................................................................................២៧
៣.២.២. អាយុរបស់ជនត្រូវចោទ ........................................................................................................២៩
៣.៣. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ..................................................................................៣០
៣.៤. នីតិវិធីសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន...........................................................................៣១
៣.៥. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន.....................................................................................៣២
៣.៥.១.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទឧក្រិដ្ឋ..........................................................៣៣
៣.៥.១.១. ករណីជនត្រូវចោទជានីតិជន ....................................................................................... ៣៣
៣.៥.១.២.ករណីជនត្រូវចោទជាអនីតិជន ....................................................................................... ៣៣
៣.៥.២.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទមជ្ឈិម.............................................................៣៤
៣.៥.២.១.ករណីជនត្រូវចោទជានីតិជន ..........................................................................................៣៤
៣.៥.២.២.ករណីជនត្រូវចោទជាអនីតិជន ..........................................................................................៣៥
៣.៥.៣.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋសង្គ្រាម ...............................................................................................៣៥
៣.៥.៤. ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ....................................................................... ៣៦
៣.៦. ការបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ..................................................................................... ៣៧
៣.៦.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ.............................................................................៣៧
៣.៦.១.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ........................... ៣៧

៣.៦.១.២.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ..................... ៣៨
៣.៦.១.៣.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ជនត្រូវចោទ ..................... ៣៩
៣.៦.២. ការបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្នដោយដីកាដំណោះស្រាយ ..................................... ៤០
**ផ្នែកទី៤៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ** ........................................................................ ៤១
៤.១. គោលការណ៍នៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................................ ៤១
៤.២. លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................................... ៤១
៤.៣. នីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ................................................................ ៤៣
៤.៤. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ............................................................... ៤៤
៤.៤.១. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ ................................ ៤៤
៤.៤.២. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ........................ ៤៤
៤.៤.៣. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការតាមពាក្យសុំរបស់ជនត្រូវចោទ ........................ ៤៥
៤.៥.ទណ្ឌកម្មចំពោះការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ................. ៤៥
៤.៦. ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការដោយដីកាដំណោះស្រាយ ................................... ៤៦
**សេចក្ដីសន្និដ្ឋាន** ..................................................................................................... ៤៧
**អនុសាសន៍** ............................................................................................................ ៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ជាទូទៅនៅក្នុងសង្គមជាតិយើងបច្ចុប្បន្ននេះទាំងរូបវន្តបុគ្គល និងនីតិបុគ្គលតែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយសារការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ គឺមានការផ្សាភ្ជាប់គ្នាទៅនឹងទំនាក់ទំនងជាមួយសង្គមមនុស្សទាំងអស់។ ជាការពិតណាស់ ដើម្បីមានការទាក់ទងគ្នានៅក្នុងសង្គមប្រកបដោយរបៀបរៀបរយល្អ នោះថ្នាក់ដឹកនាំសង្គមជាតិនីមួយៗតែងតែខិតខំព្យាយាមរិះរកនូវគ្រប់គោលនយោបាយ វិធីសាស្ត្រជាច្រើន ដើម្បីប្រមូលថែរក្សា ក៏ដូចជាការពារទប់ស្កាត់នូវអំពើអវិជ្ជមាន អសន្តិសុខ ដែលបានផ្តល់ឱ្យកើតមាននូវការប៉ះពាល់ណាមួយទៅដល់ការរស់នៅ រវាងទំនាក់ទំនាងគ្នានៅក្នុងសង្គម រួមទាំងភាពរៀបរយនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃនៅក្នុងសង្គមជាតិទាំងមូល។ ជាក់ស្តែងនៅក្នុងបណ្តាប្រទេសនីមួយៗ នៅក្នុងសកលលោកនេះពួកគេទាំងអស់នោះតែងតែបង្កើត និងស្វែងរកនូវវិធីសាស្ត្រថ្មីៗ កម្មវិធីនយោបាយ យុទ្ធសាស្ត្រ ដែលជាពិសេសនោះគឺវិធានច្បាប់ផ្សេងៗដែលសម្រាប់ប្រឆាំងទៅនឹងអំពើអវិជ្ជមានដែលប្រព្រឹត្តផ្ទុយពីច្បាប់ ហើយអាចនិយាយបានថាជាបទល្មើសដែលបានកើតមាននៅក្នុងសង្គមរបស់ពួកគេ។ វិធានច្បាប់នេះបានដើរតួយ៉ាងសំខាន់ក្នុងការរៀបចំប្រទេសជាតិឱ្យមានសុខសុវត្ថិភាព សន្តិសុខ និងមានសណ្តាប់ធ្នាប់ល្អ។ តួយ៉ាងនៅក្នុងប្រទេសកម្ពុជាយើងបន្ទាប់ពីសង្គ្រាមផ្ទៃក្នុងដ៏រ៉ាំរ៉ៃត្រូវបានបញ្ចប់មក វិស័យច្បាប់នៅក្នុងប្រទេសកម្ពុជាទទួលបានការរីកចម្រើនលូតលាស់ និងវិវត្តន៍ទៅមុខកាន់តែល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃផងដែរ។ ជាក់ស្តែងនៅក្នុងសង្គមជាតិកម្ពុជា ដើម្បីរក្សាសណ្តាប់ធ្នាប់ អង្គការនីតិបញ្ញត្តិបានបង្កើត និងអនុម័តនូវច្បាប់ជាច្រើនក្នុងការបង្ការការពាររួមទាំងប្រឆាំងទប់ស្កាត់នូវអំពើជាបទល្មើសដែលកើតមាន។ ហើយចំពោះវិធានច្បាប់ដែលមានអានុភាពក្នុងការអនុវត្តទៅលើជីវភាពប្រចាំថ្ងៃនោះ គឺវិធានច្បាប់ព្រហ្មទណ្ឌដែលបានចែងអំពីបទល្មើស និងទោសនៅក្នុងនោះ។ ចំពោះក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១១០៩/០២២ ចុះនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។ ជាងនេះទៅទៀតនោះ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជានេះបានកំណត់នូវគោលការណ៍ទូទៅដើម្បីអនុវត្ត ក៏ដូចជាបានចែងអំពីបទល្មើសជាច្រើនដែលរាប់ចាប់ពីបទលហុបទមជ្ឈិម និងបទឧក្រិដ្ឋ ដែលបានចែកចេញជា ៦គន្ថី និង ៦៧២មាត្រា សុទ្ធសឹងតែបានកំណត់នូវអំពើជាបទល្មើស ដែលតែងតែកើតឡើងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងសង្គម។ ទន្ទឹមនឹងនេះដែរ ដើម្បីមានភាពងាយស្រួលក្នុងការអនុវត្តក្នុងរឿងក្តីព្រហ្មទណ្ឌឱ្យមានប្រសិទ្ធភាពល្អ និងដំណើរការនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌប្រព្រឹត្តទៅដោយរលូននោះ អង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបង្កើតនូវក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវ

បានអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧។[1] គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌគឺដើម្បីកំណត់អំពីវិធានទាំងឡាយណាដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។[2] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនោះយើងសង្កេតឃើញថាមានការតាក់តែងទាក់ទងទៅនឹងនីតិវិធីក្នុងការដោះស្រាយ ក៏ដូចជាការអនុវត្តនៅពេលមានបទល្មើសបានកើតឡើង។ តួយ៉ាងនីតិវិធីព្រហ្មទណ្ឌនេះគឺជាសំណុំវិធានដែលបានគ្រប់គ្រងទៅលើការរៀបចំការប្រព្រឹត្តទៅ និងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌដើម្បីធានានូវប្រសិទ្ធភាពនៃដំណើរនីតិវិធីរបស់តុលាការ រួមទាំងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត នីតិវិធីព្រហ្មទណ្ឌនេះត្រូវបានរៀបចំឡើងសម្រាប់គោលដៅដូចជា ការទាក់ទងទៅដល់ការកំណត់របស់សមត្ថកិច្ច និងការប្រព្រឹត្តិទៅរបស់យុត្តាធិការព្រហ្មទណ្ឌ ដែលយើងហៅថាតុលាការព្រហ្មទណ្ឌ។ ពិសេសជាងនេះនោះគឺ ទាក់ទងទៅនឹងការពិនិត្យទៅបែបបទនៃនីតិវិធី ការចោទប្រកាន់បទល្មើស ការស្រាវជ្រាវបទល្មើស ការស្វែងរកភស្តុតាង ការស៊ើបសួរ ព្រមទាំងនីតិវិធីនៃការជំនុំជម្រះផងដែរ។ ដូចនេះនិយាយជារួមមកគោលបំណងធំបំផុតរបស់នីតិព្រហ្មទណ្ឌគឺធានានូវការបង្ក្រាបដោយមានប្រសិទ្ធភាពផង រួមទាំងធានានូវសិទ្ធិសេរីភាពរបស់បុគ្គលដែលពាក់ព័ន្ធផងដែរ។ ម្យ៉ាងទៀតនោះ ដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ យើងអាចបែងចែកជាបួនដំណាក់កាលទៅតាមលំដាប់លំដោយ ដែលក្នុងនោះមានដូចជា៖ ដំណាក់ការមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលចោទប្រកាន់ដោយព្រះរាជអាជ្ញា ដំណាក់ការស៊ើបសួរដោយចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដោយនៅពេលមានបទល្មើសណាមួយបានកើតឡើងនោះ ត្រូវអនុវត្តតាមដំណាក់កាលទាំងបួននេះ។ យ៉ាងណាមិញ ទោះបីជាដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌសំខាន់ៗខាងលើនេះមានបួនក៏ដោយ ប៉ុន្តែនៅក្នុងបរិបទនៃកិច្ចស្រាវជ្រាវនេះនឹងសិក្សាស្រាវជ្រាវត្រឹមតែដំណាក់កាលស៊ើបសួរ ពោលគឺស្រាវជ្រាវ និងនិយាយអំពីវិធានការមួយដែលចៅក្រមស៊ើបសួរតែងតែប្រើប្រាស់នៅក្នុងដំណាក់កាលស៊ើបសួរ ដើម្បីឱ្យកិច្ចស៊ើបសួរប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព និងរលូនតែប៉ុណ្ណោះ។ ចំពោះវិធាននោះគឺជា **«វិធានការនិរន្តរាយ»** ដែលវិធានការនេះស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ និងស្ថិតនៅក្រោមសមត្ថកិច្ចចៅក្រមស៊ើបសួរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នារយៈពេលកន្លងមកនេះ យើងបានសង្កេតឃើញថា សិស្សនិស្សិត ក៏ដូចជាមន្ត្រីមួយចំនួនតូចនៅក្នុងផ្នែកច្បាប់ពុំទាន់បានជ្រាបច្បាស់អំពីវិធានការនិរន្តរាយ ដែលជាប្រធានបទនេះនៅឡើយទេ ជាមូលហេតុនាំឱ្យការអនុវត្តច្បាប់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះ បានទទួលរងនូវការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលខ្លះផងដែរ។ ដើម្បីឆ្លើយតប ក៏ដូចជាស្រាយចម្ងល់ទៅកាន់ចំណោទបញ្ហានេះឱ្យកាន់តែស៊ីជម្រៅ

[1] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[2] មាត្រា១ កថាខណ្ឌទី១ នៃក្រមព្រទ្ធទណ្ឌព្រះរាជាណាចក្រកម្ពុជា

និងមានអត្ថន័យកាន់តែច្បាស់ រួមទាំងក្បោះក្បាយនោះក្នុងការស្រាវជ្រាវនេះយើងនឹងធ្វើការបកស្រាយអំពីដំណើរកាលនីតិវិធីនៃវិធានការនិរន្តរាយ ដែលវិធានការនេះត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ ដើម្បីឱ្យកិច្ចស៊ើបសួរប្រព្រឹត្តទៅដោយមានប្រសិទ្ធភាពល្អ បន្ទាប់ពីទទួលបានដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។ ដូចនេះហើយ ទើបបានជាមានសំណួរមួយចំនួនបានចោទសួរថា តើអ្វីទៅជាវិធានការនិរន្តរាយ? តើវិធានការនិរន្តរាយមានអ្វីខ្លះ? តើការអនុវត្តវិធានការនិរន្តរាយនៅក្នុងដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ? ហើយដំណើរការនីតិវិធីនៃវិធានការនេះមានអ្វីខ្លះ? តើច្បាប់បានកំណត់អំពីវិធានការនេះយ៉ាងម៉េចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណង ក៏ដូចជាហេតុផលក្នុងការតាក់តែង និងស្រាវជ្រាវប្រធានបទ « **វិធានការនិរន្តរាយ**» នេះ គឺចង់សិក្សាឱ្យច្បាស់អំពីនីតិវិធីនៃអនុវត្តវិធានការនេះ ក៏ដូចជាសិទ្ធិអំណាចដែលចៅក្រមស៊ើបសួរប្រើប្រាស់វិធានការនេះនៅក្នុងដំណាក់កាលស៊ើបសួរ។ ម្យ៉ាងទៀតនោះ គឺដើម្បីបង្កើនចំណេះដឹងអមជាមួយបទពិសោធន៍ខ្លះៗ ដើម្បីចងក្រងជាឯកសារមួយសម្រាប់ជាជំនួយស្មារតីទៅដល់អ្នកសិក្សាស្រាវជ្រាវ ឱ្យស្វែងយល់កាន់តែច្បាស់អំពីវិធានការមួយនេះដែលត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ ដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិយ៉ាងច្បាស់លាស់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ជាការពិតណាស់ ដូចដែលបានដឹងរួចមកហើយថាដំណាក់កាលសំខាន់នៃនីតិវិធីព្រហ្មទណ្ឌមានបួនក៏ដោយនៅក្នុងដែនកំណត់នៃកិច្ចស្រាវជ្រាវនេះ រួមទាំងបរិបទនៃប្រធានបទនៃការស្រាវជ្រាវនេះ គឺយើងខ្ញុំធ្វើការស្រាវជ្រាវត្រឹមតែវិធានការមួយនៅក្នុងដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលជាវិធានការមួយដ៏សំខាន់មួយនៅក្នុងដំណាក់កាលស៊ើបសួរ។ ត្រង់កន្លែងនេះចង់មានន័យថា ការស្រាវស្រាវនេះនឹងនិយាយតែអំពីវិធានការនិរន្តរាយ ក៏ដូចជាសញ្ញាណទូទៅនៃចៅក្រមស៊ើបសួរបន្តិចផងដែរដូចដែលបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈប្រធានបទនៃសារណាស្តីពី «**វិធានការនិរន្តរាយ**» នេះ អាចផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនដែលទាក់ទងនឹងការយល់ដឹងឱ្យកាន់តែច្បាស់ អំពីការអនុវត្តវិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ ពោលគឺទទួលបានចំណេះដឹងដែលទាក់ទងនឹងអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការចេញដីកាផ្សេងៗនៅក្នុងវិធានការនិរន្តរាយ ក៏ដូចជានីតិវិធីនីមួយៗនៃវិធានការនេះ ដែលចៅក្រមស៊ើបសួរតែងតែធ្វើឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដើម្បីធ្វើឱ្យការប្រព្រឹត្តទៅនៃកិច្ចស៊ើបសួរដំណើរការទៅរលូន។ ពិសេស

ជាងនេះទៅទៀតនោះ ប្រធានបទនេះក៏បានបង្កើនចំណេះដឹងផ្នែកច្បាប់ឱ្យកាន់តែល្អប្រសើរ ក៏ដូចជាស្វែងយល់កាន់តែច្បាស់អំពីដែនកំណត់ និងវិសាលភាពនៃវិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ។ ម្យ៉ាងទៀតនោះ ប្រធានបទនេះក៏បានជួយឱ្យទទួលបាននូវចំណេះដឹងទាក់ទងនឹងការអនុវត្តជាក់ស្តែងមួយចំនួនផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

តាមរយៈសារណានេះត្រូវបានរៀបចំឡើងដោយបានប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា ក៏ដូចជាវិភាគយ៉ាងស៊ីជម្រៅ។ ដោយយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ តាមរយៈការប្រមូលយកនូវព័ត៌មានទាំងឡាយក៏ដូចជាឯកសារច្បាប់ផ្សេងៗដែលមានជាប់ពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណាខាងលើនេះ ដើម្បីឱ្យសារណាខាងលើនេះមានភាពត្រឹមត្រូវច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។ អាស្រ័យហេតុនេះ ព័ត៌មានទាំងឡាយដែលយើងខ្ញុំបានជ្រើសរើស និងដកស្រង់ គឺចេញពីប្រភពមួយដែលល្អៗច្បាស់លាស់ ដែលជាការបកស្រាយ និងសរសេរ ក៏ដូចជារៀបរៀងដោយអ្នកដែលមានបទពិសោធន៍នៅក្នុងវិស័យនេះផ្ទាល់ រួមទាំងមតិយោបល់ពីអ្នកជំនាញការខាងនីតិវិធីព្រហ្មទណ្ឌ និងអត្ថបទច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា បន្ថែមជាមួយនឹងឯកសារពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជាកិច្ចបន្តទៀតនោះ ដើម្បីឱ្យយល់កាន់តែច្បាស់នៃប្រធានបទ «**វិធានការនិរន្តរាយ**» នេះ យើងខ្ញុំសូមធ្វើការតាក់តែងរៀបចំខ្លឹមសារនៃសារណានេះ ដោយបែងចែកជា ២ (ពីរ) ជំពូកធំសំខាន់ៗដូចខាងក្រោម៖

- **ជំពូកទី១៖ ចៅក្រមស៊ើបសួរ**
- **ជំពូកទី២៖វិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ**

# ជំពូកទី១
# ចៅក្រមស៊ើបសួរ

# ជំពូកទី១

# ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

ស្ថាប័នតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នដែលបម្រើផលប្រយោជន៍រួមទាំងស្វែងរកយុត្តិធម៌ឱ្យប្រជាជនទៅតាមដែនសមត្ថកិច្ចនីមួយៗ ហើយស្ថាប័នតុលាការបានបែងចែកជា ២ (ពីរ) គឺតុលាការជាន់ខ្ពស់ និងតុលាការជាន់ទាប។ តុលាការជាន់ខ្ពស់រួមមានសាលាឧទ្ធរណ៍តំបន់ និងតុលាការកំពូល។ ចំណែកតុលាការជាន់ទាបរួមមានសាលាដំបូងរាជធានី-ខេត្ត។ ចំពោះដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត អំណាចក្នុងការសម្រេចសេចក្ដីត្រូវបានប្រគល់ឱ្យចៅក្រមអយ្យការ និងចៅក្រមអាសនៈ។ ចៅក្រមអាសនៈត្រូវបានបែងចែងមុខងារជាពីរគឺមានចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។ ក្នុងការបំពេញមុខងារក្នុងដំណាក់កាលស៊ើបសួរចៅក្រមស៊ើបសួរគឺជាអ្នកស្វែងរកការពិត ដោយធ្វើយ៉ាងណាដើម្បីធានាដល់ការចោទប្រកាន់ និងនិរន្តភាពសម្រាប់ដំណើរការជំនុំជម្រះ។

### ១.១ សញ្ញាណគតិយុត្ត

ចៅក្រមស៊ើបសួរ គឺជាបុគ្គលដែលមានឋានៈជាអ្នកស្រាវជ្រាវចំពោះអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿនឱ្យស៊ើបសួររបស់តំណាងអយ្យការ។ ចៅក្រមស៊ើបសួរជាអ្នកអនុវត្ត និងដឹកនាំដោយផ្ទាល់ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធក្នុងការដាក់បន្ទុក ឬដោះបន្ទុកលើជនត្រូវចោទ និងបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការផ្ដើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ។

### ១.២. គោលបំណង

គោលបំណងសំខាន់នៃការបង្កើតចៅក្រមស៊ើបសួរឡើង គឺដើម្បីស្រាវជ្រាវរកភស្តុតាងឱ្យបានគ្រប់គ្រាន់តាមរយៈការស៊ើបសួរ។ ជាធម្មតានៅក្នុងរឿងក្ដីព្រហ្មទណ្ឌការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការសាកសួរនៅក្នុងដំណាក់កាលអយ្យការពុំទាន់អាចប្រមូលបានអង្គហេតុ និងភស្តុតាងគ្រប់ជ្រុងជ្រោយដែលអាចបញ្ជូនជនសង្ស័យទៅជំនុំជម្រះបានឡើយ ពីព្រោះគេចាត់ទុកថាដំណាក់កាលចោទនេះជាដំណាក់កាលបឋម។ ហេតុដូចនេះ ទើបនីតិវិធីច្បាប់តម្រូវឱ្យមានការបើកការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរដែលការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវតែមានភាពយុត្តិធម៌ និងឈរនៅកណ្ដាលគ្រប់ភាគីនៃរឿងក្ដីព្រហ្មទណ្ឌដើម្បីធ្វើយ៉ាងណាស្វែងរកការពិតជូនដល់ជនស្លូតត្រង់ និងធានាដល់ការចោទប្រកាន់ ក៏ដូចជានិរន្តភាពសម្រាប់ដំណើរការជំនុំជម្រះ។

ម្យ៉ាងទៀត នៅក្នុងដំណើរការនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរបុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរជាពិសេស ចៅក្រម មេធាវី ក្រឡាបញ្ជី មន្ត្រីនគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ

អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានមុខជំនាញខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្រ្តត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។[3]

ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[4]

## ផ្នែកទី២៖ សមត្ថកិច្ច

### ២.១. សមត្ថកិច្ចដែនដី

ក្នុងនីតិវិធីនៃការស៊ើបសួរចំពោះចៅក្រមស៊ើបសួរដែលស្ថិតនៅសាលាដំបូងរាជធានី-ខេត្តមានសមត្ថកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួនចំពោះបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តនៅក្នុងដែនដីរបស់ខ្លួន។

តាមបញ្ញត្តិនៃមាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាបានចែងថា៖

ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចគឺ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងសាលាដំបូងខុសៗគ្នា ហើយទទួលបានបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា នោះទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល។ ការសម្រេចនេះបិទផ្លូវតវ៉ា។[5]

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ។ ក្នុងករណីនេះព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ។ ប្រសិនបើការចាំបាច់នៃការស៊ើបសួរតម្រូវនោះចៅក្រមស៊ើបសួរអាច

---

[3] មាត្រា១២១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[4] មាត្រា១២១ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[5] មាត្រា១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជីនៅលើវិសាលភាពដែនដីជាតិទាំងមូល។ ក៏ប៉ុន្តែចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូងនៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ។[6]

ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីប្រតិបត្តិការរបស់ខ្លួននេះ។[7]

**២.២. សមត្ថកិច្ចចងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ចៅក្រមស៊ើបសួរគឺអាចធ្វើការស៊ើបសួរបានលុះត្រាតែព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬតាមរយៈមានពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។

ជាគោលការណ៍រាល់បទល្មើសឧក្រិដ្ឋទាំងអស់ ចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរជាដាច់ខាតទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។

**ផ្នែកទី៣៖ ប្រភពនាំឱ្យមានការស៊ើបសួរ**

**៣.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរគឺជាសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាដែលប្តឹងទៅចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចធ្វើឡើងប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬអញ្ញាតជន (ជនដែលមិនស្គាល់អត្តសញ្ញាណ)។[8]

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។[9] ក្រោយពេលដែលចៅក្រមស៊ើបសួរបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររួចមក ចៅក្រមស៊ើបសួរត្រូវធ្វើការស៊ើបសួរទៅតាមការចង្អុលបង្ហាញរបស់ព្រះរាជអាជ្ញានៅក្នុងដីកា។

**៣.២. ពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍**

ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះ ឬដោយអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ដើម្បីទទួលបានការជួសជុលព្យសនកម្មដែលជនរងគ្រោះទទួលរង។[10]

កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា ហើយការតាំងខ្លួនជាដើមបណ្តឹង

[6] មាត្រា១៣០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[7] មាត្រា១៣០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[8] មាត្រា៤៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[9] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[10] មាត្រា១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋប្បវេណីអាចធ្វើឡើងតាមលិខិតដែលលិខិតនេះត្រូវដាក់បញ្ចូលក្នុងសំណុំរឿង និងអាចធ្វើឡើងដោយផ្ទាល់មាត់ហើយចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។[11]

បន្ទាប់ពីទទួលបានពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹងតាមដីកា ហើយចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា។ ក្រោយពីទទួលបានការបញ្ជូនរបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប៉ុន្តែព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។[12]

[11] មាត្រា១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[12] មាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី២
# វិធានការនិរន្តរាយ
# របស់ចៅក្រមស៊ើបសួរ

# ជំពូកទី២
# វិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ

ដើម្បីធានាឱ្យកិច្ចការស៊ើបសួររបស់ចៅក្រមស៊ើបសួរឱ្យបានល្អ និងមានប្រសិទ្ធភាពនោះគេបានបង្កើតវិធានការមួយឡើងនៅក្នុងកិច្ចស៊ើបសួរគឺ **«វិធានការនិរន្តរាយ»** ដូចដែលបានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៅគន្ថីទី៤ ជំពូកទី៣។ ដូច្នេះក្នុងការបំពេញភារកិច្ចរបស់ចៅក្រមស៊ើបសួរ ដើម្បីស្វែងរកការពិតច្បាប់បានប្រគល់សិទ្ធិអំណាចដែលមានលក្ខណៈចាប់បង្ខំមួយចំនួន ហើយការប្រើប្រាស់សិទ្ធិអំណាចនេះអាចនឹងមានការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃវិធានការនិរន្តរាយ

### ១.១. សញ្ញាណទូទៅនៃវិធានការនិរន្តរាយ

ដោយយោងទៅតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យថា « និរន្តរាយ » គឺមានន័យថា ការដែលគ្មានគ្រោះអន្តរាយ ឬដំណើរដែលគ្មានគ្រោះថ្នាក់ណាមួយ។[13] ចំណែកឯ « វិធានការ » វិញ គឺសំដៅទៅលើបែបបទវិធីចាត់ការ ឬមធ្យោបាយដែលសម្រាប់ការពារប្រុងប្រយ័ត្ន។[14] ដូច្នេះចំពោះវិធានការនិរន្តរាយ គឺចង់សំដៅលើមធ្យោបាយមួយ ឬក៏បែបបទវិធីដែលការពារប្រុងប្រយ័ត្នដែលគ្មានគ្រោះថ្នាក់អន្តរាយណាមួយ។

ងាកមកក្នុងក្រមនីតិវិធីព្រហ្មទណ្ឌវិញ វិធានការនិរន្តរាយនេះ គឺសំដៅទៅលើការចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន[15] ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។ យ៉ាងណាមិញដោយផ្អែកលើមូលដ្ឋានគ្រឹះនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការចាត់ការតាមរយៈវិធានការនិរន្តរាយ ចៅក្រមស៊ើបសួរមានអំណាចប្រើប្រាស់នូវដីកាជាច្រើនទៀតដើម្បីស្តែងឡើងអំពីសកម្មភាពរបស់ខ្លួន។ ទាំងនេះជាគោលការណ៍នៅក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីមានភាពងាយស្រួលក្នុងការស្វែងរកភស្តុតាងពិតប្រាកដសម្រាប់ដាក់បន្ទុក ឬដោះបន្ទុករបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ។

បន្ថែមពីនេះទៅទៀតនោះ វិធានការនិរន្តរាយគឺជាវិធានការមួយដែលចៅក្រមស៊ើបសួរប្រើសម្រាប់ទប់ស្កាត់ពុំឱ្យមានភាពអន្តរាយណាមួយកើតឡើងនៅក្នុងដំណាក់កាលស៊ើបសួរ ដោយវិធានការនេះបានអនុញ្ញាតឱ្យចៅក្រមស៊ើបសួរចេញដីកាសំខាន់ៗ ដើម្បីធ្វើយ៉ាងណាក្នុងការធានាឱ្យមានការស៊ើបសួរដំណើរការទៅមុខរលូនដោយពុំមានឧបសគ្គមករារាំងឡើយ។ ទន្ទឹមនឹងនេះដែរ ដើម្បីស្វែងរកនូវការពិតនៅក្នុងរឿងក្តី ច្បាប់បានប្រគល់

---

[13] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

[14] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

[15] មាត្រា១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ដែលសិទ្ធិអំណាចនេះមានលក្ខណៈចាប់បង្ខំ ព្រមទាំងនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ នៅពេលដែលចៅក្រមស៊ើបសួរបានប្រើប្រាស់នូវវិធានការនិរន្តរាយនេះ។

### ១.២. អានុភាពនៃវិធានការនិរន្តរាយ

ដូចដែលបានរៀបរាប់នៅក្នុងសញ្ញាណទូទៅនៃវិធានការនិរន្តរាយខាងលើនេះ បានបង្ហាញឱ្យឃើញថា វិធានការនេះមានអានុភាពចាប់បង្ខំ និងបំបិទសិទ្ធិសេរីភាពដល់ជនត្រូវចោទដោយត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរឡើយ លុះត្រាតែជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពរឹងទទឹង មិនព្រមចូលខ្លួនមកតាមការកោះហៅរបស់ចៅក្រមស៊ើបសួរ ឬក៏បានរត់គេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណាប៉ុណ្ណោះ។ ហើយអានុភាពនៃវិធានការនិរន្តរាយនេះមានភាពខុសៗគ្នាទៅតាមដីកានីមួយៗដែលត្រូវបានចេញដោយចៅក្រមស៊ើបសួរ។

## ផ្នែកទី២៖ ការចេញដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ

ដីកាគឺបញ្ជាជាលាយល័ក្ខអក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ចដែលបង្គាប់ឱ្យចាត់ការនូវអំពើណាមួយ។ មួយវិញទៀតបញ្ជាដែលបង្គាប់ឱ្យចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ជាការចេញដីកាដោយអង្គការតុលាការ ឬមន្ត្រីរាជការណាមួយ។ ជាទូទៅគេអាចទាញយកទៅតាមអត្ថន័យច្បាប់បានន័យថា ដីកាគឺជាសេចក្ដីសម្រេចរបស់ចៅក្រម ដើម្បីអនុញ្ញាតឱ្យធ្វើការបង្គាប់ក្នុងការធ្វើកិច្ចការអ្វីមួយទៅតាមបញ្ជារបស់ចៅក្រមក្នុងរឿងផ្សេងៗ ឬជាសេចក្ដីបង្គាប់មានជាលាយល័ក្ខអក្សរពីសំណាក់ចៅក្រមម្នាក់។

ចំពោះវិធានការនិរន្តរាយនេះដែរ ចៅក្រមស៊ើបសួរអាចចេញដីកាបានដូចជា៖ ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។[16]

### ២.១. ដីកាបង្គាប់ឱ្យចូលខ្លួន

#### ២.១.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ ឬច្រើននាក់ដើម្បីឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។[17] ជាទូទៅដីកាបង្គាប់ឱ្យចូលខ្លួននេះ អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[18] ពីព្រោះក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ជាពិសេសក្នុងការស្ដាប់ចម្លើយជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាព គឺជាកិច្ចការមួយដែលសំខាន់ដើម្បីទទួលនូវចម្លើយដោយតាមរយៈការសួរចម្លើយជនត្រូវចោទក្នុងការបញ្ជាក់ឱ្យកាន់តែច្បាស់អំពីការពិតនៃអង្គហេតុនីមួយៗ ក៏ដូចជាការស្វែងរកជនដែលពាក់ព័ន្ធដែលជាភស្តុតាងចាំបាច់ដ៏សំខាន់ផងដែរ។ ផ្ទុយមកវិញ ដីកានេះមិនអាចចេញទៅលើសាក្សីបានឡើយ។

---

[16] មាត្រា១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[17] មាត្រា១៨៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[18] មាត្រា១៨៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

បន្ថែមពីនេះទៀត បន្ទាប់ពីពេលចេញដីកានេះហើយ គឺត្រូវជូនដំណឹងដល់ជនណាដែលពាក់ព័ន្ធតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។[19] ស្របពេលដែលការចេញដីកានេះដែរ ចៅក្រមស៊ើបសួរត្រូវតែគោរព និងអនុវត្តទៅតាមលក្ខខណ្ឌមួយចំនួនផងដែរនៅខាងក្រោមនេះ។

**២.១.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យចូលខ្លួន**

ចំពោះកម្មវត្ថុនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួន គឺដើម្បីបញ្ជាឱ្យបុគ្គលដែលត្រូវចោទចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសាកសួរពត៌មាន សួររកចម្លើយ ឬស្តាប់ចម្លើយអំពីរឿងហេតុដែលត្រូវបានពាក់ព័ន្ធទៅនឹងបទល្មើស ដែលត្រូវបានចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញា។

នៅក្នុងចំណាត់ការវិធានការនិរន្តរាយនេះ ដើម្បីឱ្យការស៊ើបសួរស្វែងរកការពិតនៃរឿងមួយដែលប្រព្រឹត្តទៅបានដោយរលូនរបស់ចៅក្រមស៊ើបសួរត្រូវតែមានសហការពីព្រះរាជអាជ្ញា។ ជាទូទៅការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះ គឺធ្វើឡើងស្របពេលដែលចៅក្រមស៊ើបសួរទទួលបានសំណុំរឿងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីសំណាក់ព្រះរាជអាជ្ញា។ កម្មវត្ថុនៃការចេញដីកានេះ គឺដើម្បីបញ្ជាឱ្យបុគ្គលត្រូវចោទចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរសួរធ្វើការសាកសួរពត៌មានស្វែងរកចម្លើយអំពីរឿងហេតុពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ក៏ប៉ុន្តែការចេញដីកាបង្គាប់ឱ្យចូលខ្លួនមិនអាចត្រូវអនុវត្តបានដោយភ្លាមៗឡើយ ទោះបីជាមានសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាក៏ដោយ។ ដោយមូលហេតុមកពីនៅក្នុងសេចក្តីសន្និដ្ឋាននោះបានធ្វើការចោទប្រកាន់ទៅលើបុគ្គលដែលមិនស្គាល់អត្តសញ្ញាណ ឬមានសាវតាជាតិច្បាស់លាស់។ ហេតុដូច្នេះការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះគ្មានប្រសិទ្ធភាព និងមិនអាចធ្វើទៅបានឡើយ។ ហេតុនេះហើយ ចំពោះចំណាត់ការក្នុងការឆ្លើយតបទៅនឹងករណីនេះ ជាដំបូងនោះចៅក្រមស៊ើបសួរធ្វើការស៊ើបសួរស្វែងរកសាវតាជាតិ និងអត្តសញ្ញាណរបស់បុគ្គលនោះជាមុនសិន តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស មុននឹងឈានដល់ការចេញដីកាបង្គាប់ឱ្យចូលខ្លួន។ យ៉ាងណាមិញចៅក្រមស៊ើបអាចចេញដីកាបង្គាប់ឱ្យចូលខ្លួនបានក្នុងករណីដែលមានការស្នើសុំពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌។ ករណីនេះយោងតាមស្ថានភាពជាចាំបាច់នៃវិធានការនិរន្តរាយ។

ទោះបីជាយ៉ាងណា ដីកាបង្គាប់ឱ្យចូលអាចនឹងចេញបានជាច្រើនដងទៅលើបុគ្គលដែលត្រូវចោទម្នាក់ក្នុងករណីដែលបុគ្គលនោះមិនបានធ្វើការចូលមកបង្ហាញខ្លួនតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួននេះដោយត្រូវមានសំអាងហេតុត្រឹមត្រូវសមស្របណាមួយ ដែលអាចឱ្យចៅក្រមស៊ើបសួរទទួលយកបាន។ ក្នុងនោះដែរ មូលហេតុទាំងនោះមានជាអាទិ៍ ជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពនោះ ត្រូវបានជាប់រវល់ក្នុងបេសកម្មការងារ ឬកំពុងព្យាបាលជម្ងឺផ្សេងៗ ឬសុំពន្យារពេលចូលមកបង្ហាញខ្លួនដើម្បីស្វែងរកមេធាវីការពារឱ្យខ្លួនជាដើម។

[19] មាត្រា១៨៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ដោយផ្អែកទៅលើស្ថានភាពខាងលើនេះ ឬស្ថានភាពចាំបាច់ផ្សេងៗទៀតដែលសមស្រប ចៅក្រមស៊ើបសួរអាច អនុញ្ញាតឱ្យជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពនោះ ចូលមកបង្ហាញខ្លួននៅពេលដែលកំណត់ផ្សេង ទៀតតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួននេះដដែល។

លើសពីនេះចំពោះដីកាបង្គាប់ឱ្យចូលខ្លួននេះ ត្រូវចាំបាច់ចុះនិទ្ទេសដែលកំណត់ដូចខាងក្រោម៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមស៊ើបសួរដែលចេញដីកានេះ។[20]

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះ ត្រាផង។[21]

បន្ថែមពីនេះទៀត ដីកាបង្គាប់ឱ្យចូលខ្លួនមិនមានវិធានការចាប់បង្ខំដល់ជនដែលចៅក្រមបានកំណត់ ឈ្មោះនៅក្នុងដីកានោះទេ មានន័យថាជនដែលទទួលដំណឹងនៃដីកានេះរួចហើយ បុគ្គលនោះអាចចូល ឬមិន ចូលបង្ហាញខ្លួននៅចំពោះចៅក្រមស៊ើបសួរក៏បាន។ ប៉ុន្តែទោះបីជាបែបណាក៏ដោយ ដីកាបង្គាប់ឱ្យចូលខ្លួនមិន មានអានុភាពដោយផ្ទាល់ក្នុងការចាប់បង្ខំបុគ្គលនោះឱ្យត្រូវតែចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមក៏ពិតមែន ក៏ ប៉ុន្តែវាមានតម្លៃក្នុងការជម្រុញទៅលើនីតិវិធីបន្ត ក្នុងករណីដែលបុគ្គលនោះបដិសេធមិនព្រមចូលខ្លួនតាមដីកា បង្គាប់ឱ្យចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ។ ចំណាត់ការបន្ត ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន។

### ២.១.៣. ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន

ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួននេះត្រូវបានចេញដោយចៅក្រមស៊ើបសួរ ហើយត្រូវបញ្ជូនទៅដំណឹង ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអាជ្ញាសាលា[22] ដោយក្រឡាបញ្ជើឱ្យដីកាទៅ បុគ្គលទាំងនេះយកដីកាទៅឱ្យប្រគល់ដល់បុគ្គលដែលពាក់ព័ន្ធ។ ហើយជាទូទៅ គឺត្រូវបញ្ជាក់ស្របពេល ដែលមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាដែលមានសមត្ថកិច្ចក្នុងការប្រគល់ដីកានេះដល់បុគ្គលដែលពាក់ព័ន្ធ គឺពួកគាត់ត្រូវបញ្ជាក់ ប្រាប់ទៅបុគ្គលទាំងនោះអំពីកម្មវត្ថុនៃដីកានេះឱ្យទទួលយកចុងដីកា ហើយត្រូវចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃនៅលើដើមដីកានោះផងដែរ រួចបង្វិលមកជូនចៅក្រមស៊ើបសួរវិញ។[23] ប្រសិនបើបុគ្គលដែល ត្រូវទទួលយកដីកាមិនព្រមទទួលយកដីកានេះ គឺត្រូវបញ្ជាក់អំពីមូលហេតុនៃការមិនព្រមទទួលយកដីកានោះ

[20] មាត្រា១៨៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[21] មាត្រា១៨៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[22] មាត្រា១៨៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[23] មាត្រា១៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ហើយមន្ត្រីដែលមានសមត្ថកិច្ចត្រូវចារលើដីកានោះផងដែរ ដោយបញ្ជាក់អំពីមូលហេតុនៃការដែលពុំព្រមទទួលយកដីកានោះ។ បន្ទាប់មក មន្ត្រីមានសមត្ថកិច្ចត្រូវបញ្ជូនដីកានេះភ្លាមត្រឡប់មកជូនចៅក្រមស៊ើបសួរវិញឱ្យរហ័សតាមពេលវេលាដែលអាចធ្វើទៅបាន។

ម្យ៉ាងទៀត ប្រសិនបើមន្ត្រីមានសមត្ថកិច្ចដែលទទួលបន្ទុកក្នុងការជូនដំណឹង និងប្រគល់ដីកាបង្គាប់ឱ្យចូលខ្លួននេះដល់បុគ្គលដែលពាក់ព័ន្ធ បានជួបនូវការលំបាកក្នុងការអនុវត្តនូវបេសកម្មរបស់ខ្លួន មន្ត្រីដែលមានសមត្ថកិច្ចនោះត្រូវជូនដំណឹងអំពីការលំបាកនោះភ្លាមដល់ចៅក្រមស៊ើបសួរ។[24] លើសពីនេះ ចំពោះបុគ្គលដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួននោះមិនព្រមចូល ឬបដិសេធក្នុងការចូលខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ នោះចៅក្រមស៊ើបសួរនឹងធ្វើការចេញនូវដីកាបង្គាប់ឱ្យនាំខ្លួន។

ទោះបីជាយ៉ាងណា សូមបញ្ជាក់ផងដែរថា នៅក្នុងក្របខណ្ឌនៃការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួននេះ មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចត្រឹមតែយកដីកាបង្គាប់ឱ្យចូលខ្លួននេះទៅប្រគល់ឱ្យបុគ្គលដែលត្រូវបង្គាប់ឱ្យចូលខ្លួនតែប៉ុណ្ណោះ ដោយមិនមានអំណាចចាប់បង្ខំឱ្យនាំខ្លួន ឬចាប់ខ្លួនបុគ្គលនោះបញ្ជូនមកចៅក្រមស៊ើបសួរឡើយ។

### ២.១.៤. អានុភាពនៃដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូល គឺមិនមានអានុភាពចាប់បង្ខំដូចជាការចាប់ខ្លួន ឬនាំខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ទៅលើបុគ្គលដែលជាកម្មវត្ថុនៃដីកា (ជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាព) មកចំពោះមុខចៅក្រមស៊ើបសួរទេ។ នៅពេលដែលបុគ្គលទាំងនោះទទួលបានដីកានេះរួចហើយ ពួកគាត់ទាំងនោះអាចចូល ឬមិនចូលបង្ហាញខ្លួននៅចំពោះចៅក្រមស៊ើបសួរបាន ពោលគឺដីកាបង្គាប់ឱ្យចូលខ្លួននេះពុំមានអានុភាពចាប់បង្ខំឡើយ។

ទោះបីជាដីកាបង្គាប់ឱ្យចូលខ្លួននេះមិនមានអានុភាពដោយផ្ទាល់ក្នុងការចាប់បង្ខំឱ្យបុគ្គលដែលជាកម្មវត្ថុនៃដីកានោះឱ្យត្រូវតែចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរយ៉ាងណាក៏ដោយ ក៏ប៉ុន្តែវានឹងមានតម្លៃជាការជម្រុញទៅលើនីតិវិធីបន្ត ក្នុងករណីដែលបុគ្គលនោះបដិសេធក្នុងការចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវច្បាស់លាស់។ ចំណាត់ការជាបន្តនោះបន្ទាប់ពីបុគ្គលដែលជាជនត្រូវចោទបដិសេធមិនព្រមចូលមកបង្ហាញខ្លួនតាមការបង្គាប់ឱ្យចូលខ្លួន ដូចនេះនាំឱ្យចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនបន្ថែមទៅលើដីកាបង្គាប់ឱ្យចូលខ្លួន។

ចំពោះការបដិសេធមិនព្រមចូលខ្លួនរបស់បុគ្គលដែលជាជនត្រូវចោទ ដោយមានមូលហេតុត្រឹមត្រូវច្បាស់លាស់ឆ្លើយតបមកចំពោះចៅក្រមស៊ើបសួរវិញ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យពន្យារពេលនៃការចូលខ្លួន

[24] មាត្រា១៨៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ដល់បុគ្គលនោះបានផងដែរ។ ម្យ៉ាងទៀតនោះ ដីកាបង្គាប់ឱ្យចូលខ្លួនមិនមានអានុភាពធំធេងដូចដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួននោះទេ។

### ២.២. ដីកាបង្គាប់ឱ្យនាំខ្លួន

#### ២.២.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យនាំខ្លួន

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅជួបនៅចំពោះមុខចៅក្រមស៊ើបសួរ។[25] ហើយចៅក្រមស៊ើបសួរមានអំណាចចេញនូវដីកាបង្គាប់ឱ្យនាំខ្លួន។[26] ក្នុងន័យនេះការចេញដីកា គឺជាករណីចាំបាច់ដើម្បីបង្ខំឱ្យជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពឱ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរតាមរយៈការប្រើប្រាស់កម្លាំងសាធារណៈឱ្យចាប់បង្ខំនាំយកបុគ្គលនោះមកបង្ហាញខ្លួន។ ម្យ៉ាងទៀតនោះ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនទៅកាន់សាក្សីបាននោះទេ ទោះបីជាសាក្សីនោះរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួនតាមការកោះហៅពីសំណាក់ចៅក្រមស៊ើបសួរក៏ដោយ។ ក៏ប៉ុន្តែ ទោះបីជាមានការបញ្ញត្តិបែបនេះក៏ដោយ ពុំមានន័យថាចៅក្រមស៊ើបសួរមិនមានអំណាចក្នុងការចាប់បង្ខំសាក្សីឱ្យមកចូលខ្លួននៅពេលដែលសាក្សីរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួននោះឡើយ។ ជាក់ស្តែងចៅក្រមស៊ើបសួរអាចចាប់បង្ខំសាក្សីឱ្យមកចូលខ្លួនបានតាមរយៈការស្នើសុំទៅកងកម្លាំងសាធារណៈ ដើម្បីបង្ខំសាក្សីដែលរឹងទទឹងឱ្យមកបង្ហាញខ្លួនបាន។[27]

#### ២.២.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។[28] ជាទូទៅការចេញដីកាបង្គាប់ឱ្យនាំខ្លួននេះគឺត្រូវបានធ្វើឡើងបន្ទាប់ពីចំណាត់ការនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួនលែងមានប្រសិទ្ធភាពតទៅទៀត ឬលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួនជាលក្ខខណ្ឌជាចាំបាច់ក្នុងការដើរតួនាទីជំនួសឱ្យដីកាបង្គាប់ឱ្យចូលខ្លួន។ ជាធម្មតាដីកាបង្គាប់ឱ្យនាំខ្លួនតែងតែដើរតួនាទីតាមក្រោយដីកាបង្គាប់ឱ្យចូលខ្លួន។ ក៏ប៉ុន្តែ ក៏មានករណីពិសេសដែលធ្វើឱ្យដីកាបង្គាប់ឱ្យនាំខ្លួនអាចដើរតួនាទីជំនួសឱ្យដីកាបង្គាប់ឱ្យចូលខ្លួនបានផងដែរ ជាក់ស្តែងប្រសិនបើត្រូវចោទមិនបានចូលខ្លួនតាមដីកាបង្គាប់ឱ្យចូលខ្លួនទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទបាន ករណីដែលជនត្រូវចោទមិនបានរត់គេចទៅទីណានោះ។ ចំណុចនេះមានន័យថា ជនត្រូវចោទកំពុងតែរស់នៅជាធម្មតានៅមូលដ្ឋានដោយគ្មានការរត់គេចខ្លួន

[25] មាត្រា១៩០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[26] មាត្រា១៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[27] មាត្រា១៥៣ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[28] មាត្រា១៩០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

នោះចៅក្រមស៊ើបអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទនោះតែម្ដង។ ម្យ៉ាងវិញទៀត ប្រសិនបើក្នុងករណីចៅក្រមស៊ើបយល់ឃើញថា ការចេញដីកាបង្គាប់ឱ្យចូលខ្លួនទៅកាន់ជនត្រូវចោទពីបទមជ្ឈិម ឬបទឧក្រិដ្ឋធ្វើឱ្យជនត្រូវចោទមានបំណងរត់គេចខ្លួននោះ ចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាបង្គាប់ឱ្យនាំខ្លួនតែម្ដង។ ផ្ទុយមកវិញនោះដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចចេញទៅលើបទលហុបាននោះទេ។ មួយវិញទៀតនោះ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនដែលមានអានុភាពដើម្បីធ្វើការនាំខ្លួនជន នោះមកស៊ើបសួរក្នុងការស្វែងរកការពិតដោយសារតែជនត្រូវចោទនៅតែរឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួនចំពោះមុខតុលាការជាដាច់ខាតនៅពេលដែលចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនរួចហើយ។

យ៉ាងណាមិញ ក៏នៅមានចំណុចនៃនីតិវិធីដែលគួរឱ្យកត់ចំណាំផងដែរថា ប្រសិនបើចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនរួចហើយ ស្រាប់តែជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពបានរត់គេចខ្លួនបាត់ដោយពុំព្រមចូលមកបង្ហាញខ្លួន និងដោយមានចំណារពីមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌បានបញ្ជាក់ថាបុគ្គលដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចូលខ្លួននោះបានរត់គេចខ្លួនបាត់នោះ បន្ទាប់ពីបុគ្គលនោះបានទទួលដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួននោះ ដោយយោងតាមស្ថានភាពចាំបាច់ខាងលើនេះ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជំនួសឱ្យការចេញដីកាបង្គាប់ឱ្យនាំខ្លួនតែម្ដង។ ជាងនេះទៅទៀតនោះ តាមរយៈដីកាបង្គាប់ឱ្យនាំខ្លួន ក៏ដូចជាដីកាបង្គាប់ឱ្យចាប់ខ្លួនបានបង្ហាញឱ្យយើងឃើញថាដីកាទាំងពីរនេះសុទ្ធសឹងតែបានបញ្ជាឱ្យកងកម្លាំងសាធារណៈឱ្យធ្វើការចាប់ និងនាំខ្លួនជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពបានដូចគ្នា។[29] ទោះបីជាយ៉ាងណា ស្របតាមស្មារតីនៃមាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ដែរថា ដីកាបង្គាប់ឱ្យចាប់ខ្លួនគឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[30] ត្រង់ចំណុចនៃឃ្លានេះ គឺមិនត្រូវបានចែងនៅក្នុងលក្ខខណ្ឌនៃការអនុវត្តនៃដីកាបង្គាប់ឱ្យនាំខ្លួនឡើយ។ ហេតុនេះហើយនាំឱ្យយើងទាញរកលក្ខខណ្ឌខុសគ្នារវាងដីកាទាំងពីរនេះបានគឺថា ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានយកទៅប្រើប្រាស់នៅក្នុងស្ថានភាពដែលចៅក្រមស៊ើបសួរបានដឹងច្បាស់ពីទីកន្លែងស្នាក់នៅរបស់ជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពច្បាស់លាស់។ ចំណែកឯដីកាបង្គាប់ឱ្យចាប់ខ្លួនគឺត្រូវបានយកទៅប្រើប្រាស់ទៅលើស្ថានភាពដែលជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពបានរត់គេចខ្លួន ឬនៅពេលដែលចៅក្រមស៊ើបសួរពុំបានដឹងច្បាស់ពីទីកន្លែងស្នាក់នៅពិតប្រាកដរបស់ជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធភាពនោះ។[31]

[29] មាត្រា១៩០ កថាខណ្ឌទី១ និងមាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[30] មាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[31] មាត្រា១៩៦ កថាខណ្ឌទី២ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ដើម្បីឱ្យដីកាបង្គាប់ឱ្យនាំខ្លួនមានអានុភាពនោះ ត្រូវចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។[32]

ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[33]

ដីកាបង្គាប់ឱ្យនាំខ្លួននេះត្រូវតែចុះកាលបរិច្ឆេទ និងនិទ្ទេស ដូចដែលបានចង្អុលបង្ហាញខាងលើទើបដីកានេះមានប្រសិទ្ធភាព និងមានអានុភាពត្រឹមត្រូវតាមច្បាប់។

**២.២.៣. ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន**

ចំពោះដីកាបង្គាប់ឱ្យនាំខ្លួន គឺត្រូវប្រគល់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកទទួលបន្ទុកក្នុងការអនុវត្ត។[34] ប្រសិនបើជាការចាំបាច់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមរយៈគ្រប់មធ្យោបាយ[35] ដូចជាព័ត៌មានកាសែត វិទ្យុ ទូរទស្សន៍ ឬប្រព័ន្ធអ៊ីនធើណេតអេឡិចត្រូនិច ដែលជាបណ្តាញសង្គមជាអាទិ៍។ ដីកាបង្គាប់ឱ្យនាំខ្លួនអាចជាកម្មវត្ថុក្នុងការផ្សព្វផ្សាយលើវិសាលភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ការផ្សព្វផ្សាយបែបនេះគឺចំពោះភាពបន្ទាន់នៃការអនុវត្តដីកាដើម្បីបង្ការឱ្យជនត្រូវចោទកុំឱ្យព្យាយាមរត់គេចខ្លួនចេញពីដែនដីកម្ពុជា។ ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកក្នុងការអនុវត្តដីកានោះតាមរយៈក្រឡាបញ្ជី។[36] ចំពោះដីកាត្រូវមានបោះត្រាក្របាមដែលមិនមែនជាសន្លឹកថតចម្លង។ មិនថាស្ថិតក្នុងកាលៈទេសៈបែបណាទេ គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពសិទ្ធិលំនៅឋានបើទោះបីជាស្ថិតក្នុងលក្ខខណ្ឌបន្ទាន់ក្នុងការអនុវត្តដីកាយ៉ាងណាក៏ដោយ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅនាំខ្លួនជនត្រូវចោទមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចជាដាច់ខាត។[37]ម្យ៉ាងវិញទៀតនោះ ប្រសិនបើស្ថិតនៅក្នុងបេសកម្មនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជួបនូវការលំបាកផ្សេងៗណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងស្តីអំពីការលំបាករបស់ខ្លួនទៅកាន់ចៅក្រមស៊ើបសួរ។[38] ក្រោយពីធ្វើការនាំខ្លួនជនដែលជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធបានហើយ មន្ត្រី

[32] មាត្រា១៩១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[33] មាត្រា១៩១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[34] មាត្រា១៩២ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[35] មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[36] មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[37] មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[38] មាត្រា១៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

នគរបាលយុត្តិធម៌ត្រូវតែនាំជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយ ឬស្តាប់ចម្លើយដែលពាក់ព័ន្ធ។ ប្រសិនបើមានកាលៈទេសៈណាមួយដែលជាហេតុនាំឱ្យមន្ត្រីនគរបាលយុត្តិធម៌មិនអាចនាំខ្លួនបុគ្គលដែលជាប់ពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនោះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ[39] ហើយបុគ្គលត្រូវចោទនោះត្រូវនាំខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួស។[40] ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេបុគ្គលដែលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។[41] កន្លែងនេះចង់បញ្ជាក់ថាថិរវេលានៃការឃាត់ខ្លួន (ឃុំខ្លួន) ជនណាម្នាក់មិនអាចលើសពី ៤៨ម៉ោងនោះទេ។ កាលណាបុគ្គលត្រូវចោទ ឬបុគ្គលដែលជាប់ពាក់ព័ន្ធ ត្រូវបាននាំខ្លួនដល់ចៅក្រមស៊ើបសួររួចមកហើយក៏ដោយ ដោយស្ថិតនៅក្នុងជម្រើសរបស់ខ្លួនចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួន ឬមិនឃុំខ្លួនទៅលើបុគ្គលនោះ។ ដោយយោងតាមការអនុវត្តជាក់ស្តែង ចៅក្រមស៊ើបសួរតែងតែសម្រេចធ្វើការឃុំខ្លួនក្នុងករណីបទល្មើសដែលបានចោទប្រកាន់ទៅលើបុគ្គលនោះ ជាប្រភេទបទល្មើសធ្ងន់ធ្ងរដែលជាបទឧក្រិដ្ឋ ឬអាស្រ័យទៅលើបុគ្គលិកលក្ខណៈនៃបុគ្គលនោះផ្ទាល់តែម្តង។ រីឯចំពោះថិរវេលានៃការឃុំខ្លួនបុគ្គលត្រូវចោទ ឬបុគ្គលដែលពាក់ព័ន្ធណាម្នាក់តាមរយៈដីកាបង្គាប់ឱ្យនាំខ្លួននោះ គឺត្រូវតែរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន។[42]

បន្ថែមពីនេះទៅទៀតនោះ នៅក្នុងស្ថានភាពខ្លះលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួនមិនត្រូវធ្វើឡើងបានឡើយ ដោយមូលហេតុថាបុគ្គលត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពនោះបានរត់គេចខ្លួនបាត់ដែលនាំឱ្យនីតិវិធីនៃការនាំខ្លួនបុគ្គលទាំងនោះជួបការលំបាក។ ហេតុនេះហើយ ជាការជំនួសឱ្យដីកាបង្គាប់ឱ្យនាំខ្លួនដែលមានលក្ខខណ្ឌអនុវត្តបានតែក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបុគ្គលទាំងនោះបានតែម្តង ដោយមិនចាំបាច់ចេញដីកាបង្គាប់ឱ្យនាំខ្លួនទៀតនោះទេ។

### ២.២.៤. អានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួនមានអានុភាពបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ឱ្យទៅចំពោះមុខចៅក្រមស៊ើបសួរ។[43] ដូចច្នេះដីកានេះគឺជា ប្រភេទដីកាដែលមានអានុភាពចាប់បង្ខំទៅលើបុគ្គលទាំងនោះ។ មួយវិញទៀតនោះ ប្រសិនបើមានមូលហេតុនៃកាលៈទេសៈណាមួយ បន្ទាប់ពីការឃាត់ខ្លួនមិនអាច

[39] មាត្រា១៩៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[40] មាត្រា១៩៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[41] មាត្រា១៩៣ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[42] មាត្រា១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[43] មាត្រា១៩០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

បញ្ជូនខ្លួនទាន់ពេលវេលាមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិរក្សាទុកជនត្រូវចោទបាន[44] ទោះបីជាយ៉ាងណា មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំខ្លួនជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ក្រោយពីពេលឃាត់ខ្លួន។[45] ម្យ៉ាងទៀតនោះ បើសិនជាមន្ត្រីនគរបាលយុត្តិធម៌មិនអាចនាំខ្លួនជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពនៅថ្ងៃបន្ទាប់ទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែដោះលែងជននោះឱ្យមានសេរីភាពឡើងវិញ។[46] ត្រង់ចំណុចនេះ គឺមានន័យថាចិរវេលានៃការឃាត់ខ្លួនតាមរយៈអានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចឃុំខ្លួនជននោះត្រឹម ៤៨ម៉ោងតែប៉ុណ្ណោះ ដោយមិនអាចលើសពី ៤៨ម៉ោងឡើយ ហើយចិរវេលានេះត្រូវគិតចាប់ពីដែលជននោះត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។[47]

ជាងនេះទៅទៀតនោះ នៅក្នុងកិច្ចអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននេះអាចមានអានុភាពជាកម្មវត្ថុចំពោះការយកទៅផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទៅលើដែនដីវិសាលភាពនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ប៉ុន្តែដីកាបង្គាប់ឱ្យនាំខ្លួននេះ គឺមិនមានអានុភាពទូលំទូលាយជាកម្មវត្ថុក្នុងការផ្សព្វផ្សាយជាអន្តរជាតិដូចទៅនឹងដីកាបង្គាប់ឱ្យចាប់ខ្លួនឡើយ។

## ២.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន

### ២.៣.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវបានចេញដោយចៅក្រមស៊ើបសួរ[48] និងជាបញ្ជារបស់ចៅក្រមស៊ើបសួរបង្គាប់ឱ្យកងកម្លាំងសាធារណៈទាំងអស់ស្រាវជ្រាវរក ចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលដែលជាប់ពាក់ព័ន្ធដែលមានតម្រុយពិរុទ្ធភាព ដើម្បីនាំខ្លួនជននោះទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ[49] ចំពោះជនណាដែលបានរត់គេចខ្លួនដោយមិនដឹងស្ថិតនៅទីកន្លែងណា។ ទោះបីជាដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវបានចេញដោយចៅក្រមស៊ើបសួរក៏ពិតមែន ប៉ុន្តែដើម្បីធានាប្រសិទ្ធភាពក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឱ្យមុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹង ឬទទួលយោបល់ពីព្រះរាជអាជ្ញាក្នុងដីកានេះជាមុនសិន ដោយមានចែងពីមូលហេតុក្រោយពីទទួលបានយោបល់ពីព្រះរាជអាជ្ញា។ ម្យ៉ាងទៀតនោះ ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺធ្វើឡើងដោយមានការកំណត់និទ្ទេស និងមានចុះកាលបរិច្ឆេទ រួមទាំងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។[50]

---

[44] មាត្រា១៩៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[45] មាត្រា១៩៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[46] មាត្រា១៩៣ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[47] មាត្រា៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[48] មាត្រា១៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[49] មាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[50] មាត្រា១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ២.៣.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។[51] ចៅក្រមស៊ើបសួរ នឹងអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះបានលុះត្រាតែះ

- បទល្មើសដែលចោទប្រកាន់ គឺជាប្រភេទបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។[52]
- បុគ្គលដែលជាប់ពាក់ព័ន្ធបានរត់គេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[53]

យ៉ាងណាមិញ លក្ខខណ្ឌដែលបានកំណត់ខាងលើនេះ គឺជាលក្ខខណ្ឌជាចាំបាច់ដែលត្រូវតែគោរពតាម ដោយហេតុថា ការដែលមិនគោរពនូវវិធានការខាងលើនេះអាចនាំឱ្យមោឃភាពនៃនីតិវិធី។

ទន្ទឹមនឹងនេះដែរ ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺធ្វើឡើងដោយមានការកំណត់និទ្ទេស និងមានកាលបរិច្ឆេទត្រឹមត្រូវ។ សម្រាប់និទ្ទេសដែលត្រូវចុះសម្រាប់ដីកានេះមានដូចតទៅ ៖

- កំណត់អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- កំណត់បទល្មើសដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស
- កំណត់ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។[54]

ការដែលមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីនិទ្ទេសសំខាន់ខាងលើនេះនៅក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួននោះទេ វានឹងនាំឱ្យដីកានេះពុំមានអានុភាព ឬតម្លៃគតិយុត្តដែលអាចឱ្យទទួលយកបានទៅអនុវត្តដីកានេះបានទេ។ ម្យ៉ាងទៀតនោះ គឺដើម្បីចៀសវាងអំពីការមោឃភាពនៃដីកានេះ។

ហើយចំពោះដីកានេះ គឺជាបញ្ជារបស់ចៅក្រមស៊ើបសួរបញ្ជាឱ្យកងកម្លាំងសាធារណៈស្រាវជ្រាវស្វែងរកជនត្រូវចោទ ឬជនដែលមានការជាប់ពាក់ព័ន្ធ ឬជនដែលមានតម្រុយពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរក្នុងការសាកសួរយកចម្លើយ និងស្តាប់ចម្លើយដែលជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។

---

[51] មាត្រា១៩៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[52] មាត្រា១៩៦ កថាខណ្ឌទី២ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[53] មាត្រា១៩៦ កថាខណ្ឌទី២ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[54] មាត្រា១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ជាការពិតណាស់ ទោះបីជាដីកាបានបំពេញតាមលក្ខខណ្ឌខាងលើក៏ពិតមែន ប៉ុន្តែដីកានេះមិនអាចធ្វើការចេញភ្លាមៗបានទេ គឺចៅក្រមស៊ើបសួរត្រូវជូនដំណឹង ឬសុំយោបល់ពីព្រះរាជអាជ្ញា[55] ហើយចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានថែងអំពីមូលហេតុ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា។[56] ហើយចំពោះហេតុផលនៃការសុំយោបល់ពីព្រះរាជអាជ្ញានោះ ក៏ព្រោះដោយយោងលើហេតុផលក្នុងនាមជាព្រះរាជអាជ្ញាដែលជាម្ចាស់នៃបណ្តឹងអាជ្ញា និងជាអ្នកទទួលបន្ទុកអនុវត្ត រួមទាំងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន[57] ផ្ទាល់តែម្តង។ ការជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការស្នើសុំឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ ត្រូវធ្វើឡើងដោយតាមរយៈ **"ដីកាបញ្ជូនឱ្យឆ្លើយ"**។ ចំពោះយោបល់នៃការឆ្លើយតបទៅលើការចាប់ខ្លួនទៅលើជនដែលពាក់ព័ន្ធរបស់ព្រះរាជអាជ្ញាគឺមិនអាចជាកាតព្វកិច្ចដែលចៅក្រមស៊ើបសួរត្រូវអនុវត្តតាមនោះទេ មានន័យថាចៅក្រមស៊ើបសួរមានសិទ្ធិឯករាជ្យពេញលេញក្នុងការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទៅលើជនត្រូវចោទបានដោយមានមូលហេតុបូករួមសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ។

សរុបមកដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាវិធានការបង្ខំដោយចៅក្រមស៊ើបសួរចេញដីកានេះ ដើម្បីឱ្យមន្ត្រីអនុវត្តច្បាប់ចាប់ខ្លួនជនត្រូវចោទក្នុងការយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ការចេញដីកានេះត្រូវផ្អែកលើស្ថានភាពមួយចំនួន គឺករណីដែលបទល្មើសត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលជាបទល្មើសត្រូវដាក់ពន្ធនាគារ និងករណីដែលជនត្រូវចោទ ឬជនដែលពាក់ព័ន្ធបានរត់គេចដោយមិនដឹងស្ថិតនៅទីកន្លែងណា។[58]

### ២.៣.៣. ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌។[59] ហេតុដូចនេះហើយដីកានេះត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកក្នុងការអនុវត្តដីកានេះ។[60] ជាងនេះទៅទៀតនោះ នៅក្នុងករណីបន្ទាន់ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថទៅតាមគ្រប់មធ្យោបាយ(ការសែត ទូរទស្សន៍ វិទ្យុ ឬតាមប្រព័ន្ធអ៊ីនធឺណេតជាដើម)។[61]

---

[55] មាត្រា១៩៧ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[56] មាត្រា១៩៧ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[57] មាត្រា១៩៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[58] មាត្រា១៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[59] មាត្រា១៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[60] មាត្រា១៩៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[61] មាត្រា១៩៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ពិសេសជាងនេះទៅទៀត សម្រាប់ដីកាបង្គាប់ឱ្យចាប់ខ្លួននេះមិនត្រឹមតែអាចជាកម្មវត្ថុក្នុងការផ្សព្វផ្សាយជាសាធារណៈនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ នៅក្នុងករណីចាំបាច់ណាមួយនោះដីកានេះអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ដោយប្រើនូវយន្តការនានាដែលមានប្រសិទ្ធភាព។[62] ត្រង់ចំណុចនេះបានសបញ្ជាក់ឱ្យឃើញថា ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួននេះ គឺអាចធ្វើឡើងលើដែនដីវិសាលភាពជាអន្តរជាតិបាន។ តាមរយៈនៃការអនុវត្តដីកានេះ គឺតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាត្រូវចូលរួមសហការជាមួយប៉ូលីសអន្តរជាតិ (ប៉ូលីសអង់ទែរប៉ុល Police Interpol) ដែលមានសមត្ថកិច្ចដើម្បីស្រាវជ្រាវស្វែងរកចាប់ខ្លួនជនត្រូវចោទដែលបានរត់គេចខ្លួនឆ្លងប្រទេសនោះ។ បន្ទាប់មកនោះ នៅក្នុងករណីដែលចាប់ខ្លួនជនដែលជាកម្មវត្ថុនៃដីកានោះបានហើយ មន្ត្រីនគរបាលយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាត្រូវតែនាំខ្លួនជននោះមកចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលខ្លីបំផុតដើម្បីសាកសួរចម្លើយស្វែងរកការពិត ប្រសិនបើស្ថិតនៅដំណាក់កាលស៊ើបសួរនៅឡើយ។[63] នៅក្រោយពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានសិទ្ធិក្នុងការចាប់ខ្លួនជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធទាំងឡាយតាមរយៈដីកាបង្គាប់ឱ្យចាប់ខ្លួននេះហើយ មន្ត្រីនគរបាលយុត្តិធម៌អាចចូលចាប់ខ្លួនជនដែលមានអត្តសញ្ញាណដូចនៅក្នុងដីកាដែលបានកំណត់បានគ្រប់ពេលវេលា។ ទោះបីជាដីកានេះមានអានុភាពយ៉ាងណាក៏ដោយ ចំពោះអភ័យឯកសិទ្ធិនៃលំនៅឋានត្រូវតែគោរព។ ត្រង់ចំណុចនេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលក្នុងលំនៅឋានរបស់របស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។[64] មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកម្មរបស់ខ្លួន។[65]

ម្យ៉ាងទៀត ដីកាបង្គាប់ឱ្យចាប់ខ្លួននេះ ក៏ជាលិខិតមួយបញ្ជាក់ឱ្យឃុំខ្លួនស្របច្បាប់របស់ចៅក្រមស៊ើបសួរ ឬអាជ្ញាធរតុលាការផងដែរ។[66] ដោយហេតុដូច្នេះហើយ ប្រសិនបើជនត្រូវចោទ ឬជនដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួននោះ មិនត្រូវបានបញ្ជូនខ្លួនភ្លាមៗតាមការកំណត់នោះទេ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទនោះជាបណ្ដោះអាសន្នសិន។[67] ហើយក៏តម្រូវឱ្យប្រធានពន្ធនាគារ និងមណ្ឌលឃុំខ្លួនរក្សាទុក ដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម។[68]

---

[62] មាត្រា២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[63] មាត្រា២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[64] មាត្រា១៩៩ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[65] មាត្រា១៩៩ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[66] មាត្រា១៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[67] មាត្រា២០១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[68] មាត្រា២០១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

លើសពីនេះទៅទៀតនោះ ជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញា ប្រសិនបើមានការនាំខ្លួនទៅបង្ហាញនេះតម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវបានចាត់ចែងដោយព្រះរាជអាជ្ញា។[69]

បន្ថែមពីនេះទៀតនោះ ប្រសិនបើជនដែលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួននោះទេ ព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនត្រូវទទួលភារកិច្ចស្តាប់ចម្លើយជននោះ។[70] ហើយព្រះរាជអាជ្ញានោះជាអ្នកធ្វើកំណត់ហេតុស្តីពីកាស្តាប់ចម្លើយជននោះ រួចហើយបញ្ជូនទៅឱ្យចៅក្រមស៊ើបសួរដែលទទួលបន្ទុកក្នុងការស៊ើបសួរទៅលើសំណុំរឿងនេះ។

នីតិវិធីដែលគួរឱ្យកត់សម្គាល់ផងដែរថា នៅពេលខ្លះជនដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួននោះអាចនឹងមិនបានបញ្ជូនឱ្យទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនោះទេ។ ត្រង់ចំណុចនេះមានមូលហេតុថានៅពេលដែលចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនហើយ បន្ទាប់មកគាត់បានសម្រេចបិទបញ្ចប់ការស៊ើបសួររបស់គាត់ ដោយបានបញ្ជូនសំណុំរឿងនោះទៅជំនុំជម្រះដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់យុត្តាធិការជំនុំជម្រះ (ចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះ)។ នៅក្នុងករណីនេះ ជននោះត្រូវតែបញ្ជូនខ្លួនឱ្យទៅចំពោះមុខចៅក្រមជំនុំជម្រះ ដើម្បីបើកសវនាការជំនុំជម្រះមុនអង្គសេចក្តី[71] ជំនុំជម្រះសម្រេចអំពីរឿងឃុំខ្លួន ឬមិនឃុំខ្លួនជននោះប្រសិនបើពុំទាន់ដល់ការកំណត់នៃសវនាការអង្គសេចក្តី[72]។

ទន្ទឹមនឹងនេះដែរ ជនណាដែលត្រូវបានចាប់ខ្លួនតាមរយៈនៃការអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន។[73]

### ២.៣.៤. អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរមានអានុភាពបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរ។[74] យ៉ាង

[69] មាត្រា២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[70] មាត្រា២០១ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[71] «ជំនុំជម្រះមុនអង្គសេចក្តី»សម្តៅដល់ការគោរពតាមគោលការណ៍សន្មតជាមុនថាគ្មានទោសដែលតាមន័យនេះអាចបញ្ជាក់បានថាជនម្នាក់ត្រូវចាត់ទុកថាមានទោស លុះត្រាតែជននោះឆ្លងកាត់នីតិវិធីជំនុំជម្រះហើយប្រកាសថាមានទោសតាមរយៈសាលក្រម ឬសាលដីកាចូលជាស្ថាពរ។

[72] «អង្គសេចក្តី» គឺមានន័យទាក់ទងទៅនឹងអង្គហេតុទាំងមូលជុំវិញអង្គហេតុចោទប្រកាន់ និងជាផ្នែកមួយនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។

[73] មាត្រា២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[74] មាត្រា១៩៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ណាមិញ ដីកានេះក៏មានអានុភាពជាលិខិតបញ្ជា (លិខិតឃុំខ្លួនស្របច្បាប់) ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះផងដែរ។[75]

ជាគោលការណ៍ ដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរអាចចេញបានតែទៅលើជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ។ ដែលជនខាងលើនេះ គឺសំដៅទៅលើបុគ្គលទាំងឡាយណាដែលព្រះរាជអាជ្ញាផ្ដើមចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (RI) មកចំពោះមុខចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះមានន័យថា ដីកានេះគឺមិនមានអានុភាពក្នុងការចេញទៅលើបុគ្គលផ្សេងទៀតដូចជា សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះក្រៅពីការចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញាដូចមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ ពិសេសជាងនេះទៅទៀតនោះ គឺអានុភាពនៃការអនុវត្តនៃដីកាបង្គាប់ឱ្យចាប់ខ្លួននេះអាចជាកម្មវត្ថុនៃការផ្សព្វផ្សាយជាសាធារណៈនៅលើដែនដីព្រះរាជាណាចក្រកម្ពុជា និងជាអន្តរជាតិផងដែរ។ ម្យ៉ាងទៀតនោះ ទោះបីជាបន្ទាប់ពីចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះរួចហើយ ចៅក្រមស៊ើបសួរបានសម្រេចបិទបញ្ចប់ការស៊ើបសួររបស់ខ្លួនដោយដីកាដំណោះស្រាយ[76] ដែលដីកាដំណោះស្រាយនេះមានអានុភាពបិទបញ្ចប់កិច្ចស៊ើបសួរនេះយ៉ាងណាក៏ដោយ ក៏ដីកាបង្គាប់ឱ្យចាប់ខ្លួននេះមានអានុភាពដរាបណាបណ្ដឹងអាជ្ញាមិនទាន់រលត់។ ដីកាដំណោះស្រាយមិនអាចលុបចោលនូវអានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួននោះទេ។

## ២.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន

### ២.៤.១. សញ្ញាណគតិយុត្តនៃដីកាបង្គាប់ឱ្យឃុំខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន។[77] ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។[78] គួរឱ្យកត់សម្គាល់ផងដែរថា ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទនោះជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។[79]

[75] មាត្រា១៩៦ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[76] «ដីកាដំណោះស្រាយ» គឺជាដីកាមួយដែលប្រើនៅពេលមានការបញ្ចប់ ឬបិទការស៊ើបសួរហើយចៅក្រមស៊ើបសួរជាអ្នកចេញដីកាដំណោះស្រាយនេះទៅឲ្យព្រះរាជអាជ្ញា។

[77] មាត្រា២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[78] មាត្រា២២០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[79] មាត្រា២២០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ២.៤.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យឃុំខ្លួន

ចៅក្រមស៊ើបសួរសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំបណ្តោះអាសន្ន។[80] ត្រង់ចំណុចនេះចង់បានន័យថា លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យឃុំ គឺអាចប្រព្រឹត្តទៅបានបន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចធ្វើការឃុំខ្លួនជនណាម្នាក់ តាមរយៈដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ផ្ទុយទៅវិញនោះចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទមុនការសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នបានទេ។ និយាយជារួមមកនោះ ការចេញដីកាបង្គាប់ឱ្យឃុំខ្លួន ធ្វើឡើងដោយឈរលើមូលដ្ឋាន នៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ទាំងស្រុង។

បន្ថែមពីនេះចៅក្រមស៊ើបសួរ អាចសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន ដោយកំណត់អំពីនិទ្ទេសដែលត្រូវចុះក្នុងដីកានេះដូចខាងក្រោម៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា[81]

ហើយដីកាបង្គាប់ឱ្យឃុំខ្លួននេះត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។[82]

### ២.៤.៣. ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន

ចំពោះការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន ដីកានេះត្រូវយកទៅអនុវត្តដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬកន្លែងដែលឃុំខ្លួនជននោះ។ ក៏ប៉ុន្តែនៅក្នុងលក្ខខណ្ឌដែលជនដែលត្រូវឃុំខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌នៅឡើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធនោះទៅកាន់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដូចដែលមានបញ្ជាក់ និងចង្អុលបង្ហាញតាមរយៈដីកាបង្គាប់ឱ្យឃុំខ្លួន។ ម្យ៉ាងទៀត ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែមានដំណឹងអំពីការដោះលែងឱ្យមានសេរីភាពឡើងវិញ។[83] លើសពីនេះទៀត ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។[84]

---

[80] មាត្រា២២០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[81] មាត្រា២២១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[82] មាត្រា២២១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[83] មាត្រា២២២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[84] មាត្រា២២២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ២.៤.៤. អានុភាពនៃដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួននេះមានអានុភាពបញ្ជាទៅដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងរួមទាំងឃុំខ្លួនជនត្រូវចោទ។ ដីកាបង្គាប់ឱ្យឃុំខ្លួនមិនអាចជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នោះទេ។ ប្រសិនបើប្រធានពន្ធនាគារក្ដី ឬប្រធានមណ្ឌលឃុំខ្លួនក្ដីបានទទួលឃុំខ្លួនជនណាម្នាក់ដោយគ្មានដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទពីសំណាក់អាជ្ញាធរតុលាការទេ នោះប្រធានពន្ធនាគារ ឬប្រធានមណ្ឌលឃុំខ្លួននោះអាចប្រឈមនឹងការប្រព្រឹត្តបទល្មើសដែលទាក់ទងទៅនឹងការបង្ខាំងមនុស្សដោយខុសច្បាប់។

ជាងនេះទៅទៀត សម្រាប់ដីកាសម្រេចឱ្យឃុំខ្លួន គឺជាលិខិតឃុំខ្លួនស្របច្បាប់របស់អាជ្ញាធរតុលាការដែលត្រូវបានប្រើប្រាស់បំពេញបន្ថែមទៅលើ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ ត្រង់ចំណុចនេះមានន័យថាកម្មវត្ថុនៃដីកាបង្គាប់ឱ្យឃុំខ្លួនគឺឈរលើកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ ដោយហេតុនេះហើយអានុភាពសម្រាប់ដីកាបង្គាប់ឱ្យឃុំខ្លួន គឺកើតចេញផ្ទាល់ពីអានុភាពនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។

## ផ្នែកទី៣៖ ការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន សំដៅទៅលើការឃុំខ្លួនជនត្រូវចោទតាមដីកាបង្គាប់ឱ្យរបស់សហចៅក្រមស៊ើបសួរ ឬសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ឬសំដៅទៅលើការឃុំខ្លួនជនជាប់ចោទតាមដីការបស់អង្គជំនុំជម្រះ ដើម្បីរង់ចាំសេចក្ដីសម្រេចចុងក្រោយ។[85] ម្យ៉ាងវិញទៀតនោះ ការឃុំខ្លួនបណ្ដោះអាសន្ននេះគឺជាការចាំបាច់ដែលធានាឱ្យមានវត្តមានរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ ហើយក៏ធានាមិនឱ្យមានការរំខានដល់ដំណើរនៃការស៊ើបសួរ ឬប្រព្រឹត្តបទល្មើសថ្មីទៀតមុនពេលជម្រះក្ដី។[86] ដោយសារតែការសម្រេចបែបនេះ គឺជាការដកហូតនូវសេរីភាពជនត្រូវចោទ ដូច្នេះហើយការសម្រេចឃុំខ្លួនបណ្ដោះអាសន្នត្រូវមានការពិចារណាឱ្យបានហ្មត់ចត់និងត្រូវផ្ដល់មូលហេតុឱ្យបានសមស្របទៅតាមបញ្ញត្តិច្បាប់។

### ៣.១ គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

បុគ្គលគ្រប់ៗរូបសុទ្ធតែមានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងលក្ខខណ្ឌដែលបានចែងក្នុងផ្នែកនេះ[87] ហើយគ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនតាមតែអំពើចិត្តបានឡើយ។ ត្រង់កន្លែងនេះចង់សំដៅថាគ្មានបុគ្គលណាម្នាក់ត្រូវបានដកហូតសិទ្ធិសេរីភាពបានឡើយ លើកលែងតែមានហេតុផលត្រឹមត្រូវ និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។ ក៏ប៉ុន្តែច្បាប់អនុញ្ញាតឱ្យចៅក្រមស៊ើបសួរអាចមានជម្រើសក្នុងការសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទបាន

[85] សន្ធានុក្រមទំព័រ ១៣២ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ឆ្នាំ ២០១៥ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

[86] ទំព័រ ៤៧ នៃសៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌឆ្នាំ២០០៦ របស់ក្រសួងយុត្តិធម៌

[87] ទំព័រ ១១២ នៃសេចក្តីពន្យល់ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ហើយជម្រើសនៃការឃុំខ្លួននេះតម្រូវឱ្យចៅក្រមស៊ើបសួរត្រូវគោរពតាមលក្ខខណ្ឌច្បាប់ដ៏តឹងរឹង គឺមិនអាចសម្រេចឃុំខ្លួនជនត្រូវចោទតាមអំពើចិត្តបានឡើយ។ ម៉្យាងទៀត ទោះបីជាជនត្រូវចោទកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នក៏ដោយ ក៏ជនត្រូវចោទគ្រាន់តែត្រូវបានដកហូតនូវសេរីភាពដើរហើររបស់ខ្លួនប៉ុណ្ណោះ រីឯសិទ្ធិផ្សេងទៀតនឹងត្រូវបានធានាដោយច្បាប់ សិទ្ធិទាំងនោះមានដូចជា សិទ្ធិឆ្លើយបំភ្លឺ ឬនៅស្ងៀមមិនឆ្លើយបំភ្លឺសិទ្ធិទទួលបានដឹងរឿងរ៉ាវអំពីការចោទប្រកាន់ និងប្រាប់ឈ្មោះបទល្មើស និងសិទ្ធិទទួលបានការការពារពីមេធាវីជាអាទិ៍។[88]

## ៣.២.លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន អនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ឱ្យផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។[89]

ហើយដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចខាងក្រោម៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅឋានរបស់ជនត្រូវចោទ ប្រសិនបើមានពិរុទ្ធកម្មត្រូវប្រកាស (ធ្លាប់មានទោស ឬអត់)
- លេខ និងកាលបរិច្ឆេទនៃការធ្វើដីកា។[90]

និទ្ទេសខាងលើនេះជាចំណុចសំខាន់ចាំបាច់ ដែលតម្រូវឱ្យមានចុះនៅក្នុងដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ។

ពិសេសជាងនេះទៅទៀតនោះ ការឃុំខ្លួនបណ្ដោះអាសន្នគឺជាជម្រើសចុងក្រោយមួយ និងចាំបាច់។ ហេតុដូច្នេះហើយ នៅមុនពេលដែលចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវពិចារណាទៅលើលក្ខខណ្ឌចាំបាច់មួយចំនួនដូចជា៖ លក្ខខណ្ឌបទល្មើស និងលក្ខខណ្ឌអាយុរបស់ជនត្រូវចោទ។

### ៣.២.១. បទល្មើស

នៅពេលដែលសំណុំរឿងព្រហ្មទណ្ឌត្រូវបានបញ្ជូនពីព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរការចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (RI) អាចជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ហើយសមត្ថកិច្ចក្នុងការស៊ើបសួរ

[88] មាត្រា១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[89] មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[90] មាត្រា២៤៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

របស់ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនបណ្ដោះអាសន្ន។ ប្រសិនជាចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់បានចែង។

ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តបានតែករណីចោទប្រកាន់ពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលច្បាប់បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពីមួយឆ្នាំ។[91] ចំពោះលក្ខខណ្ឌបែបនេះគឺជាជម្រើសសម្រាប់ចៅក្រមស៊ើបសួរ ហើយបទល្មើសមជ្ឈិម ឬបទល្មើសឧក្រិដ្ឋសុទ្ធសឹងជាបទល្មើសព្រហ្មទណ្ឌដែលអាចផ្ដន្ទាទោសជាប់ពន្ធនាគារ។ ក្នុងនោះដែរ បទល្មើសមជ្ឈិមជាបទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេល ៦(ប្រាំមួយ) ថ្ងៃ និងក្រោមឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។[92] រីឯបទឧក្រិដ្ឋវិញ គឺជាបទល្មើសដែលអតិបរមានៃការដាក់ពន្ធនាគារអស់មួយជីវិត និងជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើ ៣០(សាមសិប) ឆ្នាំ។[93]

ជាទូទៅ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមក្នុងក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យចៅក្រមជំនុំជម្រះអាចសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារចំពោះបុគ្គលណាមួយស្ថិតនៅក្នុងព្រំដែននៃកម្រិតអប្បបរមា និងកម្រិតអតិបរមានៃទោស។ ជាក់ស្ដែង ដូចជានៅក្នុងករណីបទលួចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ៣ឆ្នាំ[94] ដូចនេះហើយទើបមានការបកស្រាយផ្សេងៗគ្នាចំពោះកម្រិតអប្បបរមា និងកម្រិតអតិបរមាដែលអាចនាំឱ្យចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរកំណត់យកកម្រិតអប្បបរមានៃទោសចំនួន ៦ (ប្រាំមួយ) ខែនោះ មិនអាចឱ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទបានទេ ដោយផ្អែកទៅលើលក្ខខណ្ឌដែលចែងនៅក្នុងមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ផ្ទុយទៅវិញនោះប្រសិនបើចៅក្រមស៊ើបសួរកំណត់យកកម្រិតអតិបរមានៃទោសចំនួន ៣ (បី) ឆ្នាំ នោះប្រាកដជាបានបំពេញនូវលក្ខខណ្ឌដែលច្បាប់បានកំណត់ដែលនាំឱ្យចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទបាន។

ត្រង់ចំណុចនេះ បើផ្អែកទៅលើគោលការណ៍ក្នុងការសម្គាល់បទល្មើសខាងលើនេះអាចបញ្ជាក់បានថាស្មារតីនៃបញ្ញត្តិច្បាប់កំណត់យកកម្រិតអតិបរមា ហើយចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទបាន ដោយយោងទៅតាមលក្ខខណ្ឌដែលបានចែងថា « ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ»[95] ដូចដែលមានចែងក្នុងមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[91] មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[92] មាត្រា៤៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[93] មាត្រា៤៦ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[94] មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[95] មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

បើយើងសង្កេតមើលទៅ សម្រាប់បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ បទល្មើសភាគច្រើនសុទ្ធសឹងតែត្រូវផ្តន្ទាទោសចាប់ពី ១ (មួយ) ឆ្នាំឡើងទៅ ហើយអាចចូលលក្ខខណ្ឌច្បាប់ដែលអាចនាំឱ្យចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន។ ម្យ៉ាងទៀតប្រសិនបើជាចៅក្រមស៊ើបសួរគោរពនូវលក្ខខណ្ឌច្បាប់ខាងលើទាំងស្រុង នោះជនត្រូវចោទភាគច្រើនប្រាកដជាត្រូវបានឃុំខ្លួនបណ្តោះអាសន្នទាំងអស់។

### ៣.២.២. អាយុរបស់ជនត្រូវចោទ

ជាងនេះទៅទៀតនោះ ជាគោលការណ៍នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវកំណត់អាយុចំពោះបុគ្គលដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[96] ក៏ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មទៅលើអនីតិជនបានចាប់ពីអាយុ ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។[97] ហើយអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស។[98] ត្រង់ចំណុចនេះចង់មានន័យថា ថ្វីត្បិតតែអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ រួមទាំងមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ ហើយក្នុងករណីដែលចៅក្រមស៊ើបសួររកឃើញថាអនីតិជនដែលកំពុងជាប់ឃុំមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងអនីតិជននោះជាបន្ទាន់។[99] រីឯចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ អាចទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែតុលាការត្រូវធានាដល់វិធានការតាមដានដែលមានដូចជាវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។[100] ជាមួយគ្នានេះដែរ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នបានទេ ហើយសម្រាប់អនីតិជនដែលអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន ប៉ុន្តែថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានលក្ខណៈធូរស្រាលជាងការអនុវត្តទៅលើនីតិជន។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌនាំឱ្យការឃុំខ្លួនបណ្តោះអាសន្ន ដែលត្រូវកំណត់តាមលក្ខខណ្ឌអាយុរបស់ជនត្រូវចោទក្នុងនោះការអនុវត្តចំពោះជនត្រូវចោទដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាករណីពិសេស និងមានកម្រិតស្រាលជាងជនត្រូវចោទមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។

---

[96] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[97] មាត្រា៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[98] មាត្រា៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[99] មាត្រា៣៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[100] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

បើយើងក្រឡេកទៅមើលក្នុងស្ថានភាពជាក់ស្តែងវិញនោះ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ជនល្មើសគ្រប់រូបដោយមិនគិតពីអាយុឡើយ រួមទាំងអញ្ញត្រជនផងដែរ ប៉ុន្តែសម្រាប់ចៅក្រមស៊ើបសួរវិញអាចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ។ ហើយចំណុចដែលគួរឱ្យកត់សម្គាល់នោះ គឺការអនុវត្តការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនអាចធ្វើបានឡើយ។

### ៣.៣. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ក្រៅពីលក្ខខណ្ឌខាងលើនេះ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទបានគឺធ្វើឡើងនៅក្នុងករណីចាំបាច់ប៉ុណ្ណោះ។ ការចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន គឺត្រូវធ្វើឡើងដោយគោរពនូវមូលហេតុចំនួន ៦ (ប្រាំមួយ) ដូចខាងក្រោមនេះ៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតឡើងសារជាថ្មី។
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[101]

គោលគំនិតនៃមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ វាកើតចេញពីភាពធ្ងន់ធ្ងរនៃអំពើល្មើសចេតនាទុច្ចរិត ចរិកលក្ខណៈដ៏គ្រោះថ្នាក់របស់ជនត្រូវចោទ និងកត្តាដទៃទៀត ព្រោះប្រសិនបើចៅក្រមស៊ើបសួរអនុញ្ញាតឱ្យជនត្រូវចោទដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរមានចរិកទុច្ចរិត និងលក្ខណៈគ្រោះថ្នាក់នៅក្រៅឃុំនោះ ភាគីជនរងគ្រោះ សាក្សី និងសង្គមទាំងមូលមិនអាចទទួលយកបានឡើយ ព្រមទាំងអាចនាំឱ្យកិច្ចស៊ើបសួរទាំងមូលនេះជួបប្រទះនឹងផលអវិជ្ជមាន។ ដោយឡែកចៅក្រមស៊ើបសួរអាចសំអាងទៅលើមូលហេតុណាមួយ ឬច្រើនក្នុងចំណោមមូលហេតុខាងលើទាំងអស់នេះ ដើម្បីសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន។

ជាគោលការណ៍ច្បាប់ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់នូវមូលហេតុឱ្យសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃអំពីល្មើស និងលក្ខណៈរបស់ជនត្រូវចោទ ហើយចំពោះការដែលជ្រើសរើសនូវមូលហេតុត្រឹមត្រូវ គឺនាំឱ្យចៅក្រមស៊ើបសួរជាចមានភាពងាយស្រួលក្នុងការសរសេរនូវសំអាងហេតុច្បាស់លាស់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ផ្ទុយទៅវិញនោះ មូលហេតុនៃការឃុំខ្លួនទាំងប្រាំមួយខាងលើនេះត្រូវបានមើលរំលងដោយ

---

[101] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ចៅក្រមស៊ើបសួរដែលអាចបញ្ជាក់បានថា សិទ្ធិរបស់ជនត្រូវចោទក្នុងការដឹងអំពីមូលហេតុនៃការឃុំខ្លួន និងអំពើចោទប្រកាន់តាមផ្លូវច្បាប់។ ការខកខានក្នុងការបំពេញបែបនេះបណ្តាលមកពីស្ថានភាពជាក់ស្តែងនៅតុលាការចៅក្រមស៊ើបសួរត្រូវទទួលដោះស្រាយរឿងក្តីជាច្រើនដែលអាចបណ្តាលឱ្យប្រសិទ្ធភាពការងារនៅមានកម្រិត។ ថ្វីត្បិតតែមានការខ្វះចន្លោះក្នុងផ្នែកខាងលើក៏ដោយក៏ស្ថានភាពជាក់ស្តែងនៃការអនុវត្ត មិនបានចោទជាបញ្ហាប្រឈមធ្ងន់ធ្ងរឡើយសម្រាប់តុលាការ និងអាចទទួលយកបានគ្រប់ភាគី។

ជាងនេះទៅទៀត ចៅក្រមស៊ើបសួរផ្ទាល់ត្រូវពន្យល់អំពីរបៀបនៃការឃុំខ្លួនដែលអាចរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។ ម្យ៉ាងទៀតនោះ ចៅក្រមស៊ើបសួរមុននឹងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវតែមានមូលដ្ឋាន និងទឡ្ហីករណ៍រឹងមាំ ដើម្បីបង្ហាញឱ្យឃើញថាការដែលដោះលែងជនត្រូវចោទពិតជាបានធ្វើឱ្យមានការរំខានដល់សណ្តាប់ ធ្នាប់សាធារណៈជាក់ស្តែង។

### ៣.៤. នីតិវិធីសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន

ចៅក្រមស៊ើបសួរ អាចសម្រេចអំពីវិធាននៃការឃុំខ្លួនបណ្តោះអាសន្នដោយគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ហើយមុននឹងសម្រេចឃុំខ្លួនបណ្តោះអាសន្នចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់នានារបស់ជនត្រូវចោទនេះ។[102] ប្រសិនបើករណីជនត្រូវចោទមានមេធាវីអមនោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។[103] បន្ថែមពីនេះទៀត ចៅក្រមស៊ើបសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុត្រឹមត្រូវ។[104] ចំពោះដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[105] បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នហើយ គឺត្រូវចេញដីកាមួយទៀតហៅថា ដីកាបង្គាប់ឱ្យឃុំខ្លួន។ ត្រង់ចំណុចនេះ គឺដីកានេះត្រូវបញ្ជាក់ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនជនត្រូវចោទដែលមានកំណត់ក្នុងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។

ចំពោះការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវធ្វើឡើងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ករណីនេះបន្ទាប់ពីទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ តាមការស្នើសុំរបស់ព្រះរាជអាជ្ញានោះ ចៅក្រមស៊ើបសួរត្រូវ

102 មាត្រា២០៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
103 មាត្រា២០៦ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
104 មាត្រា២០៦ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
105 មាត្រា២០៦ កថាខណ្ឌទី២ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ចាត់វិធានការតាមនីតិវិធីដូចដែលមានចែងនៅក្នុងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជានេះ។ ទោះបីជាយ៉ាងណា បើចៅក្រមស៊ើបសួរមិនព្រមសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមការស្នើសុំនេះចៅក្រមស៊ើបសួរនឹងចេញដីកាសម្រេចមិនឃុំខ្លួនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុទេ ហើយត្រូវជូនដំណឹងបន្ទាន់នេះដល់អ្នកប្តឹងសុំ (ព្រះរាជអាជ្ញា)។[106] ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទដោយគំនិតផ្តើមរបស់ខ្លួនគាត់នោះ គឺត្រូវជូនដំណឹងអំពីការឃុំខ្លួនបណ្តោះអាសន្ននេះភ្លាមដល់ព្រះរាជអាជ្ញា និងប្រាប់ទៅកាន់ជនត្រូវចោទដែលត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ហើយការជូនដំណឹងនេះទៅកាន់ព្រះរាជអាជ្ញាត្រូវធ្វើឡើងក្នុងអំឡុងពេល ៥ (ប្រាំថ្ងៃ) យ៉ាងយូរបំផុត។ ម្យ៉ាងទៀត ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនោះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅកាន់សភាស៊ើបសួរដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ។[107]

### ៣.៥. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានលក្ខណៈខុសគ្នាអាស្រ័យទៅលើប្រភេទនៃបទល្មើស (បទឧក្រិដ្ឋ ឬបទមជ្ឈិម) រួមទាំងជនត្រូវចោទនោះកំពុងស្ថិតនៅអាយុប៉ុន្មាន? តើជនត្រូវចោទនោះគឺជានីតិជន ឬអនីតិជន? ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំចៅក្រមស៊ើបសួរមិនអាចសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នបានទេ។[108] ករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចប្រគល់ជនត្រូវចោទនោះទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាល ឬមណ្ឌលអប់រំថែរក្សាណាមួយថែរក្សាដើម្បីធ្វើការរងចាំសេចក្តីសម្រេចរបស់តុលាការ។[109] ជាងនេះទៅទៀតនោះ ដោយយោងទៅលើទម្រង់ថ្មីដែលដាក់ឱ្យប្រើដោយក្រសួងយុត្តិធម៌សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរត្រូវកំណត់អំពីថិរវេលាអតិបរមា។ ហេតុដូចនេះ ក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្នចៅក្រមស៊ើបសួរត្រូវធ្វើការផ្ទៀងផ្ទាត់ និងកំណត់ឱ្យបានច្បាស់លាស់អំពីថិរវេលាដែលអាចឃុំខ្លួនបណ្តោះអាសន្នបាន។ ជាធម្មតាថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើស និងលក្ខណៈគតិយុត្តនៃអាយុរបស់ជនត្រូវចោទនាពេលប្រព្រឹត្តបទល្មើស។ ដូចនេះហើយចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ គឺមានថិរវេលាខុសគ្នារវាងការឃុំខ្លួនបណ្តោះអាសន្នទៅលើនីតិជន និងលើអនីតិជន ក៏ដូចជារវាងបទឧក្រិដ្ឋ និងបទមជ្ឈិមផងដែរ។

[106] មាត្រា២០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[107] មាត្រា២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[108] មាត្រា២១២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[109] មាត្រា២១២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ៣.៥.១.ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋ

ចំពោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋ ថិរវេលានៃការឃុំខ្លួនមានភាពខុសគ្នារវាងជនត្រូវចោទជានីតិជន និងជនត្រូវចោទជាអនីតិជន។

#### ៣.៥.១.១. ករណីជនត្រូវចោទជានីតិជន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះជនត្រូវចោទជានីតិជនដែលចោទប្រកាន់ពីបទឧក្រិដ្ឋការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។[110] ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីបទល្មើសខាងលើជាកម្រិតអតិបរមា។ ត្រង់ចំណុចនេះបានន័យថា ច្បាប់បានទុកសិទ្ធិឱ្យចៅក្រមស៊ើបសួរអាចសម្រេចថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នប៉ុន្មានក៏បានដែរ ប៉ុន្តែមិនអាចត្រូវលើសពី ៦(ប្រាំមួយ) ខែបានទេ។ ទោះបីជាយ៉ាងណា បន្ទាប់ពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើត្រូវបានផុតរួចហើយ ក៏ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះម្ដងបាន ៦(ប្រាំមួយ) ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។[111] លើសពីនេះទៅទៀតនោះ ការសម្រេចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារពេលឃុំខ្លួនបានតែចំនួន ២ដងគត់ប៉ុណ្ណោះ។[112]

#### ៣.៥.១.២.ករណីជនត្រូវចោទជាអនីតិជន

ការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់អនីតិជន និងនីតិជនចំពោះបទឧក្រិដ្ឋមានលក្ខណៈមិនដូចគ្នាឡើយហើយចំពោះថិរវេលានេះមានភាពខុសគ្នាទៅតាមអាយុរបស់អនីតិជននោះ។ ជាការពិតណាស់ អាយុរបស់អនីតិជនក្នុងការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបែងចែកជា ៣ (បី) ប្រភេទ ដែលប្រភេទទី១ គឺជាអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ។ រីឯប្រភេទទី២ សំដៅទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ។ ហើយចំពោះប្រភេទទី៣វិញ គឺអនីតិជនដែលមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨( ដប់ប្រាំបី) ឆ្នាំ។

ជាក់ស្ដែង នៅក្នុងករណីអនីតិជនដែលមានអាយុក្រោម ១៤(ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរមិនអាចសម្រេចឱ្យឃុំខ្លួនអនីតិជននោះបានទេ ដោយយោងតាមមាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯ ករណីដែលអនីតិជននោះមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ នោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៤ (បួន) ខែ បានទេ។[113] ម្យ៉ាងវិញទៀតប្រសិនបើ

[110] មាត្រា២០៨ កថាខណ្ឌទ១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[111] មាត្រា២០៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[112] មាត្រា២០៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[113] មាត្រា២១៣ កថាខណ្ឌទី១ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ករណីដែលជនត្រូវចោទជាអនីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជននោះមិនអាចលើសពី ៦ (ប្រាំមួយ) ខែបាននោះទេ។[114] ជាងនេះទៅទៀតនោះ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់អនីតិជននេះមិនអាចត្រូវបានពន្យារពេលបានទេ ហើយក៏មិនត្រូវលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលបានអនុវត្តចំពោះអនីតិជននោះបានឡើយ។

### ៣.៥.២.ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិម

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិម ក៏មិនខុសពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋដែរ ដែលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិមក៏មានភាពខុសគ្នារវាងការឃុំខ្លួនជនត្រូវចោទជានីតិជន និងជាអនីតិជនផងដែរ។

#### ៣.៥.២.១.ករណីជនត្រូវចោទជានីតិជន

ចំពោះថិរវេលាវេលានៃការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់ជនត្រូវចោទជានីតិជនដែលត្រូវបានរងការចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបាននោះទេ។[115] ជាការពិតណាស់ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីបទមជ្ឈិមខាងលើនេះជាកម្រិតអតិបរមា ត្រង់នេះមានន័យថា ច្បាប់បានទុកសិទ្ធិឱ្យចៅក្រមស៊ើបសួរអាចសម្រេចថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នប៉ុន្មានក៏បានដែរ ក៏ប៉ុន្តែមិនអាចត្រូវលើសពី ៤ (បួន) ខែបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលផុតថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិមនេះ ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចពន្យារពេលនៃការឃុំខ្លួនបានតែម្ដងគត់ ដោយមិនឱ្យលើសពី ២ (ពីរ) ខែ និងមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។[116]

ពិសេសជាងនេះទៅទៀត ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈិមខាងលើនេះ មិនត្រូវឱ្យលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[117] ចៅក្រមស៊ើបសួរត្រូវធ្វើការគណនាដោយយកថិរវេលានៃការឃុំខ្លួនពាក់កណ្ដាលអប្បបរមានៃទោសដែលបានកំណត់ដោយច្បាប់។ ជាក់ស្ដែង ប្រសិនបើជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទលួច ដែលត្រូវផ្ដន្ទាទោសពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ[118] នោះចៅក្រមស៊ើបសួរមិនអាចសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទនោះលើសពី ៣ (បី) ខែទេ។

[114] មាត្រា២១៣ កថាខណ្ឌទី១ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[115] មាត្រា២០៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[116] មាត្រា២០៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[117] មាត្រា២០៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[118] មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

### ៣.៥.២.២.ករណីជនត្រូវចោទជាអនីតិជន

ដូចដែលបានរៀបរាប់រួចមកហើយនៅខាងលើទាក់ទងទៅនឹងការបែងចែកប្រភេទនៃអាយុរបស់អនីតិជនដែលអាចត្រូវធ្វើការឃុំខ្លួនបណ្តោះអាសន្នបាន។ ជាក់ស្តែងចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គឺដូចគ្នាទៅនឹងការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនក្នុងបទឧក្រិដ្ឋដែរ គឺអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំនេះ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នបានទេ ដោយយោងតាមមាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[119] ជាមួយគ្នានេះដែរ ចំពោះករណីដែលជនតត្រូវចោទជាអនីតិជនដែលមានអាយុ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ នោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជននោះមិនអាចលើសពី ២ (ពីរ) ខែបានទេ។[120] រីឯចំពោះករណីដែលជនត្រូវចោទដែលជាអនីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបីឆ្នាំ) ឆ្នាំ នោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់អនីតិជននោះ មិនអាចលើសពី ៤ (បួន) ខែបានទេ។[121] ហើយចំពោះថិរវេលានៃការឃុំខ្លួនជនត្រូវចោទដែលជាអនីតិជនទាំងពីរខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។[122] ពាក់ព័ន្ធទៅនឹងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដែលអនុវត្តលើអនីតិជន ចំពោះការចោទប្រកាន់ទៅលើបទមជ្ឈិមនេះ ច្បាប់មិនបានចែងឱ្យមានការពន្យារពេលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននោះទេ។ ហេតុនេះ ចៅក្រមស៊ើបសួរមិនអាចធ្វើការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនបានឡើយ។

### ៣.៥.៣.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋសង្គ្រាម

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរមានដូចជា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនចំពោះបទល្មើសខាងលើនេះ គឺមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេចំពោះបទល្មើសនីមួយៗ។[123] ទោះបីជាយ៉ាងណា នៅពេលផុតរលត់ថិរវេលានៃការឃុំខ្លួនខាងលើនេះ ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបាន ១ (មួយ) ឆ្នាំ ដោយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។[124] លើសពីនេះទៅទៀតនោះ ចៅក្រមស៊ើបសួរអាចសម្រេចបង្គាប់ឱ្យពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ (ពីរ) ដងគត់តែប៉ុណ្ណោះ។[125] ហេតុដូចនេះ ចៅក្រមស៊ើបសួរអាចឃុំខ្លួនបណ្តោះអាសន្ន

[119] មាត្រា២១២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[120] មាត្រា២១៤ កថាខណ្ឌទី១ ចំណុចទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[121] មាត្រា២១៤ កថាខណ្ឌទី១ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[122] មាត្រា២១៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[123] មាត្រា២១០ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[124] មាត្រា២១០ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[125] មាត្រា២១០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ជនត្រូវចោទក្នុងចិរវេលាសរុបចំនួន ៣ (បី) ឆ្នាំ។ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរខាងលើនេះមានលក្ខណៈពិសេសជាងបទល្មើសធម្មតា។

### ៣.៥.៤. ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

ចិរវេលានៃការបំពេញកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ អាចមានលក្ខណៈខុសៗគ្នាទៅតាមភាពស្មុគស្មាញនៃរឿងក្តី ហើយករណីខ្លះការស៊ើបសួរត្រូវការចិរវេលាយូរដែលអាចលើសពីចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ ដើម្បីបន្តនូវការស៊ើបសួរ ចាំបាច់ដែលតម្រូវឱ្យមានការឃុំខ្លួនជាបន្តចៅក្រមស៊ើបសួរត្រូវបានអនុញ្ញាតដោយច្បាប់ អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន។ កាលណាចៅក្រមស៊ើបសួរសម្រេចថានឹងពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងទៅកាន់ជនត្រូវចោទ និងទទួលការកត់សម្គាល់ជននេះ។[126] ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារកូនក្តីរបស់ខ្លួន។[127] លើសពីនេះ ចៅក្រមស៊ើបសួរធ្វើការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ននេះ តាមដីកាសម្រេចដែលមានសំអាងហេតុ។[128] បន្ថែមពីនេះទៀតនោះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាដែលបានចែងអំពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងដីកាសម្រេចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ននេះ។[129] ចំពោះដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ទៅដល់ជនត្រូវចោទ។[130] គួរឱ្យកត់សម្គាល់ផងដែរថា បញ្ញត្តិនេះបង្ហាញអំពីនីតិវិធីដែលចៅក្រមស៊ើបសួរត្រូវអនុវត្ត ដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើកដំបូងផងដែរ ប៉ុន្តែខុសគ្នាត្រង់ថាករណីពន្យារពេលឃុំខ្លួននេះជនត្រូវចោទកំពុងស្ថិតនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ហើយមានចំណុចសំខាន់ៗទៀតនោះដូចជាការជូនដំណឹងដល់ជនត្រូវចោទ និងព្រះរាជអាជ្ញា ការកត់សម្គាល់ជនត្រូវចោទ ក៏ដូចជាការចូលរួមធ្វើសេចក្តីសន្និដ្ឋានរបស់ព្រះរាជ្ញា និងសំអាងហេតុនៃដីកាសម្រេចដែលចំណុចខាងលើទាំងអស់នេះ មានលក្ខណៈដូចគ្នាទៅនឹងការអនុវត្តក្នុងការចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលើកដំបូងដែរ។ ទន្ទឹមនឹងនេះដែរ បញ្ញត្តិទាក់ទងទៅនឹងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន មិនបានចែងលម្អិតអំពីនីតិវិធីដែលត្រូវអនុវត្តដូចទៅនឹងការសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលើកដំបូងឡើយ ដូចនេះការអនុវត្តនីតិវិធីការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន គប្បីអនុវត្តដូចគ្នាទៅនឹងការអនុវត្តនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នលើកដំបូង។

[126] មាត្រា២១១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[127] មាត្រា២១១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[128] មាត្រា២១១ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[129] មាត្រា២១១ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[130] មាត្រា២១១ កថាខណ្ឌទី២ វាក្យខណ្ឌទ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ក្នុងស្ថានភាពជាក់ស្តែង ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរត្រូវមានការទទួលខុសត្រូវខ្ពស់ ព្រោះប្រសិនបើយល់ឃើញថាការស៊ើបសួររបស់ខ្លួនត្រូវការពេលវេលាបន្ថែម ចៅក្រមស៊ើបសួរផ្ទាល់ត្រូវចេញដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្តោះអាសន្នយ៉ាងណាឱ្យបានមុនពេលកាលបរិច្ឆេទនៃការអស់អានុភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (ចាស់) និងគោរពតាមគោលការណ៍សេរីភាពរបស់ជនត្រូវចោទ។

## ៣.៦. ការបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន

ដូចដែលបាននិយាយបញ្ជាក់រួចមកហើយថា ជនត្រូវចោទត្រូវបានឃុំខ្លួនគ្រាន់តែជាការឃុំខ្លួនមួយរយៈតាមដែលច្បាប់កំណត់តែប៉ុណ្ណោះ គឺគាត់មិនទាន់បានត្រូវទទួលទោសព្រហ្មទណ្ឌនៅឡើយទេ ដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថាពរណាមួយពីតុលាការ។ ជនត្រូវចោទក៏អាចត្រូវបានដោះលែងឱ្យមានសេរីភាពវិញនៅក្នុងរយៈពេលណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។

### ៣.៦.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

ការស្នើសុំដោះលែងជនត្រូវចោទនៅក្នុងដំណាក់ចៅក្រមស៊ើបសួរនេះ អាចត្រូវធ្វើឡើងដោយតាមរយៈចៅក្រមស៊ើបសួរផ្ទាល់ ឬតាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្តឹងរបស់ជនត្រូវចោទ។ ចំពោះខ្លឹមសារនៃចំណុចនីមួយៗខាងលើនេះមានដូចខាងក្រោមនេះ ៖

#### ៣.៦.១.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងពេញលេញទៅលើការសម្រេចចិត្តក្នុងការបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលានៅក្នុងដំណាក់កាលស៊ើបសួរ។[131] ចំពោះជនត្រូវចោទជាអនីតិជន ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងបានគ្រប់ពេលវេលាបានផងដែរ ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន។[132] កាលណាដែលចៅក្រមស៊ើបសួរមានបំណងចង់ធ្វើការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានទៅដល់ព្រះរាជអាជ្ញាតាមរយៈដីកាបញ្ជូនឱ្យឆ្លើយ ដើម្បីសុំយោបល់ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។[133] បន្ទាប់មកនោះព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនត្រឡប់មកវិញនៅក្នុងរយៈពេលយ៉ាងខ្លីបំផុតបន្ទាប់ពីចៅក្រមស៊ើបសួរបានបញ្ជូនសំណុំរឿងមក។[134] ហើយចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញា។[135] ជាធម្មតាចៅក្រមស៊ើបសួរត្រូវតែរង់ចាំយោបល់ពីព្រះរាជអាជ្ញាជាមុនសិន មុននឹងសម្រេចដោះលែងជនត្រូវចោទ ក៏ប៉ុន្តែប្រសិនជានៅ

---

[131] មាត្រា២១៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[132] មាត្រា៤១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[133] មាត្រា២១៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[134] មាត្រា២១៥ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[135] មាត្រា២១៥ កថាខណ្ឌទី២ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ក្នុងករណីបន្ទាន់ណាមួយ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាមដោយមិនចាំបាច់រង់ចាំយោបល់របស់ព្រះរាជអាជ្ញាទេ និងចង្អុលប្រាប់អំពីមូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន។[136] ត្រង់ចំណុចនេះអនុវត្តដូចគ្នាចំពោះជនត្រូវចោទជាអនីតិជន ដោយយោងតាមមាត្រា ៤១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។[137]

ចៅក្រមស៊ើបសួរចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ។ នៅពេលដែលចៅក្រមស៊ើបសួរសម្រេចចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំនេះ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសនៅក្នុងដីកាសម្រេចនោះដូចខាងក្រោម៖

- ឈ្មោះរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់

ហើយដីកានេះត្រូវចុះលេខរៀង កាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី និងមានបោះត្រាផង។[138]

**៣.៦.១.២.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា**

ក្រៅពីការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនេះ ព្រះរាជអាជ្ញាក៏មានសិទ្ធិក្នុងការបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទដែរព្រះរាជអាជ្ញាក៏អាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។[139] ក្រោយពីបានទទួលបណ្ដឹងក្នុងការសុំឱ្យដោះលែងជនត្រូវចោទពីសំណាក់ព្រះរាជអាជ្ញារួចហើយ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។[140] នៅក្នុងករណីនេះការសម្រេចរបស់ចៅក្រមស៊ើបសួរ បន្ទាប់ពីទទួលបានបណ្ដឹងពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចសម្រេចតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា។ ផ្ទុយមកវិញ ចៅក្រមស៊ើបសួរក៏អាចសម្រេចបដិសេធនូវបណ្ដឹងរបស់ព្រះរាជអាជ្ញាបានដែរ នៅក្នុងករណីដែលចៅក្រមស៊ើបសួរបានយល់ឃើញថាការឃុំខ្លួន

---

[136] មាត្រា២១៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[137] មាត្រា៤១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន
[138] មាត្រា២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[139] មាត្រា២១៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[140] មាត្រា២១៦ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

បណ្តោះអាសន្នជនត្រូវចោទនៅតែជាករណីចាំបាច់សម្រាប់ដំណើរការនីតិវិធីផ្សេងៗបន្ថែមទៀត។ ម្យ៉ាងទៀតនោះ ចំពោះសេចក្តីសម្រេចដែលបដិសេធបណ្តឹងរបស់ព្រះរាជអាជ្ញានោះ ចៅក្រមស៊ើបសួរត្រូវធ្វើដីកាសម្រេចមិនព្រមដោះលែងតែត្រូវមានសំអាងហេតុ។[141] ជាងនេះទៅទៀត ប្រសិនបើចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបណ្តឹងពីព្រះរាជអាជ្ញានោះទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅកាន់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[142]

### ៣.៦.១.៣.ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ

ក្រៅពីការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំពីសំណាក់ចៅក្រមស៊ើបសួរ និងតាមបណ្តឹងរបស់ព្រះរាជអាជ្ញានោះក៏មានការដោះលែងជនត្រូវចោទទៅតាមបណ្តឹងរបស់ជនត្រូវចោទផងដែរ។

ចំពោះជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។[143] ហើយចំពោះពាក្យសុំដោះលែងឱ្យនៅក្រៅឃុំដែលធ្វើឡើងដោយជនត្រូវចោទ គឺចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅកាន់ព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាធ្វើការពិនិត្យ។[144] បន្ទាប់មកព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលមួយដ៏ខ្លីបំផុត។[145] ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញា។[146] ទោះបីជាយ៉ាងណា ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំនេះ ជនត្រូវចោទអាចពាក្យសុំមួយដែលបានធ្វើឡើងសារជាថ្មីម្តងទៀតទៅកាន់ចៅក្រមស៊ើបសួរ ឬទៅកាន់សភាស៊ើបសួរនៅក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន ហើយចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើកពាក្យសុំនេះជាថ្មី នៅក្នុងរយៈ ៥ (ប្រាំ) ថ្ងៃបន្ទាប់ទទួលបានពាក្យសុំ។[147] ហើយចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។[148] ជាទូទៅ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមាន

---

[141] មាត្រា២១៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[142] មាត្រា២១៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[143] មាត្រា២១៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[144] មាត្រា២១៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[145] មាត្រា២១៧ កថាខណ្ឌទី១ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[146] មាត្រា២១៧ កថាខណ្ឌទី១ វាក្យខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[147] មាត្រា២១៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[148] ទំព័រទី៤១ នៃសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ ,ឆ្នាំ២០១៣-២០១៤, រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

សំអាងហេតុ។[149]ម្យ៉ាងទៀតនោះ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ គឺជនត្រូវចោទនោះអាចធ្វើពាក្យប្តឹងដោយផ្ទាល់ទៅកាន់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[150]

នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងភ្លាមទៅដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[151] យ៉ាងណាក៏ដោយទោះបីជាមានសេចក្តីសម្រេចរបស់ចៅក្រមសម្រេចឱ្យដោះលែង ក៏ជនត្រូវចោទមិនអាចត្រូវបានដោះលែងបានភ្លាមៗដែរ ដោយត្រូវរក្សាទុកជនត្រូវចោទនោះទុកក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន រហូតដល់ផុតបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាបានយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាមដោយព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ហើយត្រូវបានដាក់ចូលក្នុងសំណុំរឿងនៃនីតិវិធី។[152] ក្នុងករណីដែលព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍អំពីដីកាដោះលែងឱ្យនៅក្រៅឃុំជនត្រូវចោទដែលត្រូវបានជាប់ឃុំនោះ ត្រូវរក្សាទុកនៅក្នុងពន្ធនាគារដដែលរហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។[153]

### ៣.៦.២. ការបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នដោយដីកាដំណោះស្រាយ

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។[154] នៅពេលដែលចៅក្រមស៊ើបសួរបញ្ចប់ការស៊ើបសួររបស់ខ្លួនដោយបានចេញដីកាដំណោះស្រាយ នោះការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទក៏ត្រូវបានបញ្ចប់ដែរ។ ដូចនេះដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន និងដីកាបង្គាប់ឱ្យឃុំខ្លួនដែលបានចេញដោយចៅក្រមស៊ើបសួរក៏ត្រូវអស់សុពលភាពដែរ។ ត្រង់ចំណុចនេះ គឺមានន័យថាជាគោលការណ៍ជនត្រូវចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។ ក៏ប៉ុន្តែនៅក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្ននេះនៅតែជាការចាំបាច់ ចៅក្រមស៊ើបសួរនៅតែអាចបន្តឃុំខ្លួនជនត្រូវចោទទៀតបានដោយតាមរយៈសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ហើយចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។[155] នៅក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជា

[149] មាត្រា២១៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[150] មាត្រា២១៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[151] មាត្រា២១៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[152] មាត្រា២៧៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[153] មាត្រា២៧៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[154] មាត្រា២៤៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា
[155] មាត្រា២៤៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

ណាចក្រកម្ពុជាដែលបានបញ្ញត្តិអំពីមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នផងដែរ។[156] ជាក់ស្ដែង ដីកាដែលសម្រេចដោយឡែកនោះមានឈ្មោះថា «ដីកាសម្រេចរក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្ដោះអាសន្ន» ដែលដីកានេះមានអានុភាពរក្សាទុកជនត្រូវចោទឱ្យនៅក្នុងការឃុំខ្លួនបន្តក្នុងរយៈពេល ៤ (បួន) ខែ។[157]

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេល ៤ (បួន) ខែ នោះទេ ជនត្រូវចោទនោះនឹងត្រូវបានដោះលែងឱ្យនៅក្រៅឃុំ និងមានសេរីភាពវិញដោយឯកឯង។[158]

## ផ្នែកទី៤៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ

កាលណាចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទ ឬដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្ដោះអាសន្នចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។

### ៤.១. គោលការណ៍នៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ជាគោលការណ៍ បើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទនោះទេគឺចៅក្រមស៊ើបសួរត្រូវសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យនេះអាចធ្វើឡើងតាមរយៈគំនិតផ្ទាល់របស់ចៅក្រមស៊ើបសួរ ឬតាមសេចក្តីសម្រេចសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មិនត្រូវបានអនុវត្តចំពោះអនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំទេ។[159]

### ៤.២. លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប្រសិនបើជនត្រូវចោទត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ចំពោះការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះផងដែរ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។[160]

ហើយដីកាបង្គាប់ឱ្យដាក់ក្រោការត្រួតពិនិត្យតាមផ្លូវតុលាការមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចខាងក្រោម៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី

[156] មាត្រា២៤៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[157] មាត្រា២៤៩ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[158] មាត្រា២៤៩ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

[159] មាត្រា២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា

[160] មាត្រា២២៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅឋានរបស់ជនត្រូវចោទ ប្រសិនបើមានពិរុទ្ធកម្មត្រូវប្រកាស (ធ្លាប់មានទោស ឬអត់)
- លេខ និងកាលបរិច្ឆេទនៃការធ្វើដីកា។[161]

និទ្ទេសខាងលើនេះជាចំណុចសំខាន់ចាំបាច់ ដែលតម្រូវឱ្យមានចុះក្នុងដីកាសម្រេចឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់ចៅក្រមស៊ើបសួរ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬ ច្រើនដូចតទៅៈ

១- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

២- មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣- មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧- មិនត្រូវបើកបររថយន្ត។

៨- មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩- ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១- ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាដហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។[162]

[161] មាត្រា២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[162] មាត្រា២២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងករណី ដែលកាតព្វកិច្ចតម្រូវលើជនត្រូវចោទមានចែងនៅត្រង់ចំណុចទី ៦ ទី៩ និងចំណុចទី ១០ នៃមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា ជនត្រូវចោទត្រូវទទួលបង្កាន់ដៃស្តីពីការប្រគល់ឯកសារអត្តសញ្ញាណប្រាក់ធានា ឬអាវុធដែលមានចុះហត្ថលេខាដោយក្រឡាបញ្ជី ហើយបង្កាន់ដៃប្រគល់ប្រាក់ធានា ឬ អាវុធ ត្រូវចុះហត្ថលេខរួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។[163]

ម្យ៉ាងទៀតនោះ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទដែលជាអនីតិជនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ដោយជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជននោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។[164]

**៤.៣. នីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

បន្ទាប់ពីបញ្ជូនជនសង្ស័យមកកាន់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរស្វែងរកការពិតរួចហើយ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួន នោះចៅក្រមស៊ើបសួរត្រូវសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមរយៈដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាវិធានការជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្ន ហើយការសម្រេចឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះផងដែរមិនសូវជាបិទសិទ្ធិសេរីភាពរបស់ជនត្រូវចោទទាំងស្រុងនោះទេ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមិនមែនជាករណីចាំបាច់ក្នុងការអនុវត្តការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរបានសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ហើយចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីការសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។[165]

ប្រសិនបើចៅក្រមស៊ើបសួរបានទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលស្នើសុំឱ្យដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប៉ុន្តែមិនព្រមសម្រេចតាមការសុំនេះទេ ចៅក្រមស៊ើបសួរត្រូវចេញដីការបដិសេធការសុំនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[166]

[163] មាត្រា២២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[164] មាត្រា៤០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[165] មាត្រា២២៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[166] មាត្រា២២៦ កថាខណ្ឌទី៣ ទី៤ និងទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

### ៤.៤. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ

ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ សំដៅទៅលើការកែប្រែខ្លឹមសារនៃកាតព្វកិច្ច ឬ បញ្ចូលកាតព្វកិច្ចថ្មី ឬ លុបចោល ឬ សុំឱ្យលើកលែងការត្រួតពិនិត្យតាមផ្លូវតុលាការ។ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការអាចធ្វើឡើងតាមគំនិតរបស់ចៅក្រមស៊ើបសួរ តាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ឬ តាមបណ្ដឹងសុំរបស់ជនត្រូវចោទ។ ចំពោះមូលហេតុក្នុងការសម្រេចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ គឺផ្អែកសំខាន់ទៅលើបុគ្គលិកលក្ខណៈជាក់ស្ដែង ឬ ស្ថានភាពនៃជីវភាពជាក់ស្ដែងរបស់ជនត្រូវចោទ។

#### ៤.៤.១. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ

ជាធម្មតាចៅក្រមស៊ើបសួរអាចធ្វើការកែប្រែ លុបចោល នៃខ្លឹមសារកាតព្វកិច្ច ឬ បញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ ក្នុងការកែប្រែ ឬ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការនេះ អាចធ្វើឡើងដោយផ្អែកលើមូលហេតុជាក់ស្ដែង ដោយចៅក្រមស៊ើបសួរអាចធ្វើការបន្ថែម ឬ បន្ធូរបន្ថយនូវកាតព្វកិច្ចដែលត្រូវកំណត់ក្នុងដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ហើយការសម្រេចកែប្រែ ឬ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[167]

#### ៤.៤.២. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

នៅគ្រប់ពេលដែលព្រះរាជអាជ្ញាយល់ឃើញថា ត្រូវលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនោះព្រះរាជអាជ្ញាត្រូវធ្វើបណ្ដឹងសុំឱ្យលើកលែង ឬ បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការទៅកាន់ចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដែលត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។[168]

កាលណាចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលខាងលើនោះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅកាន់សភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុអំពីការមិនព្រមធ្វើតាមការសុំរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែបើចៅក្រមស៊ើបសួរយល់ស្របតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា នោះចៅក្រមស៊ើបសួរត្រូវដីកាសម្រេចតាមពាក្យសុំរបស់ព្រះរាជអាជ្ញាតែម្ដង។[169]

[167] មាត្រា២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[168] មាត្រា២២៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[169] មាត្រា២២៨ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

### ៤.៤.៣. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការតាមពាក្យសុំរបស់ជនត្រូវចោទ

ក្រៅពីចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា ក្នុងនោះជនត្រូវចោទក៏មានសិទ្ធិអាចធ្វើពាក្យសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាផងដែរ។ ក្នុងករណីនេះ បន្ទាប់ពីចៅក្រមស៊ើបសួរទទួលពាក្យសុំពីជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿង និងពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសុំយោបល់។ ចៅក្រមស៊ើបសួរត្រូវសម្រេចលើពាក្យសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការរបស់ជនត្រូវចោទយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាសម្រេចលើពាក្យសុំនេះ ក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ [170]

កាលណាជនត្រូវចោទបានធ្វើពាក្យសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការជាថ្មីម្តងទៀត មុនពេលចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរសម្រេចលើពាក្យសុំពីមុន នោះចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំថ្មីនោះយ៉ាងយូររយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយគិតផ្តើមគិតចាប់ពីពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន។[171]

ចំពោះដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំត្រូវតែមានសំអាងហេតុ។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនសម្រេចលើពាក្យសុំរបស់ជនត្រូវចោទក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[172]

### ៤.៥.ទណ្ឌកម្មចំពោះការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ

ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានដែលតម្រូវឱ្យជនត្រូវចោទត្រូវគោរព និងអនុវត្តកាតព្វកិច្ចឱ្យបានត្រឹមត្រូវទៅតាមដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែលជនត្រូវចោទមានចេតនាគេចវេះពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ នោះចៅក្រមស៊ើបសួរអាចនឹងចាត់វិធានការតឹងរឹងជាងមុន គឺសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានចិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលមានប៉ុន្មានក៏ដោយ។[173]

---

[170] មាត្រា២២៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[171] មាត្រា២២៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[172] មាត្រា២២៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[173] មាត្រា២៣០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

កាលណាចៅក្រមស៊ើបសួរសម្រេចផ្លាស់ប្តូរវិធានការត្រួតពិនិត្យការត្រួតពិនិត្យតាមផ្លូវតុលាការទៅជាការឃុំខ្លួនបណ្តោះអាសន្នវិញ នោះចៅក្រមស៊ើបសួរសម្រេចចេញដីកាដែលមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទអំពីដីកាសម្រេចនេះ។ ការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចនេះមិនអាចឱ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន។[174]

## ៤.៦. ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការដោយដីកាដំណោះស្រាយ

ការត្រួតពិនិត្យតាមផ្លូវតុលាការនឹងត្រូវបញ្ចប់តាមដីកាដំណោះស្រាយ។ ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរអាចស្តែងក្រោមរូបភាពជាដីកាលើកលែងចោទប្រកាន់ ឬ ជាដីកាបញ្ជូនទៅជំនុំជម្រះ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ឱ្យជនត្រូវចោទបង់ប្រាក់ធានា ឬ ឱ្យប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬ ឱ្យប្រគល់អាវុធដែលមិនទាក់ទងនឹងបទល្មើស ត្រូវប្រគល់សងសាមីខ្លួនវិញដោយក្រឡាបញ្ជីដោយមានបង្កាន់ដៃទទួលដែលចុះហត្ថលេខាដោយជនត្រូវចោទទុកជាសម្គាល់។[175] ក៏ប៉ុន្តែ នៅក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅតែជាការចាំបាច់ នោះចៅក្រមស៊ើបសួរនៅតែអាចបន្តដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទៀតបាន ដោយតាមរយៈសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ហើយចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។[176]

[174] មាត្រា២៣០ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[175] មាត្រា២៤៩ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[176] មាត្រា២៤៩ កថាខណ្ឌទី៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវចងក្រងយ៉ាងលម្អិត និងស៊ីជម្រៅថែមទៀតនោះដែលទាក់ទងទៅនឹងប្រធានបទសារណានេះដែលស្តីអំពី «**វិធានការនិរន្តរាយ**» រួចមកនោះ ពិតជាបានបង្ហាញ និងឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីវិធានការនេះ និងការអនុវត្តដោយផ្ទាល់ពីសំណាក់ចៅក្រមស៊ើបសួរនៅក្នុងកិច្ចស៊ើបសួរ ដើម្បីឱ្យដំណើរការនីតិវិធីប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ដើម្បីបញ្ជាក់អំពីអង្គហេតុពិតនៃរឿងក្តីព្រហ្មទណ្ឌ ក៏ដូចជាបញ្ជាក់អំពីសិទ្ធិសេរីភាពរបស់ជនត្រូវចោទ ឬបុគ្គលដែលពាក់ព័ន្ធ។ វិធានការនិរន្តរាយនេះ បានស្តែងចេញនូវសកម្មភាពជាច្រើន ដូចជាការស្វែងរកភស្តុតាងសម្រាប់ដាក់បន្ទុក និងដោះបន្ទុក ក៏ដូចជាការបង្គាប់ឱ្យចូលខ្លួន ការបង្គាប់ឱ្យនាំខ្លួន ការបង្គាប់ឱ្យចាប់ខ្លួន ការបង្គាប់ឱ្យឃុំខ្លួន ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ស្ថិតឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលសុទ្ធសឹងតែជាប់ទាក់ទងនឹងសេរីភាពរបស់បុគ្គល។ នៅក្នុងនោះដែរការប្រើប្រាស់វិធានការនិរន្តរាយនៅក្នុងដំណើរការនៃនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌពិតជាមានសារៈសំខាន់ណាស់គឺដើម្បីឱ្យមានតម្លាភាព យុត្តិធម៌ និងភាពប្រាកដនិយមទៅលើដំណើការនៃនីតិវិធីដែលធ្វើយ៉ាងណាកុំឱ្យមានភាពអសកម្ម និងភាពលំបាកដែលទាក់ទងនឹងការអនុវត្តជាក់ស្តែង។ វិធានការនេះទៀតសោត ត្រូវបានចៅក្រមស៊ើបសួរអនុវត្តដើម្បីជាការងាយស្រួលក្នុងការស្វែងរកភស្តុតាងពិតប្រាកដសម្រាប់ដាក់ និងដោះបន្ទុកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

ជាងនេះទៅទៀតនោះ សម្រាប់វិធានការនេះត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌនៃការស៊ើបសួរសំដៅទៅលើការធានាដល់ការស៊ើបសួរឱ្យប្រព្រឹត្តទៅបានល្អ ហើយក្នុងការបំពេញភារកិច្ចរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ ដើម្បីស្វែងរកការពិត ក៏ច្បាប់បានប្រគល់សិទ្ធិអំណាចដែលមានលក្ខណៈបង្ខំមួយចំនួនដែលអាចប្រើប្រាស់ប្រឆាំងនឹងសេរីភាពរបស់ជនត្រូវចោទ។ ម្យ៉ាងទៀត ចៅក្រមស៊ើបសួរក៏អាចប្រើប្រាស់វិធានការមួយនេះទៅលើបុគ្គលដែលមិនព្រមឆ្លើយតបទៅនឹងការកោះហៅជាធម្មតារបស់ចៅក្រមស៊ើបសួរ។ ចំពោះដីកាទាំងនោះមានដូចជា ដីកាបង្គាប់ឱ្យចូលខ្លួន ដែលដីកានេះគោរពទៅតាមគោលការណ៍ស្ម័គ្រចិត្តរបស់ជនត្រូវចោទ ឬបុគ្គលដែលពាក់ព័ន្ធដោយពួកគេអាចចូល ឬមិនចូលតាមបង្គាប់នោះ។ រីឯដីកាបង្គាប់ឱ្យនាំខ្លួន ដីកានេះបានបញ្ជាទៅកងកម្លាំងសាធារណៈឱ្យចាប់និងនាំខ្លួនបុគ្គលដែលមានតម្រុយពិរុទ្ធភាព ដែលមានលក្ខណៈជាការចាប់បង្ខំទៅដល់បុគ្គលទាំងនោះ។ ឯដីកាបង្គាប់ឱ្យចាប់ខ្លួនវិញ ក៏មានលក្ខណៈចាប់បង្ខំដែរ ប៉ុន្តែដីកានេះអាចចេញទៅបានលុះត្រាតែជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពនោះ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម និងមិនដឹងថាបុគ្គលនោះស្ថិតនៅទីកន្លែងណាច្បាស់លាស់ ហើយដីកានេះជាការបញ្ជាទៅដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវ និងចាប់ខ្លួនបុគ្គលនោះ ដែលអានុភាពនៃដីកានេះអាចផ្សព្វផ្សាយជាអន្តរជាតិបានផងដែរតាមរយៈក្រសួងយុត្តិធម៌។ ចំពោះដីកាបង្គាប់ឱ្យឃុំខ្លួនវិញនោះ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ

មណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ ហើយដីកានេះអាចចេញបានលុះត្រាតែជនត្រូវចោទនោះជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ឬអាចនិយាយបានថាបន្ទាប់ពីចៅក្រមស៊ើបសួរបានចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរួចហើយ។

បន្ថែមពីនេះទៅទៀត ទោះបីជាចៅក្រមស៊ើបសួរមានសិទ្ធិពេញទីក្នុងការសម្រេចដាក់ជនត្រូវចោទក្រោមការឃុំខ្លួនបណ្ដោះអាសន្នក៏ដោយ ក៏ការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរត្រូវតែគោរពនូវសិទ្ធិសេរីភាពបុគ្គលក៏ដូចជាអាយុរបស់ជនត្រូវចោទនោះ រួមទាំងពិនិត្យទៅលើប្រភេទនៃបទល្មើសផងដែរ។ ចៅក្រមស៊ើបសួរក៏អាចសម្រេចឱ្យបុគ្គលដែលមានតម្រុយពិរុទ្ធភាពស្ថិតនៅក្រោមការត្រួតពិនិត្យតុលាការផងដែរ (ក្រៅឃុំ) ដោយមានការកំណត់កាតព្វកិច្ច ក៏ដូចជាបិទសិទ្ធិសេរីភាពរបស់បុគ្គលនោះមួយចំនួន។ ក្នុងករណីដែលមានការស្នើសុំដោះលែងជនត្រូវចោទ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរនេះ គឺអាចត្រូវធ្វើឡើងដោយតាមរយៈចៅក្រមស៊ើបសួរផ្ទាល់ ឬ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្ដឹងរបស់ជនត្រូវចោទ។ ជាពិសេសនោះ ការដោះលែងជនត្រូវចោទក៏អាចធ្វើដោយដីកាដំណោះស្រាយផងដែរ។ ចំពោះការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏មិនខុសពីការស្នើសុំដោះលែងជនត្រូវចោទដែរ ដោយអាចសម្រេចដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរផ្ទាល់ ឬតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្ដឹងរបស់ជនត្រូវចោទផងដែរ។

សរុបសេចក្ដីមក វិធានការនិរន្តរាយដែលប្រើប្រាស់ដោយចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរគឺមានអត្ថប្រយោជន៍ជាខ្លាំងនៅក្នុងវិស័យយុត្តិធម៌ ដោយបានធានាទៅដល់ការការពារបុគ្គលដែលជាជនរងគ្រោះ និងបុគ្គលដែលមានពិរុទ្ធភាព ដែលពួកគេនៅតែជាបុគ្គលគ្មានជាប់ទោសនៅឡើយទេ ក្នុងន័យនេះគឺថាបុគ្គលដែលមានតម្រុយពិរុទ្ធភាពពុំទាន់ត្រូវបានតុលាការប្រកាសទោសនៅឡើយទេ។ ម្យ៉ាងទៀតនោះ ដោយយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានបញ្ញត្តិថា ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។[177] ទោះបីជាចៅក្រមស៊ើបសួរបានទទួលនូវសិទ្ធិអំណាចក្នុងការចេញដីកាខាងលើនេះយ៉ាងណាក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវប្រើប្រាស់សិទ្ធិក្នុងការចេញដីកានេះ ដោយផ្អែកទៅលើគោលការណ៍អនាគតិ[178] (ភាពមិនលំអៀង)។

ជាចុងក្រោយ ដើម្បីចូលរួមក្នុងការរីកចម្រើនទៅមុខលើវិស័យយុត្តិធម៌នេះ យើងទាំងអស់គ្នាដែលជាប្រជាពលរដ្ឋគួរគប្បីត្រូវគោរពនូវវិធានច្បាប់ទាំងអស់គ្នា ដែលជាមាគ៌ាមួយក្នុងការទទួលបាននូវសុខសន្តិភាព ស្ថេរភាព និងមានសណ្ដាប់ធ្នាប់របៀបរៀបរយនៅក្នុងសង្គមជាតិ ក៏ដូចជានាំឱ្យសង្គមជាតិទាំងមូលមានការអភិវឌ្ឍន៍ផងដែរ។

---

[177] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[178] ប្រការ៧ ជំពូក៣ នៃក្រមសីលធម៌ចៅក្រម ឆ្នាំ២០០៧

# អនុសាសន៍

# អនុសាសន៍

ដោយបានឆ្លងកាត់ការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីពី **«វិធានការនិរន្តរាយ»** រួចមក ដោយក្នុងនាមយើងជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យើងខ្ញុំបានយល់ឃើញថានៅមានភាពខ្វះខាតមួយចំនួនដែលទាក់ទងទៅនឹងការបំពេញកិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ក៏ដូចជាការអនុវត្តវិធានការនិរន្តរាយដោយចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ។ អាស្រ័យហេតុនេះហើយ ជាកិច្ចចាប់ផ្តើម យើងខ្ញុំសូមធ្វើការសំណូមពរឱ្យប្រជាពលរដ្ឋ រួមទាំងសមត្ថកិច្ចទាំងអស់សហការចូលរួមជាមួយនឹងស្ថាប័នតុលាការនៅពេលដែលមានបទល្មើស ក៏ដូចជារឿងក្តីព្រហ្មទណ្ឌបានកើតឡើងដើម្បីធ្វើឱ្យដំណើរការនីតិវិធី ក៏ដូចជាដំណើរការកិច្ចស៊ើបសួរប្រព្រឹត្តទៅមុខដោយរលូន។ បន្ថែមពីនេះទៅទៀតនោះ ដើម្បីបង្ការបទល្មើស រួមទាំងស្វែងរកភាពយុត្តិធម៌ទៅដល់ជនរងគ្រោះ ក៏ដូចជាផ្តល់យុត្តិធម៌ដល់ជនល្មើសនៅពេលដែលចៅក្រមស៊ើបសួរប្រើប្រាស់វិធានការនិរន្តរាយក្នុងពេលដំណើរការកិច្ចស៊ើបសួរនោះ និងការធានាការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌនេះឱ្យមានប្រសិទ្ធភាពល្អ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍ ដែលអាចពង្រឹងដល់កិច្ចការរបស់ស្ថាប័នតុលាការ ក៏ដូចជាក្រសួងយុត្តិធម៌មួយចំនួនដូចខាងក្រោមនេះ៖

- បន្តពង្រឹងទៅលើវិស័យអប់រំក្នុងគោលបំណងដែលធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែខ្ពស់ហើយមានភាពខ្លាចរអាក្នុងការបំពានច្បាប់ដែលបានចែង ដើម្បីជាផ្លូវមួយអាចកាត់បន្ថយបទល្មើសដែលកើតឡើងជាយថាហេតុ និងគ្មានការប្រព្រឹត្តបទល្មើសណាមួយទៀត។
- បន្តបង្កើនការផ្សព្វផ្សាយច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានទូលំទូលាយ និងច្បាស់លាស់ទៅដល់មជ្ឈដ្ឋានទូទៅនិងប្រជាពលរដ្ឋទូទាំងប្រទេស។
- គប្បីជ្រើសរើសមន្ត្រីតុលាការដែលមានសមត្ថភាពពិតប្រាកដ និងចេះថ្លឹងថ្លែងនូវអ្វីត្រូវអ្វីខុស។
- ត្រូវមានការគោរពនូវសិទ្ធិសេរីភាពរបស់បុគ្គល ទោះបីគេជាជនសង្ស័យ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពក៏ដោយ គឺផ្អែកទៅលើគោលការណ៍សេរីភាពរបស់បុគ្គល ហើយបុគ្គលគ្រប់រូបសុទ្ធតែមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។
- ចៅក្រមស៊ើបសួរត្រូវធ្វើការវិនិច្ឆ័យឱ្យបានត្រឹមត្រូវនៅរាល់ពេលដែលចៅក្រមស៊ើបសួរប្រើប្រាស់នូវវិធានការនិរន្តរាយតាមរយៈការចេញដីកា ដើម្បីចៀសវាងក្នុងការបំពានសិទ្ធិសេរីភាពបុគ្គល។
- គប្បីពង្រឹងនូវការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈតាមរយៈការឃ្លាំមើល និងការដាក់ទណ្ឌកម្មទៅលើរាល់ការបំពានក្រមសីលធម៌របស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវី។

- សូមឱ្យចៅក្រមស៊ើបសួរគោរពនូវគោលការណ៍ទាំងឡាយ ដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឱ្យបានហ្មត់ចត់ក្នុងពេលដែលបំពេញបេសកម្មរបស់ខ្លួននៃដំណើរការនីតិវិធីព្រហ្មទណ្ឌ បើសិនបើមានតែច្បាប់មួយមុខនោះ ហើយគ្មានការអនុវត្តឱ្យបានល្អទេវានឹងបណ្តាលឱ្យមានភាពអយុត្តិធម៌។
- ចៅក្រមស៊ើបសួរគប្បីគោរពឱ្យបានខ្ជាប់ខ្ជួននូវការហាមឃាត់ទាំងឡាយណាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ក៏ដូចជាក្រមសីលធម៌ចៅក្រម។
- ជាងនេះទៅទៀតនោះ ជម្រុញឱ្យមានការសហការចូលរួមសរសេរសៀវភៅដែលពាក់ព័ន្ធទៅនឹងច្បាប់ពីសំណាក់សាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ រួមទាំងអ្នកប្រកបវិជ្ជាជីវៈមួយចំនួនដោយធ្វើការពន្យល់ឱ្យបានក្បោះក្បាយ និងមានភាពងាយស្រួលយល់ទៅដល់ប្រជាពលរដ្ឋ ក៏ដូចជាសិស្សនិស្សិត ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់ និងរួមកាត់បន្ថយអំពើជាបទល្មើសនានា។

# ឯកសារយោង

# ឯកសារយោង

## ក. លិខិតបទដ្ឋានគតិយុត្ត

### ១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

### ២. ក្រម

- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ៣. ច្បាប់

- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។
- ក្រមសីលធម៌ចៅក្រម ដែលអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម យល់ព្រមប្រកាសឱ្យប្រើនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧។

## ខ. ឯកសារស្រាវជ្រាវ

- លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** «**មេរៀននីតិវិធីព្រហ្មទណ្ឌ**» ឆ្នាំ២០១៣-២០១៤។
- លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** «**នីតិព្រហ្មទណ្ឌទូទៅ**» ឆ្នាំ២០១១។
- លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** «**នីតិព្រហ្មទណ្ឌនិងនីតិគ្រួសារ**» ឆ្នាំ២០១៧។
- វចនានុក្រមខ្មែរភាគ១-ភាគ២ របស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**។
- លោកមេធាវី **កែ វិសាល**, លោកមេធាវី **សេហា សុខឃី** និងលោកមេធាវី **ហេង ឮង** រួមទាំងកែសម្រួលដោយលោកមេធាវី **យឹម សារី** នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា «**នីតិវិធីនៃការអនុវត្តជាក់ស្តែងក្នុងរឿងក្តីព្រហ្មទណ្ឌ**» ឆ្នាំ២០១៤-២០១៥។

- សេចក្ដីពន្យល់ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា៖ សេចក្ដីពន្យល់ករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិសម្រាំង  ឆ្នាំ២០១៤។
- សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ ឆ្នាំ២០០៦ របស់ក្រសួងយុត្តិធម៌។
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០១៥ ស្ដីពីវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ។
- សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ (កិច្ចសហប្រត្តិការបារាំង គំរោងទ្រទ្រង់នីតិរដ្ឋ) ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

## គ. ឯកសារ និងប្រភពផ្សេងៗ

- ឯកឧត្តម **កើត រិទ្ធិ** និងឯកឧត្តម **ផូខ សំភី** រួមទាំងឯកឧត្តម **ម៉ឺន ហ៊ុន** វីដេអូឃ្លីបស្ដីពី « **កម្មវិធីការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៩** » របស់ទូរទស្សន៍ជាតិកម្ពុជា(ទទក) ចេញផ្សាយថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៨។
- តើ «អង្គសេចក្ដី» សំដៅលើអ្វីក្នុងភាសាច្បាប់? | ភ្នំពេញ ប៉ុស្ដិ៍ (postkhmer.com) ចេញផ្សាយនៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៦។
- តើអ្វីជា «ដីកាដំណោះស្រាយ» ហើយត្រូវប្រើពេលណា? | ភ្នំពេញ ប៉ុស្ដិ៍ (postkhmer.com) ចេញផ្សាយនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧។
- ដូចម្ដេចដែលហៅថា វិធានការនិរន្តរាយ (វិធានការទប់ស្កាត់ដើម្បីជៀងវាងផលប៉ះពាល់ ឬ ធានាដល់ដំណើរការនៃនីតិវិធី)? | PheakdeyLaw (pheakdeylaw.com) ចេញផ្សាយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៦។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី១** | ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ |
| **ឧបសម្ព័ន្ធទី២** | ដីកាបង្គាប់ឱ្យចូលខ្លួន |
| **ឧបសម្ព័ន្ធទី៣** | ដីកាបង្គាប់ឱ្យនាំខ្លួន |
| **ឧបសម្ព័ន្ធទី៤** | ដីកាបង្គាប់ឱ្យចាប់ខ្លួន |
| **ឧបសម្ព័ន្ធទី៥** | ដីកាបង្គាប់ឱ្យឃុំខ្លួន |
| **ឧបសម្ព័ន្ធទី៦** | ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី៧** | ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី៨** | ដីកាបញ្ជូនឱ្យឆ្លើយ |
| **ឧបសម្ព័ន្ធទី៩** | ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ |
| **ឧបសម្ព័ន្ធទី១០** | ដីកាសម្រេចពន្យារពេលនៃការឃុំខ្លួន បណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី១១** | ដីកាបង្គាប់ឱ្យពន្យារពេលការឃុំខ្លួន បណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី១២** | ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ |
| **ឧបសម្ព័ន្ធទី១៣** | ដីកាបង្គាប់ឱ្យដោះលែង |
| **ឧបសម្ព័ន្ធទី១៤** | ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ |
| **ឧបសម្ព័ន្ធទី១៥** | ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ |
| **ឧបសម្ព័ន្ធទី១៦** | ដីកាសម្រេចអនុញ្ញាតឱ្យជនត្រូវចោទ នៅក្រៅឃុំជាបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី១៧** | ដីកាដំណោះស្រាយ |
| **ឧបសម្ព័ន្ធទី១៨** | ដីការក្សាការឃុំខ្លួនបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី១៩** | ដីកាបញ្ជូន |
| **ឧបសម្ព័ន្ធទី២០** | ច្បាប់ស្តីពី«យុត្តិធម៌អនីតិជន» |

| | |
|---|---|
| **ឧបសម្ព័ន្ធទី២១** | ក្រមសីលធម៌ចៅក្រម |
| **ឧបសម្ព័ន្ធទី២២** | គោលការណ៍ណែនាំដែលទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| **ឧបសម្ព័ន្ធទី២៣** | ការដាក់ឱ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន |

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**

**អមសាលាដំបូងខេត្តបន្ទាយមានជ័យ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖

ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៩

លេខ: ..[illegible].. **អ.យ.ខ**

## <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ</u>

យើង តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-**បានឃើញ** របាយការណ៍លេខ: ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ការិយាល័យបទល្មើសព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ។

<u>ក្រោយពីបានពិនិត្យឯកសារខាងលើ</u>

<u>**យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា ៖**</u>

-នាមត្រកូល-នាមខ្លួន: ហៅ ភេទប្រុស កើតថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៧ សញ្ជាតិចិន ជនជាតិចិន មុខរបរ បុគ្គលិកកាស៊ីណូប្រ៉ោន សាសនាព្រះពុទ្ធ ទីកន្លែងកំណើតស្រុកZhi Po ខេត្ត Shang Tong ប្រទេសចិន អាសយដ្ឋានបច្ចុប្បន្នសណ្ឋាគារលី ភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់) នៅលីវ ជានីតិជន កំរិតវប្បធម៌ បរិញ្ញាប័ត្រនៅប្រទេសចិន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ **(មានខ្លួន)**

**បានប្រព្រឹត្តអំពើដូចតទៅ៖** កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង១០នាទី ស្ថិតនៅចំណុចផ្សារដើមពុទ្រា ភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានករណី **លួច(មានស្ថានទម្ងន់ទោស)** មួយកើតឡើង ដែលបង្កឡើងដោយជនសង្ស័យម្នាក់ឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជាជនជាតិចិន បានធ្វើសកម្មភាពយកកូនកាំបិតទៅឆ្វៀលបំពង់ករបស់ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ ៣៨ឆ្នាំ និងបានយកកាបូបលុយរបស់ជនរងគ្រោះដែលមានប្រាក់ចំនួន **៥៣៧៤០**(ប្រាំម៉ឺនបីពាន់ប្រាំពីររយសែសិប)បាត និងប្រាក់ចិន **៧៥៣៩**(ប្រាំពីរពាន់ប្រាំរយសាមសិបប្រាំបួន)យ័ន។ បន្ទាប់ពីធ្វើសកម្មភាពរួចហើយ ជនសង្ស័យព្យាយាមរត់គេចខ្លួន ប៉ុន្តែត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ដកហូតបានវត្ថុតាង ប្រាក់បាត **៥៣៧៤០**(ប្រាំម៉ឺនបីពាន់ប្រាំពីររយសែសិប)បាត និង

ប្រាក់ចិន **៧៥៣៩**(ប្រាំពីរពាន់ប្រាំរយសាមសិបប្រាំបួន)យ៉ន កាបូបស្ពាយពណ៌សូកូឡា ចំនួន ០១(មួយ) កាបូបស្ពាយពណ៌ខ្មៅ ចំនួន ០១(មួយ) និងកូនកាំបិតឯងជ័រពណ៌ខ្មៅចំនួន ០១(មួយ) ហើយបានកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

អំពើខាងលើជាបទល្មើស៖ **លួច(មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា)** ប្រព្រឹត្តនៅចំណុចផ្សារដើមពុទ្រា ភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិតាមមាត្រា**៣៥៣** និងមាត្រា**៣៥៧ ចំណុច១** នៃក្រមព្រហ្មទណ្ឌ។

បានឃើញមាត្រា៨៤ និងមាត្រា១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>សម្រេច</u>**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ ៖

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ

-ឈ្មោះ ហៅ ភេទប្រុស កើតថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៧

ពីបទ៖ **លួច(មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា)** ប្រព្រឹត្តនៅចំណុចផ្សារដើមពុទ្រា ភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិតាមមាត្រា**៣៥៣** និងមាត្រា**៣៥៧ ចំណុច១** នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

☑ ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នលើ

-ឈ្មោះ ហៅ ភេទប្រុស កើតថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៧ (មានខ្លួន)

ថ្ងៃអង្គារ ១១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩

**តំណាងអយ្យការ**

☐ ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា ជនត្រូវចោទមាន សិទ្ធិទទួលបានជំនួយពីមេធាវី តាមការជ្រើសរើសដោយខ្លួនឯង ឬពីមេធាវីតាមការចាត់តាំង ។

ជនត្រូវចោទ បានប្រកាសប្រាប់ថា:

☑ខ្ញុំបដិសេធជំនួយពីមេធាវី

☐ខ្ញុំចង់បានជំនួយពីមេធាវីម្នាក់

☐ លោក/លោកស្រីមេធាវី.................................... ត្រូវបានជូនដំណឹងដោយ លោកចៅក្រមស៊ើបសួរ លឹម សុគន្ធារ៉ា អាចពិគ្រោះមើលសំណុំរឿង ដែលទុកឲ្យគាត់ពិនិត្យ និងអាចសន្ទនាដោយសេរីជាមួយកូនក្តី របស់គាត់ ។

**ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន:**

☑ត្រូវបានធ្វើ

☐ត្រូវបានលើកទៅថ្ងៃទី........ខែ............ឆ្នាំ២០.......តាមសំណូមពររបស់.............................................។

តំណាងអយ្យការបានបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន ដូចខាងក្រោម:

[illegible]

[illegible]

[illegible]

ជនត្រូវចោទបានបង្ហាញសេចក្តីសង្កេតរបស់ខ្លួន ដូចខាងក្រោម:

ខ្ញុំបទឯកភាពតាមកាឃុំខ្លួនរបស់ព្រះរាជអាជ្ញា ព្រោះខ្ញុំពិតជាបានប្រព្រឹត្តិដូចការចោទប្រកាន់មែន។

លោក/លោកស្រីមេធាវី....................................................បានបង្ហាញសេចក្តីសន្និដ្ឋានការពារកូនក្តី របស់ខ្លួន ដូចខាងក្រោម:

.................................................................................................................................................

.................................................................................................................................................

☑យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដោយ មានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួន នៅថ្ងៃនេះ ។

☑យើងបានប្រាប់ជនត្រូវចោទ ឲ្យអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួនដែលយើងបានកត់ ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខានៅលើកំណត់ហេតុនេះ។

☑បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្តិតស្រាមដៃជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបាន ចុះហត្ថលេខាជាមួយយើង, ក្រឡាបញ្ជី និង អ្នកបកប្រែ។

| **ជនត្រូវចោទ** | **តំណាងអយ្យការ** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |
|---|---|---|---|

**ឧបសម្ព័ន្ធទី២**

គំរូដីកាបង្គាប់ឲ្យចូលខ្លួន៖

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត.............**

លេខអយ្យការ: ..........................

លេខស៊ើបសួរ: ..........................

លេខ:..........................

## ដីកាបង្គាប់ឲ្យចូលខ្លួន

**យើង .................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត............ ។**

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ .................... ចុះថ្ងៃទី .......... ខែ..........ឆ្នាំ ............ របស់តំណាងអយ្យការអមសាលាដំបូងខេត្ត .................... ដែលបើកការប្រឆាំងនឹងជនត្រូវចោទឈ្មោះ ...................... ពីបទៈ ....................... ប្រព្រឹត្តនៅភូមិ ......... ឃុំ ......... ស្រុក .......... ខេត្ត .......... កាលពីថ្ងៃទី........ ខែ.......... ឆ្នាំ......... បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា.......... នៃច្បាប់.............................. ។

## បង្គាប់មក

ឈ្មោះ **..................** ភេទ...... អាយុ........ រស់នៅភូមិ ........ ឃុំ.........ស្រុក.........ខេត្ត...................

**ឲ្យចូលមកកាន់សាលាដំបូងខេត្ត......................................** ។

- **នៅថ្ងៃទី** .................. **ខែ** ............. **ឆ្នាំ** ............ **វេលាម៉ោង** ........................... ជាកំណត់ ។
- **ដើម្បី** ឆ្លើយបំភ្លឺពីដំណើររឿងពាក់ព័ន្ធ និងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

សាមីខ្លួនត្រូវចូលមកបង្ហាញខ្លួនឲ្យទាន់ពេលវេលា តាមការកំណត់ខាងលើ និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងសំណុំរឿងខាងលើមកជាមួយផងប្រសិនបើមាន។

**ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើទេ យើងនិងចេញបញ្ជាឲ្យកម្លាំងសាធារណៈបង្ខំសាមីខ្លួនឲ្យចូលមកបង្ហាញខ្លួនតែ យើងចេញដីកាបង្គាប់ឲ្យនាំខ្លួន ។**

ធ្វើនៅ........... ថ្ងៃទី .......... ខែ .......... ឆ្នាំ..........

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

**ឧបសម្ព័ន្ធទី៣**

## គំរូដីកាបង្គាប់ឲ្យនាំខ្លួនៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត.............**

លេខអយ្យការ: ..........................

លេខស៊ើបសួរ: ..........................

លេខ:..........................

**ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ**

យើង ...................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត......................។

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រមក/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦០០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ...................... ចុះថ្ងៃទី ....... ខែ ........ ឆ្នាំ .......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត ............. ដែលបើកការប្រឆាំងនឹងជនត្រូវចោទ .............................. ពីបទៈ .................. ប្រព្រឹត្តនៅភូមិ ............ សង្កាត់ ......... ក្រុង .......... ខេត្ត ............ កាលពីថ្ងៃទី .......... ខែ ...... ឆ្នាំ .......... តាមបញ្ញត្តិមាត្រា ............ នៃច្បាប់............................................................ ។

យល់ឃើញថា ................................................................................................................ ។

យល់ឃើញថា ................................................................................................................ ។

យល់ឃើញថា ................................................................................................................ ។

**ហេតុដូច្នេះសម្រេច**

- បង្គាប់ឲ្យនាំខ្លួនឈ្មោះ ......................... ភេទ......... អាយុ........ឆ្នាំ កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ ....... មានទីកន្លែងកំណើតនៅភូមិ................ឃុំ.............ស្រុក................ខេត្ត.............. និងរស់នៅបច្ចុប្បន្ននៅភូមិ................ ឃុំ.............ស្រុក................ខេត្ត.............. ឪពុកឈ្មោះ .................... ម្តាយឈ្មោះ .................. មកកាន់សាលាដំបូងខេត្ត........................ ដើម្បីសាកសួរយកព័ត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។
- បង្គាប់មក **ភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់** អនុវត្តដីកានេះឲ្យបានសម្រេច ។

.................., ថ្ងៃទី............ខែ ......... ឆ្នាំ ..............

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

**ឧបសម្ព័ន្ធទី៤**

គំរូដីកាបង្គាប់ឲ្យចាប់ខ្លួន

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត.............**

លេខអយ្យការ: ...........................

លេខស៊ើបសួរ: ...........................

លេខ:..........................

## ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង **...............**ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត.....................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ .................... ចុះថ្ងៃទី ............. ខែ ........... ឆ្នាំ ..............។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ .............. ចុះថ្ងៃទី .............. ខែ .......... ឆ្នាំ ......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត............................ ។

បានឃើញដីកាបញ្ជូនឲ្យឆ្លើយលេខៈ ..................... ចុះថ្ងៃទី ........... ខែ .......... ឆ្នាំ .............. របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្ត......................................... ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់**

**យល់ឃើញថា**

- .......................................................................................................................................

-.......................................................................................................................................

-.........................................................................................................................................

## ហេតុដូច្នេះសម្រេច

១- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ឲ្យចាប់ និងនាំខ្លួនជនឈ្មោះ**..............**ភេទ.........ជាតិ........អាយុ.............ឆ្នាំ កើតនៅភូមិ....................ឃុំ.............ស្រុក.....................ខេត្ត...................... រស់នៅភូមិ................ឃុំ.................ស្រុក.....................ខេត្ត.................ឪពុកឈ្មោះ .............. ម្តាយឈ្មោះ .................. នៅលីវមានប្រពន្ធឈ្មោះ.........................ទោសពីមុន.................................................. ។

២- បង្គាប់ឲ្យប្រធានពន្ធនាគាខេត្តកំពង់ធំ ទទួលយកជននេះ រហូតដល់មានបទបញ្ជាកថ្មីសម្រេចផ្សេងពីនេះ ។

៣- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ ត្រូវអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់ ។

............., ថ្ងៃទី............ ខែ.......... ឆ្នាំ.............

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## ដីកាបង្គាប់ឱ្យឃុំខ្លួន

បន្ទប់ស៊ើបសួរ ________

លេខ ________ តព្រ.

យើង ______________________ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ២០៦, ២១៥, ២២០, ២២១ និងមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ____________________ ចុះថ្ងៃទី ______ ខែ ________ ឆ្នាំ ________

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ________________ ចុះថ្ងៃទី ____ ខែ ______ ឆ្នាំ ______

បានឃើញសំណុំរឿងស៊ើបសួរលេខ ____________________ ចុះថ្ងៃទី ______ ខែ ________ ឆ្នាំ ________

ដែលទាក់ទងនឹង :

នាមត្រកូល ________________ នាមខ្លួន ________________________ ភេទ ប្រុស/ស្រី អាយុ ______ ឆ្នាំ

កើតថ្ងៃទី __________ ខែ ____________ ឆ្នាំ __________ សញ្ជាតិ __________ សាសនា ________________

ទីកន្លែងកំណើតផ្ទះលេខ ______________ ផ្លូវ ____________ ក្រុម __________ ភូមិ ____________________

ឃុំ/សង្កាត់ ____________________ ស្រុក/ខណ្ឌ/ក្រុង ____________________ ខេត្ត/រាជធានី ______________

ទីលំនៅផ្ទះលេខ __________ ផ្លូវ ____________ ក្រុម ______ ភូមិ ________________ ឃុំ/សង្កាត់ ______________

ស្រុក/ខណ្ឌ/ក្រុង ______________ ខេត្ត/រាជធានី ___________ មុខរបរ ______________________________

នៅលីវ/ ប្តី/ ប្រពន្ធ ឈ្មោះ ________________________________________ (រ/ស) មានកូន ______________ នាក់

ឪពុកឈ្មោះ ________________________________ (រ/ស) ម្ដាយឈ្មោះ ________________________________ (រ/ស)

ចូល/ឃាត់/ចាប់ខ្លួន នៅថ្ងៃទី ________________ ខែ __________________ ឆ្នាំ ____________________

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ________________________________________________

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ____________________________________

____________________________________________________________ តាមមាត្រា ______________

នៃច្បាប់ ______________________________________________________________________ ។

បានឃើញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ____________ តព្រ. ចុះថ្ងៃទី _____ ខែ _____ ឆ្នាំ _______

### បង្គាប់

១. ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ________________ ទៅពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ____________ ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ។

២. ឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន __________ ទទួល និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣. ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

រាជធានីភ្នំពេញ, ថ្ងៃទី _____ ខែ ______ ឆ្នាំ ______

**ឧបសម្ព័ន្ធទី៦**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តបន្ទាយមានជ័យ**
សំណុំរឿងព្រហ្មទណ្ឌលេខ:
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩
សំណុំរឿងស៊ើបសួរលេខ:
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩
**លេខ:**

# <u>ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១៩ ដែលបើកការស៊ើបសួរលើ៖

១-ឈ្មោះ ភេទប្រុស ឆ្នាំកំណើត១៩៦៥ (អាយុ៥៤ឆ្នាំ) សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិផ្អាវ ឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិអណ្តូងថ្មមាស សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ (ស្លាប់) ម្តាយឈ្មោះ (ស្លាប់) មានប្រពន្ធឈ្មោះ មានកូនចំនួន១នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិស្ទឹងបត់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែមេសា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ តាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

បានឃើញ កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង។

បានឃើញ កំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី។

**I.ស្ថានភាពអង្គហេតុ និងអង្គច្បាប់**

១.ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ត្រូវបានចោទពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**។

២.ប្រព្រឹត្តនៅចំណុចភូមិស្ទឹងបត់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែមេសា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ តាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។(សង្ខេបអង្គហេតុនៃរឿងក្តី)

៣.តំណាងអយ្យការបានស្នើសុំឲ្យ ឃុំខ្លួន☑ មិនឃុំខ្លួន☐ បណ្តោះអាសន្នលើជនត្រូវចោទឈ្មោះ ភេទប្រុស ឆ្នាំកំណើត១៩៦៥ ផ្អែកលើសំអាងហេតុដូចតទៅ៖

-បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។

-ដើម្បីរក្សាទុកជនត្រូវចោទជូនតុលាការតាមនីតិវិធី។

-ដើម្បីរក្សាសណ្តាប់ធ្នាប់សារធារណៈ កុំឱ្យមានភាពច្របូលច្របល់ដែលបណ្តាលមកពីបទល្មើស។

៤.ជនត្រូវចោទ  ឬមេធាវីការពារស្នើសុំ(កូនក្តី) ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន☐ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ☐ ដោយមានសំអាងហេតុផល ថា៖ ខ្លួនដឹងកំហុសហើយ សូមតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

**II.សំអាងហេតុនៃសេចក្តីសម្រេច**

៥.ជនត្រូវចោទឈ្មោះ  ត្រូវបានចោទពីបទឧក្រិដ្ឋ ឬមជ្ឈឹម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី០១(មួយឆ្នាំ) (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦.(បញ្ចូលនូវការយល់ឃើញឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលលើកឡើងដោយភាគីមានដូចជាតំណាងអយ្យការ និងជនត្រូវចោទ ឬមេធាវីជនត្រូវចោទ ដោយពន្យល់សំអាងហេតុគាំទ្រទៅនឹងមូលហេតុនៃការឃុំខ្លួនចំនួនមួយឬច្រើនដែលមានចែក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

☐រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ

☐រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ការពារជនត្រូវចោទ

☑បង្ការបទល្មើសកុំឲ្យកើតជាថ្មី

☑ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

☐បញ្ចប់បទល្មើស

☐ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

-វិធានការដែលមានក្នុងមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការមានលក្ខណៈមិនធួនល្មម ដែលអាចធានាដើម្បីឱ្យជនត្រូវចោទមកបញ្ហាខ្លួនចំពោះកិច្ចនីតិវិធីរបស់តុលាការ។

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង នឹងអាចធានាឲ្យមានការបំពេញកិច្ចកាប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

-ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់តែមួយគត់ និងជាវិធានការចុងក្រោយក្នុងការរក្សាជនត្រូវចោទទុកជូនតុលាការ គប្បីសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះសម្រេច</u>**

ឃុំខ្លួនជនត្រូវចោទឈ្មោះ  ជាបណ្តោះអាសន្នរយៈពេលអតិបរមា។

ថ្ងៃ ព្រហស្បតិ៍ ២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**  **ចៅក្រមស៊ើបសួរ**

## លិខិតបញ្ជូន

យើង                    បានប្រគល់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខៈ
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩  របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ដល់ឈ្មោះដូចខាងក្រោមនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ។

**អ្នកប្រគល់**

អ្នកទទួល

**តំណាងអយ្យការ**   **មេធាវី**   **ជនត្រូវចោទ**

**ព្រះរាជអាជ្ញារង**

**សម្គាល់៖**   តាមរយៈការជូនដំណឹងជនត្រូវចោទ ត្រូវបានប្រាប់ថា៖

ជនត្រូវចោទមានសិទ្ធិប្តឹងឧទ្ធរណ៍នឹងដីកា សម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៦៧ និងមាត្រា២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**
ចៅក្រមបន្ទប់

# <u>ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន</u>

លេខៈ

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ

អមដោយលោក ជាក្រឡាបញ្ជី ។

**បាញឃើញៈ** មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**បានឃើញៈ** សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ។

**បានឃើញៈ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៩។

**បានឃើញៈ** សំណុំរឿងស៊ើបសួរលេខៈ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ។

ក្រោយពីបានសាកសួរចម្លើយជនត្រូវចោទចប់សព្វគ្រប់ និងពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## ហេតុដូច្នេះសម្រេច

មិនឃុំខ្លួនឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៦០ មុខរបរ យោធា សញ្ជាតិ ខ្មែរ ទីកន្លែងកំណើតនៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្ននៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ មានកូន០៤នាក់ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "ស្លាប់" ទោសពីមុន គ្មាន ។

ថ្ងៃពុធ ៩រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
បន្ទាយមានជ័យ, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩
**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

បានទទួលដំណឹង
ថ្ងៃ.............ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
បន្ទាយមានជ័យ ថ្ងៃទី.......ខែ..........ឆ្នាំ២០១៩
**ជ.ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**

លេខ

## ដីកាបញ្ជូនឱ្យឆ្លើយ

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ

បានឃើញ មាត្រា **២១៧** និងមាត្រា **២១៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១១៧៣ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១១៦២ អយខ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលកំណត់បុគ្គលរងនូវការស៊ើបសួរដូចខាងក្រោមៈ

.ឈ្មោះ ភេទប្រុស អាយុ ៣៧ឆ្នាំ (ក្នុងឃុំ) ជាជនត្រូវចោទនៅក្នុងការស៊ើបសួរពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិថ្មបាំង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៨ , ៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

**ទៅលោកស្រីព្រះរាជអាជ្ញារង ដើម្បីពិនិត្យ និង ធ្វើសេចក្តីសន្និដ្ឋាន ឬ ផ្តល់យោបល់លើៈ**

☑ ពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣៧ឆ្នាំ។

ថ្ងៃចន្ទ ១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅបន្ទាយមានជ័យ , ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩
**ចៅក្រមស៊ើបសួរ**

## យោបល់របស់ព្រះរាជអាជ្ញារង

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយខាងលើ

ក្រោយពីបានពិនិត្យសំណុំរឿងខាងលើចប់ ស្នើសុំ :

...........................................................................................................................

...........................................................................................................................

...........................................................................................................................

ថ្ងៃចន្ទ ១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅបន្ទាយមានជ័យ , ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩
**ជ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី៩**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ

សំណុំរឿងព្រហ្មទណ្ឌ

លេខ...............

លេខស៊ើបសួរ.......

## ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

យើង........................ចៅក្រមស៊ើបសួរនៃសាលាដំបូង................

បានឃើញមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានឃើញសំណុំរឿងស៊ើបសួរដែលទាក់ទងនឹង :

### ជនត្រូវចោទ

នាមត្រកូល..............នាមខ្លួន...........................

កើតថ្ងៃទី :...................................................

ទីកន្លែងកំណើត :..........................................

អាសយដ្ឋាន :..............................................

មុខរបរ :..................................................

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ឬប្តី............

សញ្ជាតិ :..................................................

ឪពុកឈ្មោះ................"រ-ស" ម្តាយឈ្មោះ..........."រ-ស

អនីតិជន ☐ ឬនីតិជន ☐

លោក លោកស្រី............................ជាមេធាវី

☐ **នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** : ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការលេខ........ ចុះថ្ងៃទី.......... ខែ............ ឆ្នាំ........

☐ **ជាប់ឃុំខ្លួន** : ដីកាសម្រេចឱ្យឃុំខ្លួនលេខ..........ចុះថ្ងៃទី និងដីកាបង្គាប់ឱ្យឃុំលេខ ............. ចុះថ្ងៃទី..... ខែ.......... ឆ្នាំ............

☐ **នៅក្រៅឃុំ**

### ដើមបណ្តឹងរដ្ឋប្បវេណី

នាមត្រកូល..............នាមខ្លួន............................

កើតថ្ងៃទី :...................................................

ទីកន្លែងកំណើត :............................................
អាសយដ្ឋាន :...............................................
មុខរបរ :...................................................
នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ឬប្ដី.............
សញ្ជាតិ :..................................................
ឪពុកឈ្មោះ................"រ-ស" ម្ដាយឈ្មោះ..........."រ-ស
អនីតិជន ☐ ឬនីតិជន ☐
លោក លោកស្រី...........................ជាមេធាវី

បញ្ជា ឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះ ទៅព្រះរាជអាជ្ញាដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬ ផ្ដល់យោបល់ទៅតាមនីតិវិធីនៃច្បាប់ ។

បានទទួលអនុវត្ត

**ក្រឡាបញ្ជី**

ធ្វើនៅ................ ថ្ងៃទី... ខែ.... ឆ្នាំ........

**ចៅក្រមស៊ើបសួរ**

**យោបល់របស់ព្រះរាជអាជ្ញា**

យើង.........................ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង..............

បានឃើញដីកាបញ្ជូនឱ្យឆ្លើយខាងលើ

បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ..................................

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្នើសុំ :

☐ ........................................................................

☐ ចោទប្រកាន់បន្ថែម តាមដីកាដែលមានភ្ជាប់ជាមួយ

☐ បន្តការស៊ើបសួរ

☐ បញ្ជូនសំណុំរឿងទៅសភាព្រហ្មទណ្ឌនៃសាលាដំបូង .....................

☐ លើកលែងការចោទប្រកាន់

☐ រក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្ដោះអាសន្ន

☐ ឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ

ធ្វើនៅ.............. ថ្ងៃទី... ខែ...... ឆ្នាំ..........

**ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី១០**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបន្ទាយមានជ័យ
មន្ទីរស៊ើបសួរ
លេខ:

# ដីកាសម្រេចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

(មាត្រា ២០៣, ២០៥, ២១១ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩។

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់យល់ឃើញថា:

ជនត្រូវចោទឈ្មោះ ភេទប្រុស (ឆ្នាំកំណើត១៩៨៦) ជនជាតិថៃ ទីកន្លែងកំណើតនៅឃុំអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ទីលំនៅបច្ចុប្បន្ននៅឃុំអារញ្ញ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ប្រពន្ធឈ្មោះ មានកូន១នាក់ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ) កម្រិតវប្បធម៌ថ្នាក់ទី៩ ជា អនីតិជន ☐ នីតិជន☑ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ មាន☐ គ្មាន☐ ។

ជននេះត្រូវដាក់នៅក្រោមការត្រួតពិនិត្យពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៨ រហូតដល់ថ្ងៃ១ ខែមករា ឆ្នាំ២០១៩ តាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-យល់ឃើញថា: ការពន្យាពេលនៃការឃុំខ្លួនជនត្រូវចោទមានមូលហេតុដូចខាងក្រោម៖

☐ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី

☐ រក្សាភស្តុតាង ឬតម្រុយជាសំភារៈ

☐ រារាំងកុំឱ្យមានការគាបសង្កត់សាក្សី ឬជនរងគ្រោះ

☐ រារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ ការពារជនត្រូវចោទ

☐ បង្ការបទល្មើសកុំឱ្យកើតជាថ្មី

☐ ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់តាមនីតិវិធី

☐ បញ្ចប់បទល្មើស

☐ ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស

**<u>ហេតុដូច្នេះសម្រេច</u>**

-<u>ពន្យាពេលនៃការឃុំខ្លួនលើជនត្រូវចោទ៖</u>

ជនត្រូវចោទឈ្មោះ                    ភេទប្រុស (ឆ្នាំកំណើត១៩៨៦) ជនជាតិថៃ, (អត្តសញ្ញាណដូចខាងលើ) ជាបណ្ដោះអាសន្នរហូតដល់មានសេចក្ដីសម្រេចពីចៅក្រមស៊ើបសួរ។

ថ្ងៃចន្ទ ១៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ

ថ្ងៃ........................ ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី.............. ខែកក្កដា ឆ្នាំ២០១៩

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

*******

**មន្ទីរស៊ើបសួរ**

លេខសំណុំរឿង:

លេខស៊ើបសួរ:

លេខ:...................................ពស.ព្រទ

**ដីកាបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ន**

(មាត្រា ២១៩ និង មាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

******

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ។

បានឃើញ សំណុំរឿងទាក់ទងនឹង:

ឈ្មោះ ភេទប្រុស សញ្ជាតិៈ ខ្មែរ
អាយុ ៤៥ ឆ្នាំ, ជាតិនិតជន ☑
ទីកន្លែងកំណើតភូមិក្បាលក្របី ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបាត់ដំបង
ទីលំនៅបច្ចុប្បន្នភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ
មុខរបរៈ ធ្វើស្រែ
☑ រៀបការប្រពន្ធឈ្មោះ -ស្លាប់-
ឪពុកឈ្មោះ -ស្លាប់- ម្ដាយឈ្មោះ -រស់-
ប្រវត្តិនៃផ្ដន្ទាទោសដោយតុលាការ គ្មាន

| | | | |
|---|---|---|---|
| ☑ជននេះ | ☑ចេះនិយាយ | ☑ចេះអាន | ☑ចេះសរសេរអក្សរខ្មែរ |
| ☐ជននេះ | ☐មិនចេះនិយាយ | ☐មិនចេះអាន | ☐មិនចេះសរសេរអក្សរខ្មែរ |

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ ឃាតកម្ម ប្រព្រឹត្តនៅភូមិដូនឡឹក ឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

បានឃើញមាត្រា២០៣, មាត្រា២០៤, មាត្រា២០៥, មាត្រា២០៦ និងមាត្រា២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥។

បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ។

បានឃើញ ដីកាសម្រេចពន្យាការឃុំខ្លួនបណ្ដោះអាសន្នរបស់យើង ចុះកាលបរិច្ឆេទថ្ងៃនេះ ។

**បង្គាប់មក**

-ប្រធានមន្ទីរឃុំឃាំងបន្តឃុំខ្លួនជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

-បង្គាប់ឲ្យគ្រប់ភ្នាក់ងារនៃកំលាំងសាធារណៈទាំងអស់ នៅពេលត្រូវបានបង្ហាញនេះ សហការអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់ ។

-ដីកានេះមានអនុភាពអនុវត្តបន្តឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទខាងលើ ចាប់ពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០១៦ តទៅ ។

បន្ទាយមានជ័យ, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**

មន្ទីរស៊ើបសួរអក្សរ
លេខ:....................

# <u>ដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យអមដោយលោក ជាក្រឡាបញ្ជី

បាញយើញ មាត្រា២១៥, ២១៦, ២១៧ និងមត្រា២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០១៧ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧ ។

បានឃើញ ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ របស់ជនត្រូវចោទឈ្មោះ ។

បានឃើញ យោបល់របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចុះថ្ងៃទី..........ខែ មិថុនា ឆ្នាំ២០១៧ ។

ក្រោយពីបានពីបានពិនិត្យពិចារណាលើសំណុំរឿងចប់សព្វគ្រប់ហើយ:

## <u>ហេតុដូច្នេះសម្រេច</u>

១. ដោះលែងជនត្រូវចោទឈ្មោះ ភេទប្រុស កើតឆ្នាំ២០០១ សញ្ជាតិ ខ្មែរ កើតនៅភូមិគោរង្គាន ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ សាសនា ព្រះពុទ្ធ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិគោរង្គាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នៅ លីវ ឪពុកឈ្មោះ “រស់” ម្ដាយឈ្មោះ “រស់” ទោសពីមុន គ្មាន ត្រូវចោទប្រកាន់ពីបទ: **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោស)** ប្រព្រឹត្តនៅចំណុចភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ **ឲ្យនៅក្រៅឃុំ** ។

២. បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តបន្ទាយមានជ័យ ដោះលែងជនត្រូវចោទដូចមានឈ្មោះខាងលើ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧ ប្រសិនបើជននេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

បានទទួលដំណឹង

បន្ទាយមានជ័យ, ថ្ងៃទី......ខែមិថុនា ឆ្នាំ២០១៧

បន្ទាយមានជ័យ, ថ្ងៃទី......ខែមិថុនា ឆ្នាំ២០១៧ **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ខ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី១៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**
មន្ទីរស៊ើបសួរអក្សរាយ
លេខ :...... /..........

# ដីកាបង្គាប់ឱ្យដោះលែង

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ:. ចុះថ្ងៃទី០៥ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេច:

ឱ្យដោះលែងនៅក្រៅឃុំឈ្មោះ ភេទប្រុស អាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើតភូមិឈើទាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ មានកូន០២នាក់ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "រស់" ប្រវត្តិនៃការផ្ដន្ទាទោសពីមុន: គ្មាន។

ត្រូវចោទឃុំពីបទ: លួច បទល្មើសដែលត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិចាន់គិរី សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩។**

បង្គាប់មកលោកប្រធានពន្ធនាគារខេត្តបន្ទាយមានជ័យ ឱ្យដោះលែងឈ្មោះ ភេទប្រុស (អត្តសញ្ញាណខាងលើ) ជាបន្ទាន់ ប្រសិនបើឈ្មោះនេះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

បន្ទាយមានជ័យ ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ២០១៩

**[illegible]ចៅក្រមស៊ើបសួរ**

**យើង**............................................................ ប្រធានមន្ទីរឃុំឃាំងខេត្តបន្ទាយមានជ័យ បានដោះលែងឈ្មោះ... ................................... ឃុំខ្លួនលេខ............. ចុះថ្ងៃទី.......... ខែ........... ឆ្នាំ.......... ពីបទ .... ........................................................................................................ ............ ប្រព្រឹត្តនៅភូមិ............. ..... ឃុំ................. ស្រុក........................ ខេត្ត........................... កាលពីថ្ងៃទី.......... ខែ......... ឆ្នាំ.......... តាមអំណាចដីកនេះ កាលពីថ្ងៃទី............ ខែ...... ..... ឆ្នាំ ............. រួចហើយ។

**<u>សំគាល់</u>**៖ ឈ្មោះនេះ បានឃុំខ្លួនផ្សេងពីបទ ...................................................... ............ កាលពីថ្ងៃទី............ខែ.......... ឆ្នាំ................ត្រង់លេខខ្លួន......................................... ............ (បើគ្មានដាក់ថាគ្មាន)

ធ្វើនៅ............................ ថ្ងៃទី......... ខែ.......... ឆ្នាំ.. ............

**ប្រធានមន្ទីរឃុំឃាំង**

**ឧបសម្ព័ន្ធទី១៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**
ចៅក្រមបន្ទប់

លេខ:.......................

# <u>ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ

អមដោយលោក ជាក្រឡាបញ្ជី ។

**បានឃើញ:** សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ ។

**បានឃើញ:** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩ ។

**បានឃើញ:** សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ ។

**បានឃើញ:** ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ ។

**បានឃើញ:** ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ ។

**បានឃើញ:** ពាក្យស្នើសុំឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ របស់ឈ្មោះ ។

**បានឃើញ:** ដីកាបញ្ជូនឲ្យឆ្លើយលេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ។

**បានឃើញ:** យោបល់របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ ។

## សំអាងហេតុ

១.យល់ឃើញថា: តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩, ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ និងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ឃើញថា: ជនត្រូវចោទឈ្មោះ ភេទប្រុស ត្រូវបានចៅក្រមសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ និងឃុំខ្លួនបណ្ដោះអាសន្នពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចកាស៊ីណូអ័រគីដេ ស្ថិតនៅក្នុងភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ បទល្មើសមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ។ បន្ទាប់ពីជាប់ឃុំបណ្ដោះអាសន្នជនត្រូវចោទឈ្មោះ បានដាក់ពាក្យសុំមកចៅក្រមស៊ើបសួរឲ្យដោះលែងខ្លួននៅក្រៅឃុំបណ្ដោះអាសន្នវិញ យោងតាមពាក្យឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ។ ឃើញថា: ពាក្យស្នើសុំឲ្យនៅក្រៅឃុំបណ្ដោះអាសន្នរបស់ជនត្រូវចោទឈ្មោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមមាត្រា២១៧

និងមាត្រា២៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យចៅក្រមស៊ើបសួរលើកយកមកពិនិត្យ និងសម្រេចតាមច្បាប់បាន ។

**២.យល់ឃើញថា:** ការឃុំខ្លួនបណ្តោះអាសន្នលើ ជនត្រូវចោទឈ្មោះ ជាការចាំបាច់ ដើម្បីធានារក្សាវត្តមានជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី និងធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ដើម្បីធានាឲ្យការស៊ើបសួរដំណើការបានល្អ និងរលូន ។

**៣.យល់ឃើញថា:** តាមចម្លើយរបស់ជនត្រូវចោទ និងភស្តុតាងនានាក្នុងសំណុំរឿង ឃើញថា: ជនត្រូវចោទគ្មានទីលំនៅច្បាស់លាស់នោះទេ ដោយជនត្រូវចោទគ្រាន់តែជាបុគ្គលិកកាស៊ីណូ ជួលបន្ទប់ដើម្បីស្នាក់នៅប៉ុណ្ណោះ ។ ហេតុដូចនេះ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ អាចឲ្យជនត្រូវចោទគេចខ្លួនទៅរស់នៅកន្លែងផ្សេង ដោយមិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ហើយម្យ៉ាងទៀតនឹងធ្វើឲ្យតុលាការពិបាកក្នុងការកោះហៅជនត្រូវចោទបាន ជាហេតុធ្វើឲ្យនីតិវិធីរបស់តុលាការមិនអាចដំណើការទៅបានដោយរលូន ។

**៤.យល់ឃើញថា:** ជនត្រូវចោទមិនបានសងសំណងការខូចខាតទៅឲ្យជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ប្រសិនបើដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ អាចបណ្តាលឲ្យជនត្រូវចោទរត់គេចខ្លួនដោយមិនសងសំណងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលជាហេតុនាំខូចប្រយោជន៍របស់ដើមណ្តឹងរដ្ឋប្បវេណីដែលជាអ្នកទទួលរងនូវព្យសនកម្ម ។

**៥.យល់ឃើញថា:** តាមដីកាបញ្ជូនឲ្យឆ្លើយលេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ បានផ្តល់យោបល់ជូនចៅក្រមស៊ើបសួរថា: គប្បីទុកជូនចៅក្រមជំនុំជម្រះសម្រេចអំពី ទោស និងសំណងរដ្ឋប្បវេណីឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ដូចនេះស្នើសុំចៅក្រមស៊ើបសួរបដិសេធអំពីសំណើរនៅចៅក្រមនេះសិនតាមនីតិវិធី ។ ឃើញថា: យោបល់របស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវ តាមអង្គហេតុ អង្គច្បាប់ និងភស្តុតាងនានាក្នុងសំណុំរឿង ។ គប្បីចៅក្រមស៊ើបសួរសម្រេចតាមការផ្តល់យោបល់នេះ ។

**៦.យល់ឃើញថា:** មូលហេតុនៃការឃុំខ្លួនជនត្រូវចោទ យោងតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាការចាំបាច់ ។ ចំពោះការតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ យោងតាមមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនធ្ងួនល្មមសម្រាប់អនុវត្តលើ ជនត្រូវចោទរូបនេះទេ ។

**៧.យល់ឃើញថា:** តាមសំអាងហេតុខាងលើ គប្បីចៅក្រមស៊ើបសួរមិនសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ តាមពាក្យស្នើសុំរបស់ជនត្រូវចោទនោះឡើយ ។

## <u>ហេតុដូច្នេះសម្រេច</u>

១/.មិនព្រមដោះលែងឲ្យនៅក្រៅឃុំលើ ជនត្រូវចោទឈ្មោះ ភេទប្រុស សញ្ជាតិ ខ្មែរ កើតថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ មុខរបរ បុគ្គលិកកាស៊ីណូ ទីកន្លែងកំណើតនៅភូមិដូង ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅបន្ទប់ជួល ក្នុងភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុង

ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅ លីវ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "រស់" ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុនៈ គ្មាន ។

ដែលបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចកាស៊ីណូអ័រគីដេ ស្ថិតនៅក្នុងភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ បទល្មើសមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ តាមពាក្យសុំរបស់ជនត្រូវចោទនោះទេ ។

២/.បង្គាប់ឲ្យក្រឡាបញ្ជីជូនដំណឹងទៅជនត្រូវចោទ ដើម្បីជ្រាប និងអាចប្រើសិទ្ធិប្ដឹងឧទ្ធរណ៍តាមច្បាប់ ។

បានទទួលដំណឹង

ថ្ងៃ.....................ខែចេត្រ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២

បន្ទាយមានជ័យ, ថ្ងៃទី......ខែមីនា ឆ្នាំ២០១៩

**ជ.ព្រះរាជអាជ្ញា**

ថ្ងៃ..............................ខែចេត្រ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២

បន្ទាយមានជ័យ, ថ្ងៃទី......ខែមេសា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**

មន្ទីរស៊ើបសួរអក្សរ

លេខ

# **ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ

**បានឃើញ** មាត្រា២២៣ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ ។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០១៨ ។

**បានឃើញ** សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ដែលទាក់ទងទៅនឹង:

- ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរ កម្មករសំណង់ កើតនៅភូមិគោកអំពិល ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរប្រាសាទ ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅចំណុចភូមិពោធិ៍ពីរដើម ឃុំរហាត់ទឹក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ បទល្មើសមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ ។

## **យល់ឃើញថា**

-ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ១៥ឆ្នាំ ត្រូវបានសម្រេចមិនឃុំខ្លួន ។ តែដើម្បីរក្សាអោយជនត្រូវចោទមានវត្តមាន បង្ហាញមុខនៅចំពោះតុលាការ នៃនីតិវិធីបន្តបន្ទាប់ទៀត គម្បីដាក់ជនត្រូវចោទ ឈ្មោះ អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## **ហេតុដូច្នេះសម្រេច**

១.ដាក់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ១៥ឆ្នាំ សញ្ជាតិ ខ្មែរ ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

២.បង្គាប់ឲ្យជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ សញ្ជាតិ ខ្មែរ ...រពន្ធរកាតព្វកិច្ចដូចខាងក្រោម:

- មិនត្រូវធ្វើដំណើរចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។
- មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

- ត្រូវចូលបង្ហាញខ្លួននៅ ប៉ុស្តិ៍នគរបាលឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មួយ ខែម្តង គឺនៅរាល់ថ្ងៃទី០១ នៃខែនីមួយៗ ។

- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៣.ក្នុងករណីដែលជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ សញ្ជាតិ ខ្មែរ គេចវេះដោយចេតនា មិនគោរពតាមកាតព្វកិច្ចខាងលើ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នវិញបាន ដោយ អនុវត្តតាមមាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

បន្ទាយមានជ័យ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹង

ថ្ងៃ... .............ខែ.........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

បន្ទាយមានជ័យ, ថ្ងៃទី......ខែ.............ឆ្នាំ២០១៩

**ជ.ព្រះរាជអាជ្ញា**

.............................................

.............................................

**ជនត្រូវចោទ**

**ឧបសម្ព័ន្ធទី១៦**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

មន្ទីរស៊ើបសួរ (      )

លេខ ៖

## ដីកាសម្រេចអនុញ្ញាត
## ឲ្យជនត្រូវចោទនៅក្រៅឃុំជាបណ្ដោះអាសន្ន

*យើង                    ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ។*

***បានឃើញ*** *ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។*

***បានឃើញ*** *សំណុំរឿងព្រហ្មទណ្ឌលេខ        ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧។*

***បានឃើញ*** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ        ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧។*

***បានឃើញ*** *សំណុំរឿងស៊ើបសួរលេខ        ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧*

***បានឃើញ*** *ដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នលេខ        ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧*

***បានឃើញ*** *ដីកាបង្គាប់ឲ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ        ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧។*

***បានឃើញ*** *យោបល់របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ លើដីកាបញ្ជូនឲ្យឆ្លើយលេខ        ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។*

***ក្រោយពីបានពិនិត្យសំណុំរឿង និងពាក្យសុំនេះចប់សព្វគ្រប់ហើយ យល់ឃើញថា ៖***

*- ជនត្រូវចោទខាងលើត្រូវបានចោទប្រកាន់ពីបទ មជ្ឈិម (ឆបោក)។*

*- ក្នុងសំណុំរឿងនេះ បានដោះស្រាយគ្នាសំណងរដ្ឋប្បវេណីចប់សព្វគ្រប់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលជាប្រពន្ធរបស់ជនរងគ្រោះ ក៏បានចូលឆ្លើយបំភ្លឺ និងដកពាក្យបណ្ដឹងវិញផងដែរ ។*

*- ការស៊ើបសួរមានលក្ខណៈ        បើឲ្យជនត្រូវចោទបាននៅក្រៅឃុំក៏មិនមានការបារម្ភណ៍ពីផលប៉ះពាល់ដល់កិច្ចនីតិវិធីដែរ។*

*- កាតព្វកិច្ចនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានលក្ខណៈជួនល្មម ក្នុងការធានារក្សាជនត្រូវចោទក្នុងការបង្ហាញខ្លួនចំពោះមុខតុលាការបាន។*

## ហេតុដូច្នេះសម្រេច

*ឲ្យជនត្រូវចោទដែលមានឈ្មោះ        ភេទប្រុស អាយុ៣៣ឆ្នាំ ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្នតាមដីកាបង្គាប់ឲ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ ៦៦៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បាននៅក្រៅឃុំជាបណ្ដោះអាសន្ន។*

*បន្ទាយមានជ័យ, ថ្ងៃទី........... ខែតុលា ឆ្នាំ២០១៧*

*លេខ.....................*

**ក្រឡាបញ្ជី**                    **ចៅក្រមស៊ើបសួរ**

..................................................

*បន្ទាយមានជ័យ, ថ្ងៃទី.......... ខែតុលា ឆ្នាំ២០១៧*

**ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី១៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

## ដីកាដំណោះស្រាយ

លេខ:.............. "ធ" ដ.ដ

យើង ..................ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី ................ជាក្រឡាបញ្ជី

**-បានឃើញ** មាត្រា ២៤៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៥៧, មាត្រា ២៦៨ មាត្រា ៣៧២,មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២៥០ និងមាត្រាដែលពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ១៤០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៩៥២ អ.យ.ផ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ។

**-បានឃើញ** សំណុំរឿងស៊ើបសួរលេខ ៨៤៩ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ២៣០០ អ.យ.ផ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ របស់តំណាង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចចោទប្រកាន់លើ៖

១.នាមត្រកូល-នាមខ្លួន ............................ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ អ្នកគិតលុយនៅផ្ទះសំណាក់ឌីដា ទីកន្លែងកំណើត................................... ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមជ្ឈមណ្ឌលកុមារកំព្រាកុលាបទី៤ ផ្លូវលេខ២៧១ ភូមិទី១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ ............"រស់" ម្ដាយឈ្មោះ ..........."រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

ពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រោយសាលសន្និសិទ្ធចតុមុខ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.នាមត្រកូល-នាមខ្លួន **បុរសមិនស្គាល់អត្តសញ្ញាណ ភេទប្រុស អាយុប្រហែល ៣៥ឆ្នាំ ។ (គេចខ្លួន)**

ពីបទ៖ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រោយសាលសន្និសិទ្ធចតុមុខ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា **៤២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

<u>**សំអាងហេតុ**</u>

-បានឃើញរបាយការណ៍សំយោគលេខ ០៣៩/២០១៧ រ.ប.ក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ជនត្រូវចោទឈ្មោះ ........... ហៅ ភេទប្រុស អាយុ ១៩ឆ្នាំ ពិតជាបាន **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន។

-ជនត្រូវចោទឈ្មោះ......... ហៅ បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលប្រហាក់ប្រហែលគ្នាថា៖ ខ្លួនពិតជាបានរក្សាទុកគ្រឿងញៀនចំនួន០១កញ្ចប់តូច ដែលបុរសម្នាក់ឲ្យមកខ្លួនពិតប្រាកដមែន តែត្រូវសមត្ថកិច្ចត្រួតពិនិត្យឆែកឆេរឃើញ ។

-ផ្អែកតាមរបាយការណ៍សំយោគលេខ ០៣៩/២០១៧ រ.ប.ក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងតាមចម្លើយសារភាព របស់ជនត្រូចចោទ ព្រមទាំងឯកសារមួយចំនួនដែលទាក់ទងនឹងសំណុំរឿង អាចសន្និដ្ឋានថា៖ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ ពិតជាមានបទល្មើស **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តដោយជនត្រូវចោទ ឈ្មោះ ..............**ហៅ** ភេទប្រុស អាយុ ១៩ឆ្នាំ និងបទល្មើស **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយ បុរសមិនស្គាល់អត្តសញ្ញាណ** ប្រព្រឹត្តនៅក្រោយសាលសន្និសិទ្ធចតុមុខ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពិតប្រាកដមែន។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងរបៀបរៀបរយសាធារណៈ ដែលច្បាប់បានការពារ និងតម្រូវឲ្យផ្តន្ទាទោស ។

-មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនត្រូវចោទឈ្មោះ ...........**ហៅ** ភេទប្រុស អាយុ ១៩ឆ្នាំ ពីបទៈ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និង ជនមិនស្គាល់អត្តសញ្ញាណ ពីបទៈ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រោយសាលសន្និសិទ្ធចតុមុខ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៧ តាមបញ្ញត្តិមាត្រា **៩០ និងមាត្រា ៩២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-**ជនត្រូវចោទ ជនមិនស្គាល់អត្តសញ្ញាណ** ក្រោយពីបានស៊ើបសួរការស្រាវជ្រាវរួចមក នៅតែរកមិនឃើញអត្តសញ្ញាណ និងគ្មានសាវតាជាតិ គប្បីចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់តាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧, មាត្រា២៦៩, និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-តំណាងអយ្យការប្តឹងសុំឲ្យចៅក្រមស៊ើបសួរ សម្រេចបញ្ជូនជនត្រូវចោទឈ្មោះ ............. **ហៅ ភេទប្រុស អាយុ ១៩ឆ្នាំ** ទៅជំនុំជម្រះ និងសម្រេចលើកលែងចោទប្រកាន់លើ **ជនមិនស្គាល់អត្តសញ្ញាណ** ដោយហេតុថាគ្មានសាវតាជាតិ។

# **ហេតុដូច្នេះសម្រេច**

១.បញ្ជូនជនត្រូវចោទឈ្មោះ          ហៅ     ភេទប្រុស អាយុ ១៩ឆ្នាំ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

២.រក្សាជនត្រូវចោទឈ្មោះ          ហៅ     ភេទប្រុស អាយុ ១៩ឆ្នាំ ក្នុងពន្ធនាគារបន្តរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។

៣.លើកលែងចោទប្រកាន់លើ **ជនមិនស្គាល់អត្តសញ្ញាណ** ដោយហេតុថាគ្មានសារតាជាតិ ពីបទ: **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រោយសាលសន្និសិទ្ធចតុមុខ ផ្លូវព្រះស៊ីសុវត្ថិ ភូមិទី១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា **៩២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

លេខ:................អ.យ.ជ                    រាជធានីភ្នំពេញ, ថ្ងៃទី...... ខែមិថុនា ឆ្នាំ២០១៧

បានទទួលដំណឹង                    **ក្រឡាបញ្ជី**                    **ចៅក្រមស៊ើបសួរ**

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែមិថុនា ឆ្នាំ២០១៧

**ជ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី១៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង ..............................
បន្ទប់ស៊ើបសួរទី
សំណុំរឿងព្រហ្មទណ្ឌលេខ ..........
ចុះថ្ងៃទី ........ខែ .............ឆ្នាំ............
លេខស៊ើបសួរ ...............................
លេខ ..................................................

## ដីការក្សាការឃុំខ្លួនបណ្ដោះអាសន្ន

( មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

យើង.....................................ចៅក្រមស៊ើបសួរ នៃសាលាដំបូង ................................
បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ .................ចុះថ្ងៃទី ...................
បានឃើញ សំណុំរឿងស៊ើបសួរទាក់ទងនឹងជនត្រូវចោទ:
ឈ្មោះ ...................................ភេទ .........ជាតិ .......................កើតនៅថ្ងៃទី .....................
នៅភូមិ ..................ឃុំ/សង្កាត់ ...................ស្រុក/ខណ្ឌ .....................ខេត្ត/រាជធានី ........................
កំរិតវប្បធម៌ ..............................មុខរបរ ..............................ទីលំនៅបច្ចុប្បន្ននៅភូមិ .....................
ឃុំ/សង្កាត់ ..............................ស្រុក/ខ័ណ្ឌ ................................ខេត្ត/រាជធានី ..........................
ប្ដី ឬ ប្រពន្ធឈ្មោះ ..................................មានកូន ........នាក់ ឪពុកឈ្មោះ ..............................។-ស៊
ម្ដាយឈ្មោះ .....................................។-ស៊ ទោសពីមុន ..........................................................
ជននេះត្រូវបានដាក់អោយស្ថិតនៅក្រោមការពិនិត្យពីបទ: .......................................តាមមាត្រា..........
នៃ ...........................................................ប្រព្រឹត្តនៅ ភូមិ ......................ឃុំ/សង្កាត់ ................
ស្រុក/ខ័ណ្ឌ .............................ខេត្ត/រាជធានី .....................កាលពីថ្ងៃទី ............ខែ............ឆ្នាំ.........
បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ..........................................ចុះថ្ងៃទី ............ខែ............ឆ្នាំ.........
បានឃើញ ដីកាដំណោះស្រាយលេខ ..........................................ចុះថ្ងៃទី ............ខែ............ឆ្នាំ.........

### យល់ឃើញថា

- ជននេះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសស្មើ ឬលើសពី ០១ឆ្នាំ។
- កាតព្វកិច្ចទាំងឡាយនៃការត្រួតពិនិត្យតាមផ្លូវតុលាការមានលក្ខណ:មិនគ្រប់គ្រាន់ ដោយធៀបនឹងគោលដៅ ដែលមានចែងក្នុងមាត្រា ២០៣ និង ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ គឺជាមធ្យោបាយតែមួយគត់ដើម្បី:
  - □ ក្សោភស្តុតាង ឬតម្រុយជាសំភារ:
  - □ រាំងកុំអោយមានការគាបសង្កត់សាក្សី ឬជនរងគ្រោះ

.............................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................

**ឧបសម្ព័ន្ធទី១៩**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ
មន្ទីរស៊ើបសួរ
លេខ:.............លច/ដ

## ដីកាបញ្ជូន

### ផ្ញើជូន: លោកប្រធានពន្ធនាគារ ខេត្តបន្ទាយមានជ័យ

| ល.រ | ឈ្មោះឯកសារ | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាពន្យាការឃុំខ្លួនបណ្ដោះអាសន្នបន្ត<br>ឈ្មោះ<br>ឈ្មោះ | <br>០២ សន្លឹក<br>០២ សន្លឹក | ដើម្បី<br>ចាត់ការ<br>តាមនីតិវិធី ។ |
| | សរុប | ០៤ សន្លឹក | |

ថ្ងៃចន្ទ ១៤រោចខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
មន្ទាយមានជ័យ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩
**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី២០


រដ្ឋសភា
ចូល
លេខ..........
ថ្ងៃទី..........ឆ្នាំ..........ម៉ោង..........
បញ្ជូនទៅ..........


# ច្បាប់

## ស្តីពី

# យុត្តិធម៌អនីតិជន


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៣
## ការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់អនីតិជន

### មាត្រា ៧.– ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។



### មាត្រា ៨.– ការ ទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃ កថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

### មាត្រា ៩.– ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

## ជំពូកទី ៧
## ការស៊ើបសួរ

### មាត្រា ៣១.- សមត្ថកិច្ចនៃការស៊ើបសួរ

ការស៊ើបសួរករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន ។

### មាត្រា ៣២.- ការបើកការស៊ើបសួរ

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ។

ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

### មាត្រា ៣៣.- ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ៣៤.- ការផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជន

ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។

## មាត្រា ៣៥.- ការស្តាប់ចម្លើយអនីតិជន

ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច ។

ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ ។

ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានការស្នើសុំ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ៣៦.- ការលើកពេលស្តាប់ចម្លើយ

ក្នុងករណីអវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃការបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

វត្តមាន ឬអវត្តមានរបស់មេធាវី មិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនបណ្តោះអាសន្នឡើយ ។

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងារ របស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជក អាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណីតុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ជាវិធានការចុងក្រោយ ។

បន្ថែមលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ ប្រសិនបើមាន ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ៤០.- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងរ...ថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិ...លដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួស...ម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប ។

## មាត្រា ៤១.- ការដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជនអាចសុំឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។

## មាត្រា ៤២.- ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

... នឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ ... ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ ក្នុងករណីរបាយការណ៍

ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលខ្ទុទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

### មាត្រា ៤៣.- ការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្វែររបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជន ។

## ជំពូកទី ៨
## សមត្ថកិច្ចរបស់សាលាដំបូង

### មាត្រា ៤៤.- សមត្ថកិច្ចនៃការជំនុំជម្រះ

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន ជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។

សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទលហុ ។



៥០/

**ឧបសម្ព័ន្ធទី២១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌ចៅក្រម

អនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧

បោះពុម្ពផ្សព្វផ្សាយដោយតុលាការកំពូល

## ជំពូកទី៣

## គោលការណ៍ អនាគតិ (ភាពមិនលំអៀង)

ប្រការ ៧ : គោលការណ៍

ប្រការ ៨ : អាកប្បកិរិយា និង ការធ្វើសវនាការ .

ប្រការ ៩ : ការស៊ើបអង្កេត ឬ ស៊ើបសួររឿងក្តី ការប្រាស្រ័យទាក់ទងជាមួយភាគីនៃរឿងក្តី

ប្រការ ១០ : ទំនាក់ទំនង វិជ្ជាជីវៈ សង្គម និង គ្រួសារ

ប្រការ ១១ : សកម្មភាពពាណិជ្ជកម្ម

ប្រការ ១២ : សកម្មភាពសង្គម និង មនុស្សធម៌

ប្រការ ១៣ : ការផ្តល់សេវាកម្មច្បាប់ និង កិច្ចការច្បាប់

ប្រការ ១៤ : អត្ថប្រយោជន៍ហិរញ្ញវត្ថុ

ប្រការ ១៥ : ការនិយាយស្តីនៅទីសាធារណៈរបស់ចៅក្រម ក្នុងនាមជាបុគ្គល

ប្រការ ១៦ : ការអប់រំផ្នែកច្បាប់

ប្រការ ១៧ : ការដកខ្លួនរបស់ ចៅក្រម

## ជំពូកទី៣

## គោលការណ៍ អនាគតិ (ភាពមិនលំអៀង)

**ប្រការ៧ : គោលការណ៍**

ចៅក្រមត្រូវមានអាកប្បកិរិយា ទាំងក្នុង និង ក្រៅតុលាការនូវលក្ខណៈអនាគតិរបស់ខ្លួនដើម្បីការពារថែរក្សា និង លើកកំពស់ជំនឿទុកចិត្តពីសំណាក់សាធារណៈជន អ្នកមានវិជ្ជាជីវៈច្បាប់ និង ភាគីវិវាទ ។

ចៅក្រមមិនត្រូវចូលរួមពិភាក្សាជាសាធារណៈ ពាក់ព័ន្ធទៅនឹងបញ្ហា ដែលអាចមាននៅតុលាការឡើយ ព្រោះវាអាចនាំឱ្យប៉ះពាល់ដល់ ជំនឿទុកចិត្តអំពីអនាគតិរបស់ចៅក្រម ។

នៅក្នុងការសម្រេចសេចក្តី ចៅក្រម មិនត្រូវធ្វើបុរេវិនិច្ឆ័យ ទាក់ទងទៅនឹង ជាតិសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ពិការភាព អាយុ ស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច និង សង្គមឡើយ ។

ម្ចាស់បណ្តឹងអាជ្ញា ត្រូវស្វែងរកភស្តុតាងដាក់បន្ទុក ដើម្បីធ្វើការចោទប្រកាន់ ប៉ុន្តែមិនត្រូវមានភាពលំអៀងក្នុងការចោទប្រកាន់ឬមិនចោទប្រកាន់ឡើយ គឺត្រូវធានានូវភាពត្រឹមត្រូវ និង ប្រសិទ្ធភាពក្នុងការធ្វើបណ្តឹងអាជ្ញា ។

**ប្រការ៨ : អាកប្បកិរិយា និង ការធ្វើសវនាការ**

នៅពេលដំណើរការនីតិវិធី ចៅក្រមត្រូវ :

-បង្ហាញនូវភាពហ្មត់ចត់ គោរពពេលម៉ោងធ្វើការ អត់ធ្មត់ ចេះគួរសម មានសីលធម៌ និង យុត្តិធម៌នៅពេលបំពេញកិច្ចការតុលាការ ។

-មិនអធិប្បាយនូវអ្វីដែលមិនចាំបាច់ និង មិនសមហេតុផលនៅក្នុងតុលាការ ។

-ក្សោសុភាវធម៌ជានិច្ច និង ជៀសវាងនូវការប៉ះទង្គិច ឬ ការសម្តែងណាមួយដែលអាចនាំឱ្យមានការយល់ច្រឡំ ឬ សង្ស័យអំពីអនាគតិឡើយ ។

**ប្រការ៩ : ការស៊ើបអង្កេត ឬ ស៊ើបសួររឿងក្តី ការប្រាស្រ័យទាក់ទងជាមួយភាគីនៃរឿងក្តី**

ផ្អែកតាមគោលការណ៍ចំពោះមុខចៅក្រម មិនត្រូវប្រាស្រ័យទាក់ទងជាមួយភាគីណាមួយនៅពេលដំណើការនីតិវិធីដោយអវត្តមាននៃភាគីម្ខាងទៀតឡើយ លើកលែងតែច្បាប់អនុញ្ញាត ឬ ភាគីម្ខាងទៀតនោះយល់ព្រម ។ ចៅក្រមមិនត្រូវធ្វើការស៊ើបអង្កេត ឬ ស៊ើបសួរអង្គហេតុនៃរឿងក្តីដោយឯកឯង ទឹង ផ្ទាល់ខ្លួនទាំងក្នុងតុលាការ ទាំងក្រៅតុលាការ

លើកលែងតែច្បាប់អនុញ្ញាត ។

ចំពោះបទល្មើសព្រហ្មទ័ណ្ឌ ចៅក្រមត្រូវស៊ើបអង្កេតរាល់អំពើដែលច្បាប់បញ្ញត្តថាជាបទល្មើស ប៉ុន្តែពេលដែលខ្លួនទទួលបាននូវភស្តុតាងដាក់បន្ទុកលើជនសង្ស័យណាមួយដែលគេបានដឹង ឬ មានជំនឿថា ជាភស្តុតាងបានមកពីការប្រើប្រាស់វិធីមិនស្របច្បាប់ដែលបានរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនជាប់សង្ស័យរូបនោះ ជាពិសេសទាក់ទងនឹងការធ្វើទារុណកម្ម ឬ ប្រព្រឹត្តកម្មអមនុស្សធម៌ ឬ សកម្មភាពរំលោភលើសិទ្ធិមនុស្សផ្សេងៗទៀតនោះត្រូវបដិសេធមិនប្រើភស្តុតាងបែបនោះ ដើម្បីដាក់បន្ទុកលើជនសង្ស័យឡើយ ហើយត្រូវចាត់គ្រប់វិធានការណ៍ចាំបាច់ទាំងអស់ដើម្បីធានាថា បុគ្គល ដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តខាងលើត្រូវបាននាំខ្លួនទៅកាន់តុលាការភ្លាម ។

**ប្រការ១០ : ទំនាក់ទំនងវិជ្ជាជីវៈ សង្គម និង គ្រួសារ**

នៅពេលបំពេញការងារ ចៅក្រមអាចជួប និង ពិភាក្សាជាមួយអ្នកមានវិជ្ជាជីវៈច្បាប់បាន ។ ចៅក្រមក៏អាចចូលរួមផងដែរ ក្នុងសកម្មភាពសង្គមរួមគ្នាជាមួយសមាជិកមកពីផ្នែកដទៃដែលផ្តល់សេវាកម្មច្បាប់ ។

ចៅក្រមមិនគួរជំនុំជំរះរឿងក្តីណា ដែលមានមេធាវីមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គលជាមួយខ្លួនឡើយ ។

**ប្រការ១១ : សកម្មភាពពាណិជ្ជកម្ម**

ចៅក្រមមិនអាចធ្វើជំនួញដើម្បីបានទទួលនូវប្រាក់កំរៃឬអត្ថប្រយោជន៍អ្វីឡើយ ពីព្រោះថា សកម្មភាពនោះអាចរំខានដល់ការបំពេញការងារត្រឹមត្រូវ និង មានប្រសិទ្ធិភាពរបស់ខ្លួន ឬ អាចគេយល់ថា ចៅក្រមប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីរកស៊ី ឬ អាចធ្វើឱ្យចៅក្រម មានទំនាក់ទំនងពាណិជ្ជកម្មជាមួយបុគ្គល ដែលអាចមានរឿងក្តីនៅតុលាការ ។

**ប្រការ១២ : សកម្មភាពសង្គម និង មនុស្សធម៌**

ចៅក្រមត្រូវបានលើកទឹកចិត្តឱ្យចូលរួមសកម្មភាពក្នុងសង្គមជាលក្ខណៈពលរដ្ឋឯកជន ដែលទាក់ទងដល់មនុស្សធម៌ និង អប់រំ ប៉ុន្តែត្រូវជៀសវាងនូវសកម្មភាពណាមួយដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពលំអៀងរបស់ខ្លួន ឬ រំខានដល់ការបំពេញកិច្ចការតុលាការ ឬ អយ្យការ និង មិនត្រូវប្រើប្រាស់កិត្យានុភាពនៃមុខតំណែងតុលាការ ឬ អយ្យការដើម្បីទាញយកផលប្រយោជន៍សំរាប់អង្គការ ឬ ក្រុមពិសេសណាមួយឡើយ ។

**ប្រការ១៣ : ការផ្តល់សេវាកម្មច្បាប់ និង កិច្ចការច្បាប់**

ចៅក្រមមិនត្រូវផ្តល់សេវាកម្មច្បាប់ឡើយ ។ ប្រសិនបើចាំបាច់ ក្រៅពីតួក្តីនៃសំណុំរឿងដែលខ្លួនទទួលបន្ទុក អាចផ្តល់បាន តែមិនត្រូវយកកំរៃឡើយ ។

ចៅក្រមអាចធ្វើកិច្ចការច្បាប់ជាលក្ខណៈផ្ទាល់ខ្លួនបានដូចជា ការបង្រៀន ការសរសេរសៀវភៅ និង វណ្ណកម្មផ្សេងៗ ដើម្បទទួលបានកម្រៃ ។

**ប្រការ១៤ :** អត្ថប្រយោជន៍ហិរញ្ញវត្ថុ

ចៅក្រមមិនត្រូវមានអត្ថប្រយោជន៍ហិរញ្ញវត្ថុ ឬ អត្ថប្រយោជន៍អ្វីផ្សេង ទោះដោយផ្ទាល់ក្តី ឬ ដោយ

ប្រយោលក្តី ក្នុងរឿងក្តីដែលខ្លួនកាន់ឡើយ ។

**ប្រការ១៥ : ការនិយាយស្តីនៅទីសាធារណៈរបស់ចៅក្រម ក្នុងនាមជាបុគ្គល**

សេចក្តីថ្លែងរបស់ចៅក្រម អំពីបញ្ហាច្បាប់អាចមានតម្លៃធំធេង ក្នុងការជំរុញឱ្យមានការយល់ដឹងពីសាធារណៈជន លើប្រព័ន្ធតុលាការ និង ការអភិវឌ្ឍន៍ច្បាប់ ។ ក៏ប៉ុន្តែចៅក្រមត្រូវតែប្រុងប្រយ័ត្នថា ការថ្លែងជាសាធារណៈរបស់ខ្លួន ដែលបានធ្វើជាលក្ខណៈបុគ្គលនោះ អាចជាការឆ្លុះបញ្ចាំងនូវទស្សនៈតុលាការទាំងមូល និង មុខតំណែងតុលាការរបស់ខ្លួន ។ ដូច្នេះចៅក្រមត្រូវតែប្រុងប្រយ័ត្ននៅពេលធ្វើការថ្លែងជាសាធារណៈជាលក្ខណៈបុគ្គល ជាពិសេស ចៅក្រមត្រូវជៀសវាងដាច់ខាតនូវការថ្លែង :

១-ទាក់ទងនឹងភាពចំរូងចំរាស់នយោបាយ

២-ពាក់ព័ន្ធនឹងគណបក្សនយោបាយ

៣-នាំអោយមានវិវាទ ឬ ការរិះគន់ពីបុគ្គលិកតុលាការ ដែលមានទស្សនៈផ្ទុយគ្នា

៤-បញ្ចេញទស្សនៈ ដែលបណ្តាលអោយមានភាពលំអៀង ឬ បុរេវិនិច្ឆ័យចំពោះរឿងក្តី ដែលខ្លួនទទួលបន្ទុក ឬ នឹងទទួលបន្ទុក ។

៥-ទាក់ទងនឹងការសម្រេចសេចក្តី ឬ សាលក្រមរបស់ខ្លួន ។

**ប្រការ១៦ : ការអប់រំផ្នែកច្បាប់**

ដោយផ្អែកលើចំណេះដឹងផ្នែកច្បាប់ និង បទពិសោធន៍ផ្នែកកិច្ចការតុលាការ ឬ អយ្យការ ចៅក្រមអាចរួមចំណែកផ្តល់ការអប់រំផ្នែកច្បាប់ដល់ទាំងសាធារណៈជន ទាំងអ្នកមានវិជ្ជាជីវច្បាប់ ។ ក្នុងន័យនេះចៅក្រមអាច :

១-ចូលរួមផ្តល់ការបណ្តុះបណ្តាលច្បាប់ ដូចជា ការសរសេរ ការផ្តល់បទឧទ្ទេសនាម ឬ បង្រៀនអំពីច្បាប់

២-ចូលរួមជាសមាជិក នៃគណៈកម្មការកែទំរង់ច្បាប់ និង តុលាការ ។

**ប្រការ១៧ : ការដកខ្លួនរបស់ ចៅក្រម**

ប្រសិនបើចៅក្រមមានមូលដ្ឋានច្បាស់ថា ខ្លួនមិនអាចសម្រេចសេចក្តី ដោយអនាគតិបានទេនោះត្រូវដកខ្លួនពីការជំនុំជំរះ ដោយផ្អែកតាមក្រមនីតិវិធី ។

**ឧបសម្ព័ន្ធទី២២**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងយុត្តិធម៌**

លេខ : ០៥៧៨

ថ្ងៃ ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០២១

សាលាឧទ្ធរណ៍ 10 AUG 2021

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជម្រាបជូន**

- **ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ភ្នំពេញ និងតំបន់**
- **ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ និងតំបន់**
- **ឯកឧត្តមប្រធានសាលាដំបូងរាជធានី-ខេត្ត**
- **ឯកឧត្តម លោកជំទាវ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការអនុវត្តគោលការណ៍ណែនាំដែលទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

**យោង ៖** ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី ១៤-០៧-២០១៦ ។

**ជូនភ្ជាប់៖**
- គោលការណ៍ណែនាំស្តីពី នីតិវិធីយុត្តិធម៌អនីតិជនប្រៀបធៀបនឹងនីតិវិធីព្រហ្មទណ្ឌសាមញ្ញ
- គោលការណ៍ណែនាំស្តីពី ប្រព័ន្ធយុត្តិធម៌ទាក់ទងនឹងកុមារនៅក្នុងដំណើរការនីតិវិធីតុលាការក្នុងប្រទេសកម្ពុជា
- គោលការណ៍ណែនាំស្តីពី ការបង្វែរអនីតិជនទំនាស់នឹងច្បាប់។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជ្រាបថា ក្រុមការងារអន្តរក្រសួងដែលរួមមាន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការចូលរួមសហការពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF), ការិយាល័យអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC), អង្គការហាការអន្តរជាតិ (HAGAR International) និងអង្គការសិទ្ធិកុមារអន្តរជាតិ (CRI) ព្រមទាំងមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលអូស្រ្តាលី និងរដ្ឋាភិបាលជប៉ុន បានរៀបចំនូវគោលការណ៍ណែនាំចំនួន ៣ ដូចខាងក្រោម៖

១. គោលការណ៍ណែនាំស្តីពី នីតិវិធីយុត្តិធម៌អនីតិជនប្រៀបធៀបនឹងនីតិវិធីព្រហ្មទណ្ឌសាមញ្ញ។

២. គោលការណ៍ណែនាំស្តីពី ប្រព័ន្ធយុត្តិធម៌ទាក់ទងនឹងកុមារនៅក្នុងដំណើរការនីតិវិធីតុលាការក្នុងប្រទេសកម្ពុជា។

៣. គោលការណ៍ណែនាំស្តីពី ការបង្វែរអនីតិជនទំនាស់នឹងច្បាប់។

គោលការណ៍ណែនាំទាំង ៣ ខាងលើនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងការអនុវត្តច្បាប់ទាក់ទងទៅនឹងយុត្តិធម៌អនីតិជននៅប្រទេសកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត សំដៅបម្រើឧត្តម



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

ប្រយោជន៍របស់កុមារ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងឆ្លើយតបទៅនឹងច្បាប់ជាតិ និងអន្តរជាតិ ជាពិសេសច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។

ក្នុងន័យនេះ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដល់ **ឯកឧត្តម លោកជំទាវ** សូមយកចិត្តទុកដាក់ប្រើប្រាស់គោលការណ៍ណែនាំទាំង ៣ ខាងលើធ្វើជាមូលដ្ឋានបន្ថែមទៀត ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឱ្យមានប្រសិទ្ធភាពស្របតាមស្មារតីនៃច្បាប់នេះ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ និងសង្គមជាតិ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** និង**លោកជំទាវ** ចាត់ចែងអនុវត្តគោលការណ៍ណែនាំទាំង ៣ ខាងលើ ឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម **ឯកឧត្តម** និង**លោកជំទាវ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**__ចម្លងជូន៖__**
- -តុលាការកំពូល
- -មហាអយ្យការអមតុលាការកំពូល
  "ដើម្បីជូនជ្រាប"
- -ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី២៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

រាជធានីភ្នំពេញ,ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៤

លេខ ១៧០ក.ល.វ.ស./១៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើរូបមន្តនៃដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ថាកន្លងមកក្រសួងយុត្តិធម៌បានផ្តល់នូវរូបមន្តនៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតរូបមន្តថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្តីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងរូបមន្តនៃដីការសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

- នៅផ្នែកខាងដើមនៃរូបមន្តពុំមានអ្វីផ្លាស់ប្តូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័តមានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួ ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាសជរា។ល។ ក្នុងស្ថានភាពបែបនេះបើអាចជៀសវាងបាន មិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសំរេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយប្រើគំរូតាមរូបមន្តថ្មីនេះ។

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

1. ចំណុចលេខ១គួចនេះ ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២គួចនេះ ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្តី។

3. ចំណុចលេខ៣គួចនេះ ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤គួចនេះ ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាង របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. សំអាងហេតុសេចក្តីសម្រេច ៖

5. ចំណុចលេខ៥គួចនេះ ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦គួច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់បង្ហាញពីសំអាងហេតុសំរាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិដូចខាងក្រោម៖

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីធាតុផ្សំ/ហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីធាតុផ្សំដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណៈតឹងរឹងគ្រប់គ្រាន់ ដើម្បីសម្រេចបានគោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

ចៅក្រមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន សំរាប់ប្រភេទនីមួយៗនៃរឿងក្តី។

| ប្រភេទនៃបទល្មើស និងមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ + ៦ខែ |
| បទមជ្ឈិម - មាត្រា២០៩ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ -មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| មជ្ឈិម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃ ទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ -មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃ អប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរគួរធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈឹម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្តាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

ផ្នែកបញ្ចប់នៃរូបមន្តនេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្ដឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាកាដំបូងរាជធានី ខេត្ត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាកាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។/

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

ជូនភ្ជាប់ :

- គំរូរូបមន្តដីការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍

"ដើម្បីជូនជ្រាប"